## រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.)

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ
# ស្ដីពី
# ការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០២៥
# របស់ គ.ជ.អ.ប.

អនុម័តដោយៈ គ.ជ.អ.ប.

ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦

# មាតិកា


**មាតិកា** ........ i

**អក្សរកាត់** ........ ii

១. សេចក្តីផ្តើម ........ ៤

២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ........ ៥

ក. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ ........ ៦

ខ. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ២៤

គ. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ........ ៣៣

ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ... ៤១

ង. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាន ........ ៥៤

៣. ស្ថានភាពហិរញ្ញវត្ថុ ........ ៦៤

៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ ........ ៦៦

៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៦ ........ ៦៧

៦. សេចក្តីសន្និដ្ឋាន ........ ៧០

**ឧបសម្ព័ន្ធ**

១. តារាងវឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ ........ ៧២

២. តារាងវឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៥ របស់ស្ថាប័នអនុវត្ត ........ ១០០

៣. តារាងស្ថានភាពនៃការគ្រប់គ្រងហានិភ័យ ........ ១០៣

៤. តារាងគម្រោងដាច់ដោយឡែក ........ ១០៩

# អក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០ |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ (២០២១-២០២៥) ដំណាក់កាលទី១នៃ កជទី២ |
| ផអ៥ទី២ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ (២០២៦-២០៣០) ដំណាក់កាលទី២នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ដ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF/ADB | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF/WB | ផែនការអនុវត្តគណនេយ្យភាពសង្គម |
| TSSD-AF/ADB | គម្រោងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច ដំណាក់កាលទី២ |
| NASLA/ADB | គម្រោងគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| LoCAL/UNCDF | គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| CNP/WB | គម្រោងអាហារូបត្ថម្ភនៅកម្ពុជា |
| ISD/GIZ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា |
| STA/UNDP | ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ |
| CSOs | អង្គការសង្គមស៊ីវិល |

## ១. សេចក្តីផ្តើម

ផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ប្រចាំឆ្នាំ២០២៥ របស់ គ.ជ.អ.ប. ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាផែនការឆ្នាំទី៥ នៃការអនុវត្ត កជទី២ (២០២១-២០៣០) ដែលត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥។ ផែនការនេះ រួមមានលទ្ធផលរំពឹងទុកចំនួន**៣៦** សកម្មភាពជាអាទិភាពចំនួន **៨៧** សកម្មភាពលម្អិតចំនួន **២២៣** សូចនាករចំនួន**១១០** និងគម្រោងថវិកាចំណាយសរុបមានចំនួន **៧.២៩៧.៥២៦ លានរៀល (សមមូលនឹង ១.៧៧៩,៨៨ លានដុល្លារ)** ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន **៧.២០៤.៥៧៧ លានរៀល (សមមូលនឹង ១.៧៥៧,២១លានដុល្លារ) ស្មើនឹង ៩៨,៧៣%** និងថវិកាកម្ចី និងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាមាន**ចំនួន ៩២.៩៥០ លានរៀល (សមមូលនឹង ២២,៥៧លានដុល្លារ) ស្មើនឹង ១,២៧% នៃថវិកាសរុប។** ថវិកាចំណាយសរុបនេះ រួមបញ្ចូលទាំងថវិកាចំណាយសម្រាប់គាំទ្រដល់ការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាចំណាយសម្រាប់គាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ផ.ស.ថ. ឆ្នាំ២០២៥ របស់ គ.ជ.អ.ប. រួមមាន ៥សមាសភាគដូចខាងក្រោម៖

សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ

សមាសភាគទី៥ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

**តារាងទី១ ៖ សកម្មភាព និងផែនការចំណាយសរុបតាមសមាសភាគ (គិតជាលានរៀល)**

| ល.រ. | សមាសភាគ | លទ្ធផលរំពឹងទុក | សកម្មភាពជាអាទិភាព | ថវិកា | | | |
|---|---|---|---|---|---|---|---|
| | | | | រាជរដ្ឋាភិបាល | កម្ចី | ជំនួយឥតសំណង | សរុប |
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | ៥ | ១៨ | ៩.៩២៦ | ៦០.៩៦៦ | ៣១.៩៨៤ | ១០២.៨៧៦ |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៨ | ២០ | ១១.៤៩៣ | - | - | ១១.៤៩៣ |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | ១០ | ២៤ | ៣.៣៣៤ | - | - | ៣.៣៣៤ |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | ៩ | ១៦ | ៧.១៧៦.២៤៨ | - | - | ៧.១៧៦.២៤៨ |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | ៤ | ៩ | ៣.៥៧៦ | - | - | ៣.៥៧៦ |
| **សរុបរួម** | | **៣៦** | **៨៧** | **៧.២០៤.៥៧៧** | **៦០.៩៦៦** | **៣១.៩៨៤** | **៧.២៩៧.៥២៧** |
| **គិតជាភាគរយ** | | | | ៩៨,៧៣% | ០,៨៤% | ០,៤៤% | ១០០% |

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៥នេះ រៀបរាប់អំពីស្ថានភាពនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ ២០២៥ គិតពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥ រួមមាន វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ស្ថានភាពនៃការប្រើប្រាស់ថវិកា បញ្ហាប្រឈមនានា និងសកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៦។

## ២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព

ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៨៧ និងសូចនាករចំនួន ១១០ នៃ ផ.ស.ថ. ឆ្នាំ២០២៥ របស់ គ.ជ.អ.ប. មានសកម្មភាពជាអាទិភាព**ចំនួន៨១បានអនុវត្ត ស្មើនឹង ៩៣% (បានបញ្ចប់ចំនួន៣២ កំពុងអនុវត្តចំនួន៤៩ និងមិនទាន់បានអនុវត្តចំនួន៦)** និងសូចនាករដែលបានអនុវត្តចំនួន**១០៥** លើសូចនាករសរុបចំនួន**១១០** (សូចនាករសម្រេចបាន**១០០%** មានចំនួន**៥២** សូចនាករសម្រេចបានច្រើនជាង និងស្មើនឹង**៥០%** មានចំនួន**២៩** សូចនាករសម្រេចបានក្រោម**៥០%** មានចំនួន**២៤ និង**សូចនាករមិនទាន់អនុវត្តមានចំនួន**៥**) ដូចមានសង្ខេបក្នុងតារាងខាងក្រោម៖

**តារាងទី២ ៖ ស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាព**

| សមាសភាគ | បរិយាយ | សកម្មភាពអាទិភាព | បានអនុវត្ត | | សូចនាករ | បានអនុវត្ត | |
|---|---|---|---|---|---|---|---|
| | | | ចំនួន | (%) | | ចំនួន | (%) |
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | ១៨ | ១៧ | ៩៤% | ៣០ | ២៩ | ៩៧% |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០ | ១៧ | ៨៥% | ៣០ | ២៩ | ៩៧% |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | ២៤ | ២២ | ៩២% | ២៥ | ២៣ | ៩២% |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | ១៦ | ១៦ | ១០០% | ១៥ | ១៤ | ៩៣% |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | ៩ | ៩ | ១០០% | ១០ | ១០ | ១០០% |
| **សរុប** | | **៨៧** | **៨១** | **៩៣%** | **១១០** | **១០៥** | **៩៥%** |

លទ្ធផលសំខាន់ៗនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៥ មានរៀបរាប់តាមសមាសភាគនីមួយៗ ដូចខាងក្រោម៖

## ក. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី១នេះ រួមមានសកម្មភាពជាអាទិភាពចំនួន ១៨ ក្នុងនោះសកម្មភាពអាទិភាពទាំង១៧ ត្រូវបាន និងកំពុងអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់

- គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំលើកទី២៤ នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥ ដោយបានពិនិត្យ ពិភាក្សា និងអនុម័តលើរបៀបវារៈសំខាន់ៗរួមមាន៖ (១). ការអនុម័តកំណត់ហេតុកិច្ចប្រជុំលើកទី២៣ របស់ គ.ជ.អ.ប. (២). ការអនុម័តលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. (៣). ការអនុម័តលើផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ របស់ គ.ជ.អ.ប. និង(៤). ការពិនិត្យ ពិភាក្សា និងកំណត់វិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានលើកឡើងតាមរយៈវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចប់ការពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍ស្តីពីទិន្នន័យដើមគ្រាសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវាវិស័យអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធនឹងគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- គ.ជ.អ.ប. បានដាក់ចេញសៀវភៅណែនាំស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការរៀបចំការពិពណ៌នាមុខតំណែងក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមស្មារតីនៃអនុក្រឹតលេខ៧៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ២. ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព

- អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំកាលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានអនុគណៈកម្មាធិការមុខងារ និងធនធាន** ដើម្បីពិនិត្យ ពិភាក្សា និងលើកយោបល់ជូន គ.ជ.អ.ប. អំពីវិធានការណ៍ដោះស្រាយបញ្ហាប្រឈម និងសំណើ សំណូមពរដែលបានលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣០ ពាក់ព័ន្ធនឹង (១). រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២). ការផ្ទេរនិងការអនុវត្តមុខងារ (៣). ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស (៤). ការគ្រប់គ្រងការប្រើប្រាស់ធនធានហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ (៥). ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយថ្នាក់ជាតិ (៦). ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និង (៧). ការគាំទ្រ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ ការធ្វើអធិការកិច្ច និងការធ្វើសវនកម្មលើរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ដើម្បីពិនិត្យ ពិភាក្សា និងលើកយោបល់ជូន គ.ជ.អ.ប. អំពីវិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរដែលបានលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**០៧** ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក។

- អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុនៃ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំតាមរយៈប្រព័ន្ធអនឡាញ (Zoom Meeting) កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ** ដើម្បីពិនិត្យ ពិភាក្សា និងលើកយោបល់ជូន គ.ជ.អ.ប. អំពីវិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរដែលស្នើដោយរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**២១** ពាក់ព័ន្ធនឹង (១). ការគ្រប់គ្រង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២). ការរៀបចំឱ្យមានប្រាក់សោធននិវត្តន៍សម្រាប់ក្រុមប្រឹក្សា ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សា និងការបង្កើនប្រាក់ឧបត្ថម្ភសម្រាប់ថ្នាក់ដឹកនាំភូមិ (៣). នីតិវិធីនៃការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋលើការនាំចូល និងការប្រើប្រាស់សម្ភារសាងសង់ បរិក្ខារសំណង់ សម្ភារបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅថ្នាក់រាជធានី ខេត្ត និង(៤). ការគាំទ្រ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ ការធ្វើអធិការកិច្ច និងការធ្វើសវនកម្មមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ស្របតាមការណែនាំរបស់ក្រសួងមុខងារសាធារណៈ និងបានរៀបចំជារបាយការណ៍បញ្ជូនទៅក្រុមការងារពិនិត្យឡើងវិញ និងវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងបន្តតាមនីតិវិធី។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៥ របស់ គ.ជ.អ.ប. ការរៀបចំសេចក្តីសម្រេចរួម និងការរៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៦ របស់ គ.ជ.អ.ប.។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានពង្រឹងសមត្ថភាពដល់មន្ត្រី បុគ្គលិករបស់ខ្លួនតាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗ ទស្សនកិច្ចសិក្សា ការចូលរួមសិក្ខាសាលានានាទាំងនៅក្នុងប្រទេស និងក្រៅប្រទេសដូចមានកំណត់នៅក្នុងតារាងខាងក្រោម៖

| ប្រធានបទ | ចំនួនវគ្គ | អ្នកចូលរួម |
| --- | --- | --- |
| ១. វគ្គបណ្តុះបណ្តាលអភិបាលកិច្ច និងការកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាលសាធារណៈទំនើបនៅប្រទេសនូវែលសេឡង់ ដើម្បី (១). ស្វែងយល់ពីគោលការណ៍ស្នូល និងអភិក្រមសម្រាប់ការកែទម្រង់តាមបែបផែននៃការគ្រប់គ្រងរដ្ឋបាលសាធារណៈទំនើប (NPM) ដែលផ្តោតលើការពង្រឹងប្រសិទ្ធភាព គណនេយ្យភាព និងសមិទ្ធកម្មសាធារណៈ (២). ពិនិត្យមើលពីវិធាន និងវិធីសាស្ត្រជាគំរូសម្រាប់ការធ្វើវិមជ្ឈការសេវាសាធារណៈ និងកម្មវិធីការឆ្លើយតបរបស់រដ្ឋចំពោះការផ្តល់សេវាទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន (៣). វិភាគឥទ្ធិពលនៃការពង្រឹងការគ្រប់គ្រងវិស័យឯកជន ការគ្រប់គ្រងរដ្ឋបាលសាធារណៈផ្តោតលើលទ្ធផល (result-oriented government) (៤). កំណត់សមាសភាគអន្តរសកម្មគាំទ្រដល់ការកែទម្រង់អភិបាលកិច្ចសាធារណៈរបស់កម្ពុជា និងស្វែងយល់ពីឧត្តមានុវត្តន៍ចំណុចប្រឈមរបស់រដ្ឋាភិបាលនូវែលសេឡង់ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មជ្ឈការរដ្ឋបាលសាធារណៈ ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា និង(៥). ស្វែងយល់អំពីការដ្ឋានកែទម្រង់តាមស្ថាប័នសាធារណៈរបស់ប្រទេសនូវែលសេឡង់ សង្កេតនិងវាយតម្លៃការអនុវត្តជាក់ស្តែងនៃគោលការណ៍ NPM ក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ | ១វគ្គ | ០២នាក់ |
| ២. សិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពទៅដល់ភ្នាក់ងារអនុវត្តដែលជាស្ថាប័នមានសិទ្ធិទទួលហិរញ្ញប្បទានលើយន្តការទទួលដោះស្រាយបណ្តឹង និងការប្រព្រឹត្តទៅរបស់អង្គភាពសុចរិតភាពឯករាជ្យនៅប្រទេសវៀតណាម។ សិក្ខាសាលានេះ មានគោលបំណងសំខាន់ៗដើម្បី (១). លើកកម្ពស់ការយល់ដឹងអំពីកាតព្វកិច្ចរបស់មូលនិធិអាកាសធាតុបៃតងជុំវិញយន្តការទទួលដោះស្រាយបណ្តឹង និងស្តង់ដានៃសុចរិតភាព (២). ពង្រឹងសមត្ថភាពស្ថាប័នក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយ នីតិវិធីទទួល និងដោះស្រាយបណ្តឹង និង (៣). ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នមានសិទ្ធិទទួលហិរញ្ញប្បទានផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង។ | ១វគ្គ | ០២នាក់ |
| ៣. ទស្សនកិច្ចសិក្សាស្វែងយល់អំពីមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅព្រះរាជាណាចក្រថៃ និងប្រទេសឥណ្ឌូនេស៊ី ក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់អំពី (១). ការបែងចែកសិទ្ធិអំណាច មុខងារ តួនាទី និងការទទួលខុសត្រូវរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋានតាមប្រភេទផ្សេងៗគ្នាក្នុងការជំរុញ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការដោះស្រាយបញ្ហាប្រឈម និងការផ្តល់សេវាជូនប្រជាពលរដ្ឋ (២). រចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច ប្រភពធនធានហិរញ្ញវត្ថុ និងដំណើរការប្រព្រឹត្តទៅនៃទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋាន (ទីប្រជុំជន និងជនបទ) និង (៣). យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិលើការបំពេញការងាររបស់រដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋានតាមប្រភេទផ្សេងៗគ្នា។ | ២ទស្សនកិច្ចសិក្សា | ៣២នាក់ |

| | | |
|---|---|---|
| ៤. ទស្សនកិច្ចសិក្សាស្តីពី "ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យមូលដ្ឋាន" នៅរដ្ឋធានីប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន។ ទស្សនកិច្ចសិក្សានេះ មានគោលបំណងដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលមូលដ្ឋាននៅកម្ពុជា តាមរយៈការផ្តល់ឱកាសជូនអ្នកគ្រប់គ្រងមន្ទីរពេទ្យបង្អែកជ័យលាភី (តាមរយៈការប្រឡង ប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូ វិស័យសុខាភិបាល) បានសិក្សាស្វែងយល់ និងយកមកអនុវត្តនូវមេរៀន និងបទពិសោធន៍ល្អៗនៃដំណើរការផ្តល់សេវាសុខាភិបាលសាធារណៈ។ | ១ទស្សនកិច្ចសិក្សា | ១នាក់ |
| ៥. សិក្ខាសាលាស្តីពី "ការបញ្ជ្រាបកិច្ចការពារសង្គមនៅសហគមន៍មូលដ្ឋានអំពីការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ" នៅព្រះរាជាណាចក្រថៃ។ | ១វគ្គ | ១នាក់ |
| ៦. សិក្ខាសាលាថ្នាក់តំបន់ស្តីពីការផ្តល់ដំណោះស្រាយក្នុងការពន្លឿនសកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងយេនឌ័រនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៅទីក្រុងបាងកក ប្រទេសថៃរបស់គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ជំហានទី២។ សិក្ខាសាលានេះ មានគោលបំណង (១). ពិភាក្សា និងសិក្សាស្វែងយល់លើយន្តការហិរញ្ញប្បទានសម្រាប់គាំទ្រសកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងយេនឌ័រ និងបរិយាបន្នសង្គមជាមួយបណ្តាប្រទេសដៃគូអនុវត្តកម្មវិធី EmPower ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក (២). ប្រមូលធាតុចូល បទពិសោធន៍ បញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ឬផែនការសកម្មភាពអាកាសធាតុដែលឆ្លើយតបទៅនឹងយេនឌ័រ និងបរិយាបន្នសង្គមក្នុងការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (៣). ពង្រឹងសមត្ថភាពដល់អ្នកចូលរួមទៅលើការពិនិត្យគោលនយោបាយនានា ដែលឆ្លើយតបទៅនឹងយេនឌ័រដែលមានស្រាប់នៅតាមបណ្តាប្រទេសនីមួយៗ ដើម្បីអាចមានលទ្ធភាពរៀបចំសកម្មភាពអាកាសធាតុឆ្លើយតបទៅនឹងយេនឌ័រ និងបរិយាបន្នសង្គម និង (៤). ពង្រឹងកិច្ចសហប្រតិបត្តិការ និងការរៀនសូត្រ ដកបទពិសោធន៍ឆ្លងតំបន់ក្នុងចំណោមអ្នកពាក់ព័ន្ធតំណាងស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យធនាគារក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលឆ្ពោះទៅរកសកម្មភាពអាកាសធាតុឆ្លើយតបយេនឌ័រ និងបរិយាបន្នសង្គម។ | ១វគ្គ | ០២នាក់ |
| ៧. ទស្សនកិច្ចសិក្សាស្តីពី "ការគិតគូរឡើងវិញអំពីការគាំពារសង្គម និងការប្រែប្រួលអាកាសធាតុ" នៅទីក្រុងកង់ប៊ែរ៉ា ប្រទេសអូស្ត្រាលី ក្នុងគោលបំណង (១). លើកកម្ពស់នូវចក្ខុវិស័យរួម និងការយល់ដឹងអំពីការសម្របខ្លួនទៅនឹងការគាំពារសង្គម (២). បង្កើនការយល់ដឹងអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងអន្តរកម្មរវាងប្រព័ន្ធគាំពារសង្គមនៅប្រទេសអូស្ត្រាលី និង(៣). ផ្តល់នូវជំនាញដល់អ្នកចូលរួមអំពីការកំណត់ចំណុចចូលជាយុទ្ធសាស្តសម្រាប់ការធ្វើសមាហរណកម្មនៃការគាំពារសង្គម និងរបៀបវារៈការប្រែប្រួលអាកាសធាតុ។ | ១វគ្គ | ១នាក់ |

| | | |
|---|---|---|
| ៨. សន្និសីទរង្វាន់ព្រះមហាឱលឆ្នាំ២០២៥ ស្តីពី "ការធ្វើឱ្យប្រសើរឡើងសុខភាពនាពេលអនាគតតាមរយៈនវានុវត្តន៍ និងសិទ្ធិសមធម៌" នៅទីក្រុងបាងកក ប្រទេសថៃ។ សន្និសីទនេះ ផ្តោតលើប្រធានបទសំខាន់ៗចំនួន៣ រួមមាន (១). នវានុវត្តន៍បច្ចេកវិទ្យា ដើម្បីពង្រឹងប្រព័ន្ធសុខាភិបាល និងជំរុញការសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល (២). សមធម៌ ក្រមសីលធម៌ និងការលើកកម្ពស់សិទ្ធអំណាចជនងាយរងគ្រោះ និង(៣). ការគ្រប់គ្រង គោលនយោបាយ និងការផ្តល់សេវាក្នុងសម័យបច្ចេកវិទ្យាឌីជីថល។ | ១វគ្គ | ១នាក់ |
| ៩. ទស្សនកិច្ចសិក្សាស្វែងយល់អំពីការរៀបចំកម្មវិធីសិក្សាសាលាបណ្តុះបណ្តាល និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលមូលដ្ឋាននៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២២ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់អំពី (១). កម្មវិធីសិក្សារបស់សាលាបណ្តុះបណ្តាល ដើម្បីរួមចំណែករៀបចំកម្មវិធីសិក្សារបស់សាលាបណ្ឌិតសភាភាពជាអ្នកដឹកនាំតេជោក្នុងបរិបទពហុបក្ស (២). ការបែងចែកសិទ្ធិអំណាច មុខងារ តួនាទី និងការទទួលខុសត្រូវរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទផ្សេងៗគ្នានៃសាធារណរដ្ឋប្រជាមានិតចិនក្នុងការជំរុញ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការដោះស្រាយបញ្ហាប្រឈម និងការផ្តល់សេវាសាធារណៈ (៣). រចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង នីតិវិធីផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទផ្សេងនៃសាធារណរដ្ឋប្រជាមានិតចិន និង (៤). យន្តការគាំទ្រ តាមដាន និងត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទផ្សេងៗគ្នានៃសាធារណរដ្ឋប្រជាមានិតចិន។ | ១ទស្សនកិច្ចសិក្សា | ៥០នាក់ |
| ១០. កម្មវិធី "ការផ្តួចផ្តើមថ្នាក់ដឹកនាំវ័យក្មេងរបស់អាស៊ាន" (The Young Southeast Asian Leaders Initiative Professional Fellows Program-YSEALI PFP) ក្រោមប្រធានបទ "អភិបាលកិច្ច និងសង្គម" នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក។ កម្មវិធីនេះ មានគោលបំណងដើម្បី (១). ចែករំលែកនូវមេរៀន និងការផ្លាស់ប្តូរបទពិសោធន៍ជាក់ស្តែងរវាងថ្នាក់ដឹកនាំវ័យក្មេងនៅបណ្តាប្រទេសអាស៊ានទាំង១០ និងប្រទេសទីម័រខាងកើត ជាមួយសហរដ្ឋអាមេរិក "អភិបាលកិច្ច និងសង្គម" (២). សិក្សាអំពីជំនាញភាពជាអ្នកដឹកនាំ និង(៣). ចុះកម្មសិក្សាដោយផ្ទាល់នៅសាលាក្រុង Hampton នៃរដ្ឋ Virginia សហរដ្ឋអាមេរិក ដើម្បីសិក្សាស្វែងយល់ពីបទពិសោធន៍នៃការលើកកម្ពស់បរិវត្តកម្មឌីជីថលរបស់សាលាក្រុង Hampton។ | ១វគ្គ | ១នាក់ |

**៤. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ដ.វ.វ.)**

- គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៤ និងបានចុះសេចក្តីសម្រេចរួមឆ្នាំ២០២៥ រវាង គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២២ ព្រមទាំងបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៥របស់ខ្លួន

- គ.ជ.វ.វ. នៃរដ្ឋបាលរាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៤ និងបានចុះសេចក្ដីសម្រេចរួមឆ្នាំ២០២៥ រវាង គ.ជ.អ.ប. ជាមួយនឹងរាជធានី ខេត្តទាំង២៥ ព្រមទាំងបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥របស់ខ្លួន

- ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិស្ដីពី "វឌ្ឍនភាពនៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ" នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៥ ដែលមានអ្នកចូលរួមចំនួន ១៣៥រូប

- ក្រសួងព័ត៌មានបានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង និងព្រឹត្តិការណ៍នានាស្ដីពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួងព័ត៌មាន នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ដែលមានអ្នកចូលរួមសរុប២០០រូប ស្ត្រី៧៨រូប។

## ៥. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

- យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.) បានរៀបចំកិច្ចប្រជុំឆ្លាស់វេនរបស់ខ្លួនចំនួន**២ដង** រួមមាន៖

(១). លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំកិច្ចប្រជុំប្ដូរវេននៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.) ប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥ នៅសណ្ឋាគារ Raffle the Royal ភ្នំពេញ លើរបៀបវារៈចំនួន៣ រួមមាន៖ (១). ការរៀបចំពិធីប្រកាស និងដាក់ឱ្យអនុវត្ត "ចក្ខុវិស័យ និងយុទ្ធសាស្ត្រស្ដីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល" (២). វឌ្ឍនភាពនៃការរៀបចំផែនការសកម្មភាពឆ្នាំ២០២៥ នៃ យ.ស.ក និង (៣). ការពិនិត្យ និងកែសម្រួលបញ្ចប់ចក្ខុវិស័យ និងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។

(២). អគ្គលេខាធិការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ បានដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំអន្តរកំណែទម្រង់របស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥ ដើម្បីពិនិត្យ ពិភាក្សាលើ (១). ការរៀបចំយន្តការលើកកម្ពស់អភិបាលកិច្ចកំណែទម្រង់តាមក្រសួងស្ថាប័ន សម្រាប់លើកកម្ពស់ការទទួលខុសត្រូវ និងសង្គតិភាពលើការងារកែទម្រង់នានានៅតាមក្រសួង ស្ថាប័ន និង (២). ការរៀបចំឱ្យមានគោលការណ៍ណែនាំរួមមួយអំពីការរៀបចំ SOP សម្រាប់ការផ្ដល់សេវារដ្ឋបាលនៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ។

- ចក្ខុវិស័យ និងយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាលត្រូវបានពិនិត្យ និងឯកភាពដោយប្រធានគណៈកម្មាធិការកែទម្រង់គន្លឹះទាំង៥ និងទទួលបានការអនុម័តពី **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៥។

## ៦. ការរៀបចំវេទិកាការងាររាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- វេទិកាការងាររាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្ដីពី "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**" ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ វេទិកានេះត្រូវបានប្រារព្ធធ្វើឡើង ដោយមានអ្នកចូលរួមដោយផ្ទាល់សរុបចំនួនប្រមាណ ១.៤០០នាក់ ដែលមានសមាសភាពមកពីតំណាងព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាជិករាជរដ្ឋាភិបាល ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់ ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ព្រមទាំងមានការចូលរួមតាមប្រព័ន្ធអនឡាញ (ZOOM) ដែលរៀបចំឡើងនៅតាមរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញនានា និងនៅតាមក្រសួងមួយចំនួនសរុបចំនួន ២៣៧គណនី មានអ្នកចូលរួមសរុបប្រមាណជាង១០.០០០នាក់ផងដែរ។

ជាលទ្ធផល វេទិកានេះបានវាយតម្លៃជារួមថា រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងដើរលើមាគ៌ាដ៏ត្រឹមត្រូវនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយផ្អែកទៅលើបរិបទផ្ទៃកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាក់ស្ដែងរបស់កម្ពុជា និងដោយមានផែនការច្បាស់លាស់ មានដំណាក់កាលមានការសម្របសម្រួល ការពិគ្រោះយោបល់ និងការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធដោយផ្អែកលើអភិក្រម **ធ្វើផង រៀនសូត្រដកស្រង់បទពិសោធន៍ផង និងកែលម្អផង**។ ទន្ទឹមនឹងនោះ អង្គវេទិកាក៏បានកត់សម្គាល់ឃើញថា បើទោះបីជាកំណែទម្រង់នេះ មានការវិវឌ្ឍជាបន្តបន្ទាប់តាមដំណាក់កាលនីមួយៗក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវរួមគ្នាដោះស្រាយ ដើម្បីបន្តជំរុញ និងពង្រឹងដំណើរការកែទម្រង់នេះឱ្យកាន់តែមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយហានិភ័យដែលអាចកើតឡើងជាយថាហេតុ។ លទ្ធផលនៃវេទិកាការងាររាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំជារបាយការណ៍លម្អិតដោយឡែក។

- ជារួម លទ្ធផលនៃការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរទាំង៦៧ ដែលបានលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៥នេះ (តារាងលទ្ធផលនៃអនុវត្តផែនការសកម្មភាព មានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធនៃរបាយការណ៍នេះ) រួមមានដូចខាងក្រោម៖

- បញ្ហាប្រឈម សំណើសំណូមពរចំនួន៣៤ ដែលបានគ្រោងអនុវត្តនៅឆ្នាំ២០២៥ រួមមាន៖ (១). បញ្ហាប្រឈម សំណើសំណូមពរចំនួន៤បានអនុវត្ត (២). បញ្ហាប្រឈម សំណើសំណូមពរចំនួន២៨បាននិងកំពុងដំណើរការអនុវត្ត និង(៣). បញ្ហាប្រឈម សំណើសំណូមពរចំនួន២ពុំទាន់បានអនុវត្ត
- បញ្ហាប្រឈម សំណើសំណូមពរចំនួន២៤ ដែលគ្រោងអនុវត្តពហុឆ្នាំ (២០២៥-២០២៨) រួមមាន៖ (១). បញ្ហាប្រឈម សំណើសំណូមពរចំនួន១បានអនុវត្ត (២). បញ្ហាប្រឈម សំណើ

សំណូមពរចំនួន១៥បាននិងកំពុងដំណើរការអនុវត្ត និង (៣). បញ្ហាប្រឈម សំណើសំណូមពរចំនួន៨នៅពុំទាន់បានអនុវត្ត ឬគ្រោងអនុវត្តនៅឆ្នាំ២០២៦។

**៧. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា**

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (ក.ប.អ.ប.) លើកទី២១ នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ លក្ខខណ្ឌការងារបច្ចេកទេស និងសូចនាករត្រួតពិនិត្យរួមឆ្នាំ២០២៥-២០២៦ ក្រោមអធិបតីភាព **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. និងជាប្រធានក្រុមការងារបច្ចេកទេស ក.ប.អ.ប.** និងតំណាងដៃគូអភិវឌ្ឍន៍ជាសហប្រធាននៃ ក.ប.អ.ប. ដែលរួមមានតំណាងស្ថានទូតអាល្លឺម៉ង់ និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។

- គ.ជ.អ.ប. ដាក់ចេញសេចក្តីសម្រេចលេខ០៥៨ សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេស ក.ប.អ.ប. ដែលមានសមាសភាពមកពី គ.ជ.អ.ប. តំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច យុទ្ធជននិងយុវនីតិសម្បទា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងនាមជាសេនាធិការឱ្យ គ.ជ.អ.ប. បានជួបពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នានា និងអង្គការសង្គមស៊ីវិល ដើម្បីបន្សុីវាងកម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលជាមួយនឹងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបានកៀរគរការគាំទ្រមកលើកិច្ចដំណើរការនៃការកែទម្រង់ដែលរួមមានដូចជា GIZ, WB, ADB, UNDP, UNCDF, World Vision, IFAD, DFAT, UN-Environment, GCF, Luxambur។ល។

**៨. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួងកិច្ចការនារីក្រោមការគាំទ្រពីគម្រោង ISD/GIZ បានចុះសិក្សាស្វែងយល់អំពីបរិបទ និងស្ថានភាពនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ដើម្បីកំណត់បញ្ហាសំខាន់ៗ តម្រូវការ និងចំណុចអាទិភាពនៅថ្នាក់ក្រោមជាតិ ការកំណត់អំពីឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនូវការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមតាមរយៈការផ្តល់សេវាសាធារណៈ និងការប្រមូលព័ត៌មាន ដើម្បីបានជាធាតុចូលក្នុងការរៀបចំ

កែសម្រួលសេចក្តីព្រាងយុទ្ធសាស្ត្រសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមឱ្យកាន់តែល្អប្រសើរ ដែលមានសមាសភាពចូលរួមផ្តល់កិច្ចសម្ភាសន៍សរុបប្រមាណ**១៨៤នាក់** (ស្ត្រី១៣៣នាក់)។

- លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងកិច្ចការនារី បាននិងកំពុងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម (GESEI) ដែលជាឧបសម្ព័ន្ធកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២។

- ឆ្នាំ២០២៥នេះ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ក្រសួង ស្ថាប័នសំខាន់ៗ ជាពិសេសក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃបានរៀបចំវគ្គបណ្តុះបណ្តាលនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ដូចខាងក្រោម៖

| **ប្រធានបទ** | **ចំនួនវគ្គ** | **អ្នកចូលរួម** |
|---|---|---|
| វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពី «ការរៀបចំ និងការអនុវត្តការងារបញ្ជ្រាបយេនឌ័រក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ» ដល់អនុប្រធានអចិន្ត្រៃយ៍ គ.ក.ស.ក និងមន្ត្រីបច្ចេកទេសនៃមន្ទីរកិច្ចការនារី ១៧ខេត្ត នៅ២តំបន់គឺខេត្តព្រៃវែង និងខេត្តព្រះវិហារ។ | ២វគ្គ | ១០៤នាក់ (ស្ត្រី ៧៨រូប) |
| វគ្គបណ្តុះបណ្តាលថ្នាក់ជាតិស្តីពី «ការរៀបចំនិងអនុវត្តកម្មវិធីបញ្ជ្រាបយេនឌ័រ និងធ្វើបរិវត្តកម្មយេនឌ័រនៅថ្នាក់ក្រោមជាតិ» ដើម្បីអភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃមន្ទីរកិច្ចការនារីរាជធានី-ខេត្តក្នុងការរៀបចំនិងធ្វើបរិវត្តកម្មយេនឌ័រតាមវិស័យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ | ១វគ្គ | ៥៨នាក់ (ស្ត្រី៤៥រូប) |

- គ.ក.ស.ក. រាជធានី ខេត្ត ចំនួន២៥ បានរៀបចំកិច្ចប្រជុំជាប្រចាំចំនួន**៣០០លើក** និងបានដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធអំពីហិង្សា ជនងាយរងគ្រោះជាស្ត្រីនិងកុមារ ការផ្តល់យោបល់លើការថែទាំមាតាមានផ្ទៃពោះ ការអប់រំកុមារ ការរក្សាអនាម័យ និងការផ្តល់សេវាសង្គមផ្សេងៗទៀត ដែលមានសមាសភាពចូលរួមសរុបចំនួន **៧.៤៤៤នាក់** ស្ត្រីចំនួន **៥.២១២នាក់**។

- គ.ក.ស.ក. ក្រុង ស្រុកចំនួន **២១០** បានរៀបចំកិច្ចប្រជុំជាប្រចាំចំនួន **២.៤៩៦លើក** និងបានដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធអំពីហិង្សា ជនងាយរងគ្រោះជាស្ត្រីនិងកុមារ ការផ្តល់យោបល់លើការថែទាំមាតាមានផ្ទៃពោះ ការអប់រំកុមារ ការរក្សាអនាម័យ និងការផ្តល់សេវាសង្គមផ្សេងៗទៀត ដែលមានសមាសភាពចូលរួមសរុបចំនួន **៤៥.៩៥២នាក់** ស្ត្រីចំនួន **២៩.៣២៤នាក់**។ ទន្ទឹមនេះ គ.ក.ស.ក. ក្រុង ស្រុកក៏បានធ្វើការផ្សព្វផ្សាយណែនាំ និងបណ្តុះបណ្តាលបន្តស្តីពីគោលនយោបាយ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមចំនួន **១៦វគ្គ** សរុបចំនួន **៧៧៨នាក់** ស្ត្រីចំនួន ៤០០នាក់។

- គ.ក.ន.ក. ឃុំ សង្កាត់ចំនួន **១.៦៥២** បានរៀបចំកិច្ចប្រជុំជាប្រចាំចំនួន **១៥.៨៤៤លើក** ដើម្បីពង្រឹង តួនាទី ភារកិច្ចរបស់ គ.ក.ន.ក. សរុបចំនួន **២២៧.០២៤នាក់** ស្ត្រីចំនួន **១២៣.៨០៤នាក់**។ ទន្ទឹមនេះ គ.ក.ន.ក. ឃុំ សង្កាត់ក៏បានផ្សព្វផ្សាយអំពីគោលនយោបាយ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម នៅឃុំ សង្កាត់របស់ខ្លួនចំនួន **២២វគ្គ** ដែលមានសមាសភាពចូលរួមសរុបចំនួន **១.៣៨៦នាក់** ស្ត្រីចំនួន **៨៨៧នាក់**។

## ៩. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងធ្វើបច្ចុប្បន្នភាពលើយុទ្ធសាស្ត្រស្តីពីប្រាស្រ័យទាក់ទង ដើម្បីធ្វើឱ្យប្រសើរឡើងនូវការលើកកម្ពស់ការយល់ដឹង និងការចូលរួមអនុវត្តនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាពលរដ្ឋ។
- បានបញ្ចប់ការរចនាគំរូរូបរាង (Website Template) ទំព័រដើម (Home Page) និងទំព័ររង (Sub Page) នៃគេហទំព័រថ្មីរបស់ គ.ជ.អ.ប. ដោយផ្អែកលើគេហទំព័របច្ចុប្បន្ន។
- បាននិងកំពុងពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលគ្រោងនឹងបញ្ចប់នៅក្នុងឆមាសទី២ ឆ្នាំ២០២៥នេះ។
- បានបន្តផ្សព្វផ្សាយ និងដាក់បញ្ចូលឯកសារព័ត៌មានក្នុងគេហទំព័រ បណ្តាញសង្គម (Facebook YouTube និង Channel Telegram) និងបណ្ណាល័យអេឡិចត្រូនិចដែលមានលទ្ធផលដូចខាងក្រោម៖

| **សកម្មភាព** | **លទ្ធផល** |
|---|---|
| បញ្ចូលឯកសារនានាពាក់ព័ន្ធទៅនឹងកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិក របស់ គ.ជ.អ.ប. | ចំនួន **១៦.៥៦៩ ឯកសារ** |
| បណ្ណាល័យអេឡិចត្រូនិក (E-Library) របស់ គ.ជ.អ.ប. បើកជូនសាធារណៈជនចូលទស្សនា និងសិក្សាស្រាវជ្រាវឯកសារ | អ្នកចូលទស្សនាមានចំនួន **១២.៨៣៤.៩៥៥ដង** |
| ផ្សព្វផ្សាយព័ត៌មានសំខាន់ៗតាម Facebook page របស់លេខាធិការដ្ឋាន គ.ជ.អ.ប. | ចំនួនអ្នកចូលចិត្ត (Like) ចំនួន **៣៧.៩៨៦នាក់**ចំនួនអ្នកតាមដាន (Follower) **៤២.៤០០នាក់** |
| ផ្សព្វផ្សាយព័ត៌មានសំខាន់ៗតាម Telegram Channel របស់លេខាធិការដ្ឋាន គ.ជ.អ.ប. | ចំនួនអ្នកតាមដាន **១.៩៤២នាក់** |
| Telegram Chanel របស់គណនេយ្យភាពសង្គម | ចំនួនអ្នកតាមដាន **២.២៥៧នាក់** |
| YouTube របស់លេខាធិការដ្ឋាន គ.ជ.អ.ប. | ចំនួនអ្នកតាមដាន **២.៥៧៩នាក់** |
| Upload គេហទំព័រ គ.ជ.អ.ប. | ឯកសារសរុបចំនួន **៣.៥៨០** |

| | |
|---|---|
| កម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម (SA Mobile Apps) របស់លេខាធិការដ្ឋាន គ.ជ.អ.ប. | សរុបចំនួន **១០.៤០០នាក់** (ចំនួន **៤.៨៣៧នាក់** ប្រើប្រព័ន្ធ iOS និង ចំនួន **៥.៥៧៤នាក់** ប្រើប្រព័ន្ធ Android) |

## ១០. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តចំណាក់កាលនីមួយៗនៃ កជទី២

- ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ ជាឆ្នាំទី៥ នៃផែនការអនុវត្តរយៈពេល៥ឆ្នាំដំណាក់កាលទី១ (២០២១-២០២៥)។ គិតត្រឹមឆ្នាំ២០២៥នេះ ការអនុវត្តផអ៥ទី១ សម្រេចបានលទ្ធផលដូចខាងក្រោមៈ
    - លទ្ធផលរំពឹងទុកចំនួន៣៦នៃលទ្ធផលរំពឹងទុកសរុបចំនួន៣៧នៃផអ៥ទី១ បាននិងកំពុងអនុវត្តស្មើនឹង ៩៧% (បានបញ្ចប់ចំនួន៤ និងកំពុងអនុវត្តចំនួន៣២) និងលទ្ធផលរំពឹងទុកចំនួន០១ មិនទាន់បានអនុវត្ត គឺ "ក្របខ័ណ្ឌអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត"។
    - សកម្មភាពជាអាទិភាពចំនួន៩០ ស្មើនឹង៨០% នៃសកម្មភាពជាអាទិភាពសរុបចំនួន១១៣ ត្រូវបានអនុវត្ត ក្នុងនោះសកម្មភាពជាអាទិភាពចំនួន២៧ ស្មើនឹង២៤% បានអនុវត្តបញ្ចប់ ១០០% តាមផែនការកំណត់។ សូចនាករចំនួន១២៧ ស្មើនឹង៧៧% នៃសូចនាករសរុបចំនួន១៦៥ ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន៣៨ ស្មើនឹង២៣% បានសម្រេច១០០% តាមការគ្រោងទុក។

## ១១. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

- ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ត្រូវបានអនុម័តនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥ ព្រមទាំងបានបោះពុម្ពនូវរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ចំនួន១០០ក្បាល និងផែនការសកម្មភាពនិងថវិកាឆ្នាំ២០២៥ របស់ គ.ជ.អ.ប. ចំនួន១០០ក្បាល ដើម្បីបែងចែក និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បានសម្របសម្រួល ពិនិត្យ និងអនុម័តសេចក្តីសម្រេចរួមឆ្នាំ២០២៥ រវាងក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និង គ.ជ.អ.ប. សរុបក្រសួង ស្ថាប័នចំនួន២២ (សកម្មភាពលម្អិតចំនួន **១២៦** និងថវិកាគ្រោងសរុបចំនួន**១០.៩០៨ លានរៀល**) និងរដ្ឋបាលរាជធានី ខេត្ត ចំនួន២៥ (សកម្មភាពលម្អិតចំនួន **៤៩** និងថវិកាគ្រោងសរុប **១៨.៧០៧ លានរៀល**) ដូចមានភ្ជាប់ជូននៅឧបសម្ព័ន្ធទី២ ៖ វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៥របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។

## ១២. ការរៀបចំ និងការដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃ កជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ

- គ.ជ.អ.ប. បានបញ្ជូនសេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦ ពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (លិខិតលេខ

០៤៨ ស.ជ.ណ./គ.ជ.អ.ប.ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥) ដែលរួមមាន៖ លទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងក្របខ័ណ្ឌពេលវេលា ដើម្បីឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យ និងដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ ដើម្បីធានាដល់ការចូលរួមអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។

- ក្រសួង ស្ថាប័នចំនួន២២ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥ បានដាក់បញ្ចូលនូវកិច្ចការអាទិភាពនានានៃកំណែទម្រង់ទៅក្នុងផែនការយុទ្ធសាស្ត្រ និងគម្រោងថវិការបស់ស្ថាប័នសាមីនីមួយៗ។

**១៣. ការរៀបចំគម្រោងគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្សុំជាមួយនឹង កជទី២**

- គ.ជ.អ.ប. ដែលមានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការបានសម្របសម្រួល និងអនុវត្តគម្រោងដាច់ដោយឡែកដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ចំនួន **០៨គម្រោង** និងមានថវិកាសរុបចំនួន **៣៣.៩១៥.៨៤៦ ដុល្លារអាមេរិក** រួមមាន៖

1. គម្រោងគណនេយ្យភាពសង្គម (ISAF/WB) (២០២៣-២០២៥) ថវិកាចំនួន **៤លានដុល្លារ។**
2. គម្រោងការលើកកម្ពស់ការផ្ដល់សេវាសាធារណៈ (ISD/GIZ/SDC/Luxambur) (២០២២-២០២៥) ថវិកាចំនួន **១០.៥២២.៣៦៩ដុល្លារ។**
3. គម្រោងការពង្រឹងតម្លាភាព និងគណនេយ្យភាព (STA/UNDP) (២០២៣-២០២៥) ថវិកាចំនួន **៨៩៧.៧៥២ដុល្លារ។**
4. គម្រោងការពង្រឹងភាពអង់អាចដល់ស្ត្រី (Empower II/UNEP) (២០២៥-២០២៦) ថវិកាចំនួន **១៦០.០០០ដុល្លារ។**
5. គម្រោងការអភិវឌ្ឍសមត្ថភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. លើហិរញ្ញប្បទានអាកាសធាតុ (KHM-011/GCF) (២០២៥-២០២៦) ថវិកាចំនួន **៤៤១.៤៦០ដុល្លារ។**
6. គម្រោងការបន្ស៊ាំនឹងបម្រែបម្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ (LoCAL/UNCDF) (ខែមិថុនា-ខែធ្នូ ២០២៥) ថវិកាចំនួន **៩៤.២៦៥ដុល្លារ** (បានពន្យារពេលអនុវត្តដល់ខែមិថុនា ឆ្នាំ២០២៦)។
7. គម្រោងអាហារូបត្ថម្ភ (CNP2/WB) (២០១៩-២០២៦) ថវិកាចំនួន **១៧,៨លានដុល្លារ។**
8. គម្រោងមូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព (SDGs/UNDP) (កក្កដា-ធ្នូ ២០២៥) ថវិកាចំនួន **៤០.០០០ដុល្លារ** (បានអនុវត្ត និងបិទបញ្ចប់)។

*វឌ្ឍនភាពនៃការអនុវត្តគម្រោងនីមួយៗមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃរបាយការណ៍នេះ។*

- ទន្ទឹមនេះ គ.ជ.អ.ប. ក៏បានលើកសំណើគម្រោងថ្មីចំនួន៥គម្រោង មានថវិកាសរុបប្រមាណជាង **១៤០លានដុល្លារអាមេរិក** រួមមាន៖

1. គម្រោងធារាសាស្ត្រ និងកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ (CAISAR/IFAD-GCF) (២០២៦-២០៣២) ថវិកាចំនួន **៤៥លានដុល្លារ** (បានទទួលការអនុម័តពី IFAD;

AIIB; GCF និងបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥) ដែលគ្រោងអនុវត្តនៅឆ្នាំ២០២៦។

២. គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុ(SRED/ADB) (២០២៦-២០៣១) ថវិកាចំនួន **៧០លានដុល្លារ** (បានទទួលការអនុម័តលើឯកសារទស្សនទាន និងកំពុងរៀបចំសំណើគម្រោងពេញលេញ)។

៣. គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (LGCC III /GCF) (២០២៦-២០៣០) ថវិកាចំនួន **១០លានដុល្លារ** (បានទទួលការអនុម័តលើឯកសារទស្សនទាន និងបានអនុម័តលើសំណើគម្រោងពេញលេញ) ដែលនឹងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០២៦។

៤. កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា ដំណាក់កាលទី២ (ISD-II/GIZ/SDC/Luxambur)គាំទ្រថវិកាដោយរដ្ឋាភិបាលអាល្លឺម៉ង់ រដ្ឋាភិបាលស្វីស និងរាជរដ្ឋាភិបាលលុចហ្សំបួរ (២០២៦-២០២៩) ថវិកាចំនួន **២០លានអឺរ៉ូ** ដែលនឹងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០២៦។

៥. គម្រោងគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានធន់ទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាព (SCALED-WB) ថវិកាចំនួន **៨០លានដុល្លារ** (បានទទួលអនុម័តលើឯកសារទស្សនទាន និងកំពុងរៀបចំសំណើរគម្រោងពេញលេញ)។

## ១៤. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

- បានបញ្ចប់ការវាយតម្លៃការអនុវត្តកម្មវិធីជាតិ ដំណាក់កាលទី១ ដែលបានរៀបចំឡើងដោយទីប្រឹក្សាឯករាជ្យក្រោមការគាំទ្រហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា ដោយទទួលបានការឯកភាពពី **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ និងបានបោះពុម្ពសៀវភៅរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃកម្មវិធីជាតិ ដំណាក់កាលទី១ ចំនួន ២០០ក្បាល និងបានផ្សព្វផ្សាយរបាយការណ៍នេះជូនសាធារណជនសម្រាប់សិក្សាស្វែងយល់ជាមេរៀនបទពិសោធន៍ បញ្ហាប្រឈម និងសមិទ្ធផលសំខាន់ៗនៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអស់រយៈពេល១០ឆ្នាំ(២០១០-២០២០)។

- បានបញ្ចប់ការវាយតម្លៃផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី១ (២០២១-២០២៥) ឬការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិ ដំណាក់កាលទី២ (២០២១-២០៣០) ដើម្បីវាយតម្លៃអំពីវឌ្ឍនភាព និងបញ្ហាប្រឈមធៀបទៅនឹងលទ្ធផលរំពឹងទុកនៃផអ៥ទី១ និងប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះ សម្រាប់ការរៀបចំតាក់តែង ផអ៥ទី២ (២០២៦-២០៣០) ព្រមទាំងសម្រាប់ជាមូលដ្ឋានក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត កជទី២។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយទីប្រឹក្សាឯករាជ្យក្រោមការ

គាំទ្រហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា។

- បានបញ្ចប់ការអង្កេតអភិបាលកិច្ច ដើម្បីបង្កើត និងកំណត់ទិន្នន័យលើសន្ទស្សន៍ជាយុទ្ធសាស្ត្រចំនួន២ គឺសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍ការផ្តល់សេវា ដោយផ្តោតទៅលើសន្ទស្សន៍រងចំនួន៥ រួមមាន (១). ការផ្តល់សេវា (២). ការឆ្លើយតប (៣). ការចូលរួមរបស់ប្រជាពលរដ្ឋ (៤). តម្លាភាព និង (៥). គណនេយ្យភាព ធ្វើជាទិន្នន័យដើមគ្រាសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃវាស់វែងការសម្រេចបាននូវគោលដៅ និងគោលបំណងនៃ កជទី២។ ការអង្កេតនេះ ត្រូវបានធ្វើឡើងដោយក្រុមហ៊ុន ASKL Service and Consulting Inc. គាំទ្រដោយគម្រោង STA ក្រោមហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា។

- បានបញ្ចប់ការអង្កេតវាយតម្លៃសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានផ្តោតទៅលើការវាយតម្លៃសន្ទស្សន៍រងចំនួន៣ (១). សមត្ថភាពក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត (២). សមត្ថភាពស្ថាប័ន (៣). សមត្ថភាពបុគ្គល ព្រមទាំងកំណត់នូវចំណុចខ្វះខាត បញ្ហាប្រឈមនានា និងផ្តល់អនុសាសន៍សម្រាប់ការកែលម្អការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអង្កេតនេះ ត្រូវបានធ្វើឡើងដោយក្រុមហ៊ុនឯករាជ្យ ASKL Service and Consulting Inc.។

- បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (NAD) ក្នុងក្របខ័ណ្ឌ គ.ជ.អ.ប. និងកំពុងដាក់ដំណើរការសាកល្បង។

## ១៩. មុខងារ និងរចនាសម្ព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិត្រូវបានបន្តពិនិត្យមើលឡើងវិញ

- ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រសួងមុខងារសាធារណៈ និងមានការចូលរួមពីលេខាធិការដ្ឋាន គ.ជ.អ.ប. សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នចំនួន១០ត្រូវបាននិងកំពុងពិនិត្យ និងពិភាក្សាស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ និងពង្រឹងស្ថាប័នសាធារណៈឱ្យមានភាពសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំតាមរយៈការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ននីមួយៗ។ ក្នុងការរៀបចំអនុក្រឹត្យទាំងនេះ ក៏បានគិតគូរ និងតម្រឹមជាមួយនឹងមុខងារ និងរចនាសម្ព័ន្ធនានានៃក្រសួង ស្ថាប័នដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាកុំឱ្យមានភាពត្រួតស៊ីគ្នានៃមុខងារ និងរចនាសម្ព័ន្ធ និងធានាដល់ការគាំទ្រ ការតាមដាន និងត្រួតពិនិត្យក្នុងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួង ស្ថាប័នទាំងនោះរួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន ក្រសួងរ៉ែនិងថាមពល ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ។

**១៦. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

- អគ្គលេខាធិការសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំកិច្ចប្រជុំជាទៀងទាត់ចំនួន ៤ដង ធ្វើឡើងដោយផ្ទាល់ និងតាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេង(zoom) ដើម្បី (១) ពិនិត្យ ពិភាក្សា និងតម្រង់ទិសដល់ថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត (២) ពិនិត្យ ពិភាក្សាអំពីបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (៣) ពិភាក្សាអំពីការរៀបចំចូលរួមក្នុងវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិរបស់សមាគម។

- សម្ព័ន្ធភាពជាតិ បានរៀបចំមហាសន្និបាត អាណត្តិទី៤ ដើម្បី (១). ពិនិត្យ និងអនុម័តរបាយការណ៍សមិទ្ធផលសំខាន់ៗក្នុងរយៈពេល៥ឆ្នាំកន្លងមក (២). បោះឆ្នោតជ្រើសរើសបំពេញរចនាសម្ព័ន្ធអង្គអភិបាលកិច្ចសមាគម រួមមាន បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានសមាគម បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសមាគម គណៈកម្មាធិការប្រតិបត្តិ និង(៣). អនុម័តលើសមាសភាពប្រតិភូសម្រាប់គណៈកម្មាធិការប្រតិបត្តិជាតិ និងក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

- ឆ្នាំ២០២៥នេះ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

| ប្រធានបទ | ចំនួនវគ្គ | សមាសភាពអ្នកចូលរួម |
|---|---|---|
| ១. សិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់លើឯកសារគតិយុត្តិមួយចំនួនស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈការគាំទ្រថវិកាពី AIMF នាថ្ងៃទី២១ ខែមករា អគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានសហការជាមួយមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយ (ADPC) រៀបចំសិក្ខាស្តីពីការបង្ហាញ ឧបករណ៍វាយតម្លៃរបស់ដៃគូត្រៀមបង្ការអាស៊ី (APP) ជាមួយការតម្រង់ទិសសម្រាប់អ្នកអនុវត្តន៍ ការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់អាជ្ញាធរមូលដ្ឋាន ឈានទៅរកការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។ | ១វគ្គ | ប្រធានក្រុមប្រឹក្សារាជធានី ខេត្តទាំង២៥ ថ្នាក់ដឹកនាំសមាគមជាតិ និងសម្ព័ន្ធភាពជាតិ និងក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់នៃខេត្តគោលដៅ សរុបចំនួន១១០នាក់ |
| ២. សិក្ខាសាលាស្តីពីការបូកសរុបលទ្ធផលនៃការអនុវត្តគម្រោង និងលើកទិសដៅបន្ត នៃការអនុវត្តគម្រោងត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយដែលគាំទ្រថវិកាពីមូលនិធិហ្គេត តាមរយៈ AIMF ដើម្បីលើកកម្ពស់នូវសមត្ថភាព និងការយល់ដឹងរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ព្រមទាំងគណៈអភិបាល និងមន្ត្រីពាក់ព័ន្ធនៃរាជធានី ខេត្តគោលដៅលើការងារពាក់ព័ន្ធនឹងការឆ្លើយតបគ្រោះមហន្តរាយ។ | ១វគ្គ | ក្រុមប្រឹក្សា គណៈអភិបាល ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងមន្ត្រីពាក់ព័ន្ធនៃរាជធានី ខេត្តសរុបចំនួន៥៥នាក់ ស្ត្រីចំនួន១៦នាក់ |
| ៣. វគ្គបណ្តុះបណ្តាលតម្រង់ទិសដល់សមាជិកក្រុមប្រឹក្សានៃសង្កាត់ ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅស្តីពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងការកសាងផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលសង្កាត់។ វគ្គបណ្តុះបណ្តាលមានគោលបំណង លើកកម្ពស់ចំណេះដឹង អាកប្បកិរិយា តំលៃ និងជំនាញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាក្នុងការផ្តល់សេវាសាធារណៈឆ្លើយតបតម្រូវការប្រជាពលរដ្ឋ ជាពិសេស ការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។ | ១វគ្គ | សរុបចំនួន៣៥នាក់ ស្ត្រី១៨នាក់ |
| ៤. វេទិកាពិគ្រោះយោបល់របស់ក្រុមប្រឹក្សាសង្កាត់ មានគោលបំណងលើកកម្ពស់ការយល់ដឹង ការផ្លាស់ប្តូរបទពិសោធន៍ ការកសាងបណ្តាញរឹងមាំ ការកំណត់បញ្ហាប្រឈមរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធលើការផ្តល់សេវាសាធារណៈ ហើយជាងនេះទៀត វេទិកានេះ បានធ្វើឱ្យអ្នកពាក់ព័ន្ធបានចូលរួមសិក្សាស្វែងយល់ជាមូលដ្ឋានពីប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ កំណត់បាននូវបញ្ហាប្រឈមជាក់លាក់របស់ក្រុមប្រឹក្សា ដើម្បីឆ្លើយតបទៅនឹងការផ្តល់សេវាដល់ប្រជាពលរដ្ឋដោយស្វែងរកដំណោះស្រាយព្រមទាំងកិច្ចអន្តរាគមន៍ទាន់ពេលវេលា ជួយដល់សមាជិកក្រុមប្រឹក្សា និង | ៣លើក | សមាជិកក្រុមប្រឹក្សាសង្កាត់ មេភូមិ តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធ នៅសង្កាត់ច្បារអំពៅទី១ សរុបចំនួន១៤៦នាក់ |

| | | |
|---|---|---|
| អ្នកពាក់ព័ន្ធ ឱ្យកាន់តែមានភាពជឿជាក់ ក្នុងការការពារ និងរួមចំណែកដល់ការងារអភិបាលកិច្ចកាន់តែមានប្រសិទ្ធភាព ជាពិសេសប្រមូលបានមេរៀន និងបទពិសោធន៍ក្នុងរៀបចំ និងពង្រីកលទ្ធភាពសម្រាប់ការរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ | | |
| ៥. វគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ និងបង្ការការបៀតបៀនផ្លូវភេទនៅកន្លែងការងារដល់ស្រុកទាំង៧ (ស្រុកទឹកផុស ឈូក ជុំគិរី ជីក្រែង ស៊ីធរកណ្តាល រវៀង និងត្បែងមានជ័យ) គោលបំណងនៃការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ និងបង្ការការបៀតបៀនផ្លូវភេទនៅកន្លែងការងារ គឺ ៖ (១) ផ្តល់និយមន័យច្បាស់លាស់ (២) ផ្តល់អំណាចដល់ជនរងគ្រោះ និងសាក្សីឱ្យរាយការណ៍ (៣) ធានាបាននូវការអនុលោមតាមច្បាប់ និងគោលនយោបាយកន្លែងធ្វើការ និង(៤) ពង្រឹងទំនាក់ទំនងប្រកបដោយវិជ្ជាជីវៈ និងបង្កើតកន្លែងធ្វើការដែលមនុស្សគ្រប់គ្នាមានអារម្មណ៍ថាមានតម្លៃ និងការគោរព។ | ១វគ្គ | សរុបចំនួន ៦០នាក់ (ស្ត្រី២៧នាក់) |

- ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិជាស្ត្រី និងក្រុមប្រឹក្សាឃុំជាស្ត្រីជ័យលាភីពានរង្វាន់ស្នាដៃឆ្នើម បានធ្វើទស្សនកិច្ចសិក្សានៅទីក្រុងអូតាវ៉ានៃប្រទេសកាណាដា ដើម្បីបង្កើនសមត្ថភាពអ្នកដឹកនាំជាស្ត្រីរបស់សម្ព័ន្ធភាពជាតិ តាមរយៈការរៀនសូត្រពីបទពិសោធន៍ជាមួយសមាជិកក្រុមប្រឹក្សាជាប់ឆ្នោតនៃប្រទេសកាណាដា រៀនសូត្រជាមួយបុគ្គលិក FCM ពីការអនុវត្តល្អរបស់ FCM និងចែករំលែកចំណេះដឹងជាមួយសមាគមអាជ្ញាធរមូលដ្ឋានមកពីប្រទេសហ្គាណា បេនីន សំបៀរ និងស្រីលង្កា និងការកសាងជំនាញផ្សេងៗទាក់ទងនឹងការជួយជំរុញភាពស្មើគ្នាក្នុងភាពជាអ្នកដឹកនាំ។

- អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៤-២០២៨) របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងការរួមចំណែកក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ សម្ព័ន្ធភាពជាតិ កំពុងរៀបចំ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ លើកទី៤ (២០២៥-២០២៩) សម្រាប់តម្រង់ទិសការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តតួនាទី ភារកិច្ច និងមុខងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ផែនការយុទ្ធសាស្ត្រ បានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពនានាដែលសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ត្រូវអនុវត្តប្រកបដោយភាពជាម្ចាស់ ដើម្បីធានាបាននូវនិរន្តរភាពការងារ និងការរួមចំណែកអនុវត្តគោលនយោបាយ និងវិធានការជាគន្លឹះនានារបស់រាជរដ្ឋាភិបាល។

- សម្ព័ន្ធភាពជាតិ បានតម្រង់ទិស និងពង្រឹងដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានតាមរាជធានីខេត្តទាំង២៥ លើការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការស្តង់ដារ(MoM) ក្នុងការគ្រប់គ្រងចាត់ចែងថវិការបស់ខ្លួនប្រកប ដោយតម្លាភាព និងការទទួលខុសត្រូវ ស្របតាមសៀវភៅគោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការ (POMM) ដែលត្រូវបានអនុម័តជាផ្លូវការដោយថ្នាក់ដឹកនាំសមាគមទាំងពីរ (NACPC-NLC) នៅខែឧសភា ឆ្នាំ២០១៥ និងបានធ្វើបច្ចុប្បន្នភាពឆ្នាំ២០២០ ព្រមជាមួយការអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិ និងក្រុមប្រឹក្សាសមាគមតាមរាជធានី ខេត្ត។

### ១៧. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

- អង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រួមមាន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និង អង្គការសម្ព័ន្ធភាពដៃគូសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) បានចូលរួម និងផ្តល់យោបល់ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (ក.ប.អ.ប.) លើកទី២១ នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ លក្ខខណ្ឌការងារបច្ចេកទេស និងសូចនាករត្រួតពិនិត្យរួមឆ្នាំ២០២៥-២០២៦ ក្រោមអធិបតីភាព **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. និងជាប្រធានក្រុមការងារបច្ចេកទេស ក.ប.អ.ប.** និងតំណាងដៃគូអភិវឌ្ឍន៍ជាសហប្រធាននៃ ក.ប.អ.ប. ដែលរួមមានតំណាងស្ថានទូតអាល្លឺម៉ង់ និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការនិងសម្របសម្រួលជាមួយនឹងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តសកម្មភាពរួមគ្នាដែលរួមមាន ៖ (១). ការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២). ការគាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំដីកាបង្គារ និងទប់ស្កាត់ផលប៉ះពាល់នៃគ្រឿងស្រវឹងនៅក្នុងសហគមន៍ (៣). ការគាំទ្រដល់រដ្ឋបាលរាជធានី ខេត្តក្នុងការពង្រឹងការប្រើប្រាស់ទិន្នន័យ ដើម្បីគាំទ្របរិយាកាសធុរកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (៤). ការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងថវិកាថ្នាក់ក្រោមជាតិ។

## ខ. សមាសភាគទី២ ÷ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី២នេះ រួមមានសកម្មភាពជាអាទិភាពចំនួន **២០** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន **១៧** ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក

- លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចប់ការពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍ស្តីពីទិន្នន័យដើមគ្រាសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវាវិស័យអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធនឹងគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- ក្រសួង ស្ថាប័នផ្ទេរមុខងារមួយចំនួនបានផ្តល់ការគាំទ្រ ការអភិវឌ្ឍសមត្ថភាព និងការចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមស្មារតីនៃអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ២១៣អ.ន.ក្រ.បក ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

- **ក្រសួងអប់រំ យុវជន និងកីឡា៖** (១). បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាដល់រដ្ឋបាលក្រុង ស្រុក និងមន្ត្រីពាក់ព័ន្ធនៅខេត្តសៀមរាបពីថ្ងៃទី១៩-២១ ខែមីនា ឆ្នាំ២០២៥ មានអ្នកចូលរួមចំនួន ៦២នាក់ និងនៅខេត្តបន្ទាយមានជ័យពីថ្ងៃទី២៥-២៧ ខែមីនា ឆ្នាំ២០២៥ មានអ្នកចូលរួមចំនួន៤៦នាក់ (២). បានចុះគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារគ្រប់គ្រងដឹកនាំ ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តចំនួន៩ និង(៣). បានចុះពិនិត្យ និងវាយតម្លៃរដ្ឋបាលក្រុង ស្រុកអំពីការអនុវត្តមុខងារអប់រំ យុវជន និងកីឡាក្នុងក្របខណ្ឌគម្រោង ដែលគាំទ្រដោយអង្គការទស្សនពិភពលោកអន្តរជាតិក្នុងក្រុង ស្រុកគោលដៅចំនួន១២នៃខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។
- **ក្រសួងបរិស្ថាន៖** (១). បានរៀបចំកិច្ចប្រជុំស្តីពីការពិនិត្យ វាយតម្លៃ និងតាមដានវឌ្ឍនភាពនៃការអនុវត្តមុខងារលើវិស័យបរិស្ថានដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក នៅខេត្តគោលដៅចំនួន១១ ដើម្បីកំណត់ និងចាត់វិធានការដោះស្រាយបញ្ហាប្រឈមនានា ព្រមទាំងជំរុញការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព (២). បានរៀបចំការអភិវឌ្ឍសមត្ថភាពដល់ក្រុមការងារគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យបរិស្ថានក្នុងការបំពេញតួនាទី និងភារកិច្ចស្របតាមសេចក្តីសម្រេចរបស់ក្រសួងបរិស្ថាន។
- **ក្រសួងកិច្ចការនារី**បានរៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រងអនុវត្តមុខងារវិស័យកិច្ចការនារីដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- **ក្រសួងមហាផ្ទៃ**កំពុងសហការជាមួយក្រសួងពាណិជ្ជកម្មក្នុងការរៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីការអនុវត្តមុខងារអភិវឌ្ឍន៍មូលដ្ឋានក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- **ក្រសួងសាធារណការ និងដឹកជញ្ជូន** បានចុះពិនិត្យ វាយតម្លៃអំពីការអនុវត្តមុខងារដែលបានផ្ទេរ និងធ្វើប្រតិភូកម្មការផ្តល់សេវាដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹកលើវិស័យសាធារណការនិងដឹកជញ្ជូននៅអង្គភាពច្រក និងការិយាល័យច្រកចេញចូលតែមួយក្រុង-ស្រុកទាំងអស់នៃរដ្ឋបាលខេត្តត្បូងឃ្មុំ។
- **ក្រសួងទេសចរណ៍**បានរៀបចំសិក្ខាសាលាស្តីពីការបណ្តុះបណ្តាលមុខងារដែលបានផ្តល់សេវារដ្ឋបាលក្នុងវិស័យទេសចរណ៍នៅរដ្ឋបាលក្រុង ស្រុកនាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅខេត្តមណ្ឌលគិរី និងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥ នៅខេត្តបាត់ដំបង។ សិក្ខាសាលានេះមានគោលបំណងដើម្បីជំរុញការគាំទ្រដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក ជាពិសេសក្នុងការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យទេសចរណ៍ជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព គុណភាព គណនេយ្យភាព និងតម្លាភាព។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**បានចុះពិនិត្យតាមដាន និងគាំទ្រលើការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋនៅខេត្តបាត់ដំបង (២៧ ឧសភា ២០២៥) ខេត្តកំពង់ឆ្នាំង (២៨ ឧសភា ២០២៥) ខេត្តកែប (០៩ តុលា ២០២៥) ខេត្តកំពត (១០ តុលា ២០២៥) ខេត្តកំពង់ស្ពឺ (០១ កញ្ញា ២០២៥) និងខេត្តព្រះសីហនុ (០២ កញ្ញា ២០២៥) ដើម្បីត្រួតពិនិត្យ តាមដាន វាយតម្លៃ និងផ្តល់ការគាំទ្រដល់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលសង្កាត់ និងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋក្នុងការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ និងមុខងារនានាដែលបានប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- **ក្រសួងអភិវឌ្ឍន៍ជនបទ**បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រើប្រាស់ថវិកាឧបត្ថម្ភធនជំពូក៦៥ ដែលបានវិភាជន៍ដោយក្រសួងអភិវឌ្ឍន៍ជនបទនាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ ក្នុងគោលបំណង (១). ពិនិត្យមើលអំពីលទ្ធផលនៃការអនុវត្តការងារ នឹងការបំពេញបន្ថែមនូវចំណុចខ្វះខាត (២). ដោះស្រាយរាល់ការលំបាកដែលរដ្ឋបាលក្រុង ស្រុកធ្លាប់បានជួបប្រទះក្នុងពេលអនុវត្ត និង(៣). បង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារកំណែទម្រង់ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិរបស់ក្រសួងអភិវឌ្ឍន៍ជនបទឱ្យកាន់តែប្រសើរឡើង។
- **ក្រសួងសុខាភិបាល**បានដឹកនាំសម្របសម្រួលក្រុមការងារអន្តរក្រសួងចុះប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តមុខងារវិស័យសុខាភិបាល និងការសិក្សាលទ្ធភាពក្នុងការផ្ទេរមុខងារសុខាភិបាលពីរដ្ឋបាល រាជធានី ខេត្តទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ ការចុះសិក្សានេះ រៀបចំឡើងក្នុងគោលបំណង (១).វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលដែលបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត (២). សិក្សាលទ្ធភាពនូវមុខងារមួយចំនួនសម្រាប់ធ្វើប្រតិភូកម្មទៅរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ និងដើម្បីរៀបចំជាទិន្នន័យដើមគ្រាសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយនាពេលអនាគត។
- **ក្រសួងរ៉ែ និងថាមពល**បានរៀបចំកិច្ចប្រជុំពិភាក្សាលើការស្នើសុំចំណូលស្វយសារពីធនធានរ៉ែចំពោះអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី និងរណ្តៅដីចល័តដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាប័ណ្ណនាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ នៅសាលប្រជុំទីស្តីការក្រសួងរ៉ែ និងថាមពល។ កិច្ចប្រជុំនេះ មានគោលបំណងដើម្បីពិនិត្យ ពិភាក្សាលើសំណើរបស់រដ្ឋបាលក្រុង ស្រុក ដែលបានលើកឡើងនៅក្នុងវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការស្នើសុំឱ្យរដ្ឋបាលក្រុង ស្រុក ទទួលបានចំណូលស្វយសារពីធនធានរ៉ែ ចំពោះអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី និងរណ្តៅដីចល័តដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាបណ្ណ។

– បានផ្តល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព ការគាំទ្របច្ចេកទេស ធនធានហិរញ្ញវត្ថុ និងផ្តល់សម្ភារៈផ្សព្វផ្សាយ (I4C) ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៥៤ ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម

ដើម្បីលើកកម្ពស់សិទ្ធិអំណាច និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

## ២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់

- បាន និងកំពុងរៀបចំសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដោយបានចុះប្រមូលធាតុចូលលើការកែសម្រួលសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់នៅរដ្ឋបាលក្រុងកំពង់ចាមនិងស្រុកព្រៃឈរនៃខេត្តកំពង់ចាម រដ្ឋបាលក្រុងស្ទឹងសែននៃខេត្តកំពង់ធំ និងរដ្ឋបាលក្រុងកំពង់ឆ្នាំងនិងស្រុកកំពង់ត្រឡាចនៃខេត្តកំពង់ឆ្នាំង។
- បាន និងកំពុងពិនិត្យកែសម្រួលសេចក្តីព្រាងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់(PIM) ឱ្យស្របទៅតាមស្ថានភាពនៃការវិវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- បាន និងកំពុងសិក្សាកែសម្រួលតួនាទី ភារកិច្ចរបស់មន្ត្រីភូមិ ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន. ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ។
- បានផ្តល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព ការគាំទ្របច្ចេកទេស ធនធានហិរញ្ញវត្ថុ និងផ្តល់សម្ភារៈផ្សព្វផ្សាយ (I4C) ដល់រដ្ឋបាលឃុំ សង្កាត់ចំនួន ១.៥៥០ ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់សិទ្ធិអំណាច និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការផ្តល់សេវាសាធារណៈលើវិស័យអប់រំ វិស័យសុខាភិបាល និងរដ្ឋបាលឃុំ សង្កាត់។
- បានចុះសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការហាមឃាត់មិនឱ្យអ្នកសារព័ត៌មានចូលរួមក្នុងកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ ឆ្នាំ២០២៥ នៅខេត្តត្បូងឃ្មុំ។
- បានចុះគាំទ្រ តាមដាន និងត្រួតពិនិត្យការរៀបចំនិងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់នៅរដ្ឋបាលខេត្តព្រៃវែងនិងខេត្តកំពត និងការរៀបចំកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ ឆ្នាំ២០២៥ នៅរដ្ឋបាលខេត្តកំពង់ចាម ខេត្តកណ្តាល និងរដ្ឋបាលរាជធានីភ្នំពេញ។
- បានចុះប្រជុំប្រមូលធាតុចូលលើការកែសម្រួលសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់នៅរដ្ឋបាលក្រុងកំពង់ចាមនិងស្រុកព្រៃឈរនៃខេត្តកំពង់ចាម រដ្ឋបាលក្រុងស្ទឹងសែននៃខេត្តកំពង់ធំ និងរដ្ឋបាលក្រុងកំពង់ឆ្នាំងនិងស្រុកកំពង់ត្រឡាចនៃខេត្តកំពង់ឆ្នាំង។
- បានរៀបចំសិក្ខាសាលាស្តីពីការរៀបចំគម្រោងសេវាសង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៥ នៅខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តរតនគិរី។
- បានចុះជួបសម្ភាសន៍ និងប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការសិក្សាវាយតម្លៃលើប្រសិទ្ធភាពនៃដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន**

– បាននិងកំពុងរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យនៃការរៀបចំក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន ដើម្បីជាមូលដ្ឋានសម្រាប់ការបង្កើតឬការប្រែក្លាយស្រុកទៅជាក្រុង និងឃុំទីប្រជុំជនទៅជាសង្កាត់។

**៤. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលរាជធានី ខេត្ត**

– **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.អ.ប.** បានដឹកនាំក្រុមការងារអន្តរក្រសួង ដែលរួមមានតំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ លេខាធិការដ្ឋាន គ.ជ.អ.ប. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តបាត់ដំបង បំពេញទស្សនកិច្ចសិក្សារយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ នៅប្រទេសថៃ និងទស្សនកិច្ចសិក្សារយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ នៅប្រទេសឥណ្ឌូនេស៊ី។ គោលបំណងនៃទស្សនកិច្ចសិក្សានេះ គឺដើម្បីស្វែងយល់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋានមួយចំនួន។ បច្ចុប្បន្នក្រុមការងារកំពុងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃទស្សនកិច្ចសិក្សានេះ។

– **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.អ.ប.** បានដឹកនាំក្រុមការងារអន្តរក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើទស្សនកិច្ចសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសិក្សាស្វែងយល់អំពីការរៀបចំកម្មវិធីសិក្សាសាលាបណ្តុះបណ្តាល និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលមូលដ្ឋាននៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២២ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥។

– លេខាធិការដ្ឋាន គ.ជ.អ.ប. និងដោយមានការគាំទ្រពីកម្មវិធីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅកម្ពុជា (ISD/GIZ) ក៏បាននិងកំពុងសិក្សា និងប្រមូលចងក្រងឯកសារ និងបទដ្ឋានគតិយុត្តនៃបណ្តាប្រទេសមួយចំនួនរួមមាន ប្រទេសវៀតណាម ឥណ្ឌូនេស៊ី ថៃ ហ្វីលីពីន កូរ៉េខាងត្បូង អំពីការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៃរដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន រដ្ឋបាលតំបន់/រដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន។

– ក្រុមការងារអន្តរក្រសួងដឹកនាំដោយ **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.អ.ប.** បានចុះសិក្សាស្វែងយល់អំពីការអនុវត្តមុខងារ និងរចនាសម្ព័ន្ធនៅរដ្ឋបាលខេត្តចំនួន២ (ខេត្តមណ្ឌលគិរី និងខេត្តស្វាយរៀង) ក្រុងចំនួន២ (ក្រុងសែនមនោរម្យ និងក្រុងបាវិត) និងស្រុកចំនួន២ (ស្រុកកោះញែក និងស្រុកស្វាយជ្រុំ)។

## ៥. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ

- រដ្ឋបាលក្រុង ស្រុកមួយចំនួន នៃខេត្តចំនួន៥ រួមមាន ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តស្ទឹងត្រែង និងខេត្តពោធិ៍សាត់ បានរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋ ដើម្បីដោះស្រាយបញ្ហា សំណើសំណូមពររបស់ប្រជាពលរដ្ឋចំនួន៧០លើក ដែលមានអ្នកចូលរួមសរុប **៥.៦៩៧នាក់** ស្ត្រីចំនួន**៣.៧៥៨នាក់**។

- រដ្ឋបាលក្រុង ស្រុកមួយចំនួន នៃខេត្តចំនួន៨ រួមមាន ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តស្ទឹងត្រែង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ ខេត្តបន្ទាយមានជ័យ និងខេត្តកែប បានចុះជួបពិភាក្សា និងប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយព័ត៌មាននានាអំពីការបំពេញការងារ និងការផ្តល់សេវា ព្រមទាំងទទួលសំណូមពរ និងដោះស្រាយបញ្ហានានា បានចំនួន **១៦៩លើក** មានអ្នកចូលរួមសរុបចំនួន **៤៤២នាក់** ស្ត្រីចំនួន **២៥៥នាក់**។

## ៦. ការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- សាលាជាតិរដ្ឋបាលមូលដ្ឋានបាន និងកំពុងដាក់ឱ្យអនុវត្តសាកល្បងការរៀនសូត្រតាមប្រព័ន្ធអនឡាញ (E-Learning) សម្រាប់ក្រុមគោលដៅជាក្រុមប្រឹក្សាក្រុង ស្រុក និងរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ប្រតិបត្តិការការងាររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA-MIS)។

- សាលាជាតិរដ្ឋបាលមូលដ្ឋានគ្រោងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន ៤វគ្គ ដែលមានសិក្ខាកាមសរុបចំនួន៣២០នាក់។ ទន្ទឹមនឹងនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏បានរៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ និងស្លាយមេរៀនរួចរាល់ដែលគ្រោងនឹងបណ្តុះបណ្តាលនាពេលឆាប់ៗខាងមុខនេះ។

- សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានសហការជាមួយអង្គការសមត្ថភាពខ្ញុំ រៀបចំផ្តល់វគ្គបណ្តុះបណ្តាលតម្រង់ទិសដល់សមាជិកក្រុមប្រឹក្សានៃសង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ សរុបចំនួន៣៥នាក់ ស្ត្រីចំនួន១៤នាក់ អំពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងការកសាងផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលសង្កាត់។ វគ្គបណ្តុះបណ្តាលមានគោលបំណងលើកកម្ពស់ចំណេះដឹង អាកប្បកិរិយា តម្លៃ និងជំនាញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សា ក្នុងការផ្តល់សេវាសាធារណៈឆ្លើយតបតម្រូវការប្រជាពលរដ្ឋ ជាពិសេស ការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

## ៧. ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ

- លេខាធិការដ្ឋាន គ.ជ.អ.ប. បាន និងកំពុងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA/MIS) ដែលគាំទ្រដោយគម្រោង STA ក្រោមការគាំទ្រហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា។ ប្រព័ន្ធគ្រប់គ្រង

ព័ត៌មាននេះ មានគោលបំណងដើម្បីផ្តល់ព័ត៌មាននានា និងទទួលមតិយោបល់ត្រលប់អំពីការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ហើយកំពុងដាក់ឱ្យអនុវត្តសាកល្បងនៅរដ្ឋបាលក្រុងគោលដៅចំនួន៣គឺ ក្រុងបានលុងនៃខេត្តរតនគិរី ក្រុងសៀមរាបនៃខេត្តសៀមរាប និងក្រុងកំពង់ចាមនៃខេត្តកំពង់ចាម។

- ការអនុវត្តការងារគណនេយ្យភាពសង្គមសម្រាប់យន្តការផ្តល់ព័ត៌មាននានាជូនប្រជាពលរដ្ឋត្រូវបានអនុវត្ត និងសម្រេចបានលទ្ធផលសំខាន់ៗរួមមាន ៖ (១). ការរៀបចំ និងកែសម្រួលផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) នៅរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានភាពទាក់ទាញ និងល្អប្រសើរជាងមុន (២). ការរៀបចំផលិតវីដេអូគំនូរជីវចលស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម និងព័ត៌មានអំពីសិទ្ធិស្តង់ដាបំពេញការងាររបស់រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា មណ្ឌលសុខភាព និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ (៣). ការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រនិរន្តរភាពគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ (៤). ការអនុវត្តសាកល្បងនិរន្តភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់រដ្ឋបាលសង្កាត់ (រដ្ឋបាលសង្កាត់ចំនួន៥ សាលាបឋមសិក្សាចំនួន១៣ និងមណ្ឌលសុខភាពចំនួន៣) នៃក្រុងច្បារមន ខេត្តកំពង់ស្ពឺ និង (៥). ការរៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលត្រូវដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២៦ខាងមុខនេះ។

### ៤. ការពង្រឹងយន្តការសម្រាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា និងសំណើសំណូមពររបស់ប្រជាពលរដ្ឋ

- ក្រសួងមហាផ្ទៃបានផ្តល់ការគាំទ្រ និងពង្រឹងកិច្ចដំណើរការនៃការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ តាមរយៈ ៖ (១). ការដាក់ចេញប្រកាសទទួលស្គាល់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តចំនួន៣គោលដៅ រួមមាន ៖ ខេត្តតាកែវ ខេត្តមណ្ឌលគិរី និងខេត្តបន្ទាយមានជ័យ និងប្រកាសស្តីពីការទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌចំនួន ១៩គោលដៅ រួមមាន៖ ក្រុងខេមរភូមិន្ទ ក្រុងសិរីសោភ័ណ ស្រុកប្រាសាទសំបូរ ស្រុកក្រគរ ស្រុកសាលាក្រៅ ស្រុកបរិបូណ៌ ស្រុកពួក ស្រុកសំរោង ស្រុកបាធាយ ស្រុកត្បូងឃ្មុំ ស្រុកមុខកំពូល ស្រុកកោះធំ ស្រុកប្រាសាទបាគង ស្រុកកំពង់សីលា ស្រុកមេមត់ ស្រុកគិរីវង់ ស្រុកសំពៅលូន ស្រុកមណ្ឌលសីមា និងខណ្ឌបឹងកេងកង (២). ការកែសម្រួល និងធ្វើសន្ទានកម្មរវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹង និងព័ត៌មានផ្សេងៗរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តជាមួយកម្មវិធីទូរសព្ទដៃ (មតិយើង) និង(៣). ការរៀបចំកិច្ចប្រជុំតាមរយៈកម្មវិធី ZOOM ចំនួន ២លើក ស្តីពីការពិនិត្យមើលវឌ្ឍនភាពការងារ និងបញ្ហាប្រឈមនៃការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក បានចំនួន២៦គោលដៅ។

- ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត បានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន **២.០២៨ករណី** ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន**៣៨៤ករណី** (បញ្ចប់ការដោះស្រាយចំនួន **៣០៥ករណី** និងកំពុងដោះស្រាយចំនួន **៧៩ករណី**) បណ្តឹងក្រៅសមត្ថកិច្ចចំនួន **១៥៥**

**ករណី** និងព័ត៌មានផ្សេងៗចំនួន **១.៤៨៩ករណី** (ការសរសើរចំនួន **១៦១ករណី** សំណើនិងសំណូមពរចំនួន **៣៩២ករណី** និងការសាកសួរព័ត៌មានចំនួន **៩៣៦ករណី**)។







- ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន **៤៥.០៣៨ករណី**។ ចំពោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន **៣២០ករណី** (បញ្ចប់ការដោះស្រាយចំនួន **២៧២ករណី** និងកំពុងដោះស្រាយចំនួន **៤៨ករណី** បណ្តឹងក្រៅសមត្ថកិច្ចចំនួន **១៧៨ករណី** ព័ត៌មានផ្សេងៗសរុបចំនួន **៤៤.៥៤០ករណី**)។






## ៩. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ

- គ.ជ.អ.ប. បានផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលមួយចំនួនក្នុងការចូលរួមលើកកម្ពស់ដល់ការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការងារគណនេយ្យភាពសង្គមដែលបច្ចុប្បន្នរួមមានអង្គការសង្គមស៊ីវិលចំនួន៩ បានបំពេញតួនាទីជាផ្នែកតម្រូវការក្នុងការផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋអំពីសិទ្ធិ ស្តង់ដាបំពេញការងារ និងព័ត៌មានថវិកា ព្រមទាំងសម្របសម្រួលក្នុងការដាក់ពិន្ទុវាយតម្លៃលើការបំពេញការងារ និងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់ (សេវារដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) និងការអនុវត្តសាកល្បងការងារគណនេយ្យភាពសង្គមលើការផ្តល់សេវានៅថ្នាក់រដ្ឋបាល ក្រុង ស្រុក ខណ្ឌមួយចំនួនផងដែរ។

- រដ្ឋបាលខេត្តចំនួន០៧ រួមមានខេត្តកំពង់ចាម ក្រចេះ ប៉ៃលិន ពោធិ៍សាត់ ស្ទឹងត្រែង កោះកុង និងកែបបានរៀបចំកិច្ចប្រជុំរវាងរដ្ឋបាលខេត្ត និងអង្គការសង្គមស៊ីវិលស្តីពីការប្រមូលតម្រូវការអាទិភាពសម្រាប់ដំណើរការកសាង កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០២៦-២០២៨ ដើម្បីលើកកម្ពស់ការចូលរួម និងការផ្តល់យោបល់ក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានចំនួន១១ដង មានអ្នកចូលរួមសរុបចំនួន **៥៤៣នាក់** ស្ត្រី **១៣៣នាក់**។

- រដ្ឋបាលក្រុង ស្រុកមួយចំនួននៃខេត្តចំនួន០៦ រួមមានខេត្តកំពង់ចាម ក្រចេះ ប៉ៃលិន ពោធិ៍សាត់ ស្ទឹងត្រែង និងខេត្តកោះកុង បានរៀបចំកិច្ចប្រជុំរវាងរដ្ឋបាលក្រុង ស្រុក និងអង្គការសង្គមស៊ីវិល ស្តីពីការប្រមូលតម្រូវការអាទិភាពសម្រាប់ដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (២០២៦-២០២៨) ដើម្បីលើកកម្ពស់ការចូលរួម និងការផ្តល់យោបល់ ក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ចំនួន **៥៧ដង** មានអ្នកចូលរួមសរុបចំនួន **១៥២នាក់** ស្ត្រី **៥១នាក់**។

## ១០. ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំនៃក្រសួងមហាផ្ទៃក្នុងការប្រមូលទិន្នន័យអំពីបច្ចុប្បន្នភាពការប្រើប្រាស់ និងតភ្ជាប់បណ្តាញអ៊ីនធឺណិតនៅរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស។ ជាលទ្ធផលគិតត្រឹមខែមិថុនា ឆ្នាំ២០២៥ រដ្ឋបាលរាជធានីខេត្តទាំងអស់ទូទាំងប្រទេស បានតភ្ជាប់បណ្តាញអ៊ីនធឺណិត **១០០%**។ ដោយឡែក នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់សរុបចំនួន**២១០** បានតភ្ជាប់បណ្តាញអ៊ីនធឺណិតរួចរាល់ចំនួន**១៧៨** ក្រុង ស្រុក ខណ្ឌ ស្មើនឹង**៨៥%** មិនទាន់បានតភ្ជាប់មានចំនួន**១៦** ក្រុង ស្រុក ស្មើនឹង**៧,៥%** និងមិនមានទិន្នន័យច្បាស់លាស់ចំនួន១៦ ក្រុង ស្រុក ស្មើនឹង៧,៥%។ ដោយឡែកនៅរដ្ឋបាលឃុំ សង្កាត់ទាំងអស់សរុបចំនួន**១.៦៥២** បានតភ្ជាប់បណ្តាញអ៊ីនធឺណិតរួចរាល់ចំនួន**១.១១៣** ស្មើនឹង**៦៧%** មិនទាន់បានតភ្ជាប់ មានចំនួន**៣៤៨** ស្មើនឹង**២១%** និង ឃុំ សង្កាត់មិនមានទិន្នន័យច្បាស់លាស់ចំនួន១៩១ ស្មើនឹង**១២%** ។

### ១១. ការរៀបចំនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានកែសម្រួល ធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍន៍មុខងារបន្ថែមលើប្រព័ន្ធទិន្នន័យនានារបស់ គ.ជ.អ.ប. រួមមាន៖ ប្រព័ន្ធត្រួតពិនិត្យ តាមដាន ការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម (SA M&E Database System) ប្រព័ន្ធគ្រប់គ្រងការប្រកាសដេញថ្លៃគម្រោងឃុំ សង្កាត់ (Bidding Announcement) ប្រព័ន្ធទិន្នន័យភូមិសាស្ត្ររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ (Gazetteer Database) ប្រព័ន្ធទិន្នន័យការអនុវត្តគម្រោងថ្នាក់ក្រោមជាតិ (Project Implementation Database) ប្រព័ន្ធទិន្នន័យវាយតម្លៃមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ (CNP) និងប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ (Sub-National Project Database)។
- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងដំណើរការរៀបចំប្រព័ន្ធគ្រប់គ្រងការសិក្សាពីចម្ងាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (E-Learning) ក្នុងក្របខ័ណ្ឌនៃការអនុវត្តការងារគណនេយ្យភាពសង្គម។
- សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ប្រតិបត្តិការការងាររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA-MIS) ក្នុងនោះរួមមាន មុខងារគ្រប់គ្រងនិស្សិត និងការចុះឈ្មោះចូលរៀន មុខងារគ្រប់គ្រងគ្រូ និងបុគ្គលិករបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន មុខងារគ្រប់គ្រងវគ្គបណ្តុះបណ្តាល មុខងារការបង្រៀនតាមប្រព័ន្ធបច្ចេកវិទ្យា (E-Learning) និងមុខងារគ្រប់គ្រងហិរញ្ញវត្ថុ និងការបង់ប្រាក់។

### ១២. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងធ្វើបច្ចុប្បន្នភាពលើ (១). មុខងារកម្មវិធីលើទូរសព្ទគណនេយ្យភាពសង្គមលើប្រព័ន្ធប្រតិបត្តិការ iOS និង Android ដើម្បីឱ្យសាធារណជនកាន់តែងាយស្រួលប្រើប្រាស់ និងទទួលបានព័ត៌មានត្រលប់ពីប្រជាពលរដ្ឋទៅលើការផ្តល់សេវារបស់អង្គភាពផ្តល់សេវានីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង(២). គេហទំព័រថ្មីរបស់ គ.ជ.អ.ប. ដោយបន្ថែមមុខងារសំខាន់មួយចំនួន ដូចជាផ្ទាំងព័ត៌មាន (Dashboard) ដើម្បីផ្សព្វផ្សាយទិន្នន័យដែលត្រូវធ្វើសន្ទានកម្មពីប្រព័ន្ធគ្រប់គ្រងព័ត៌មាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយរដ្ឋបាលក្រុងសៀមរាប ក្រុងកំពង់ចាម និងក្រុងបានលុងក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវគេហទំព័រចែករំលែកព័ត៌មានជាសាធារណៈរួមមាន៖ krongsiemreap.gov.kh, krongkampongcham. gov.kh, krongbanlung.gov.kh ។
- រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដើម្បីលើកកម្ពស់និងផ្តល់ភាពងាយស្រួលក្នុងការទំនាក់ទំនងការងារ ការផ្សព្វផ្សាយព័ត៌មាន ការផ្តល់យោបល់ត្រឡប់ការផ្តល់សេវារដ្ឋបាល និងការអនុវត្តភារកិច្ចរបស់ខ្លួនតាមរយៈប្រព័ន្ធ និងបណ្តាញទំនាក់ទំនងសង្គម ដូចជា ព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាព ការិយាល័យ និងយន្តការច្រកចេញចូលតែមួយ ការងារគណនេយ្យភាពសង្គម កិច្ចលទ្ធកម្មសាធារណៈ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ល។

**១៧.ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រុមការងារអន្តរក្រសួងបានចុះសិក្សាអំពីលទ្ធភាព និងជម្រើសនានាក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្តនៅរាជធានី ខេត្តចំនួន៥ រួមមាន៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុកាលពីថ្ងៃទី១៦-២៥ ខែមិថុនា ឆ្នាំ២០២៥។ បច្ចុប្បន្ន លេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សានេះ។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៅរដ្ឋបាលក្រុង ស្រុក។

## គ. សមាសភាគទី៣ ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៣នេះ រួមមានសកម្មភាពជាអាទិភាពចំនួន **២៤** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន **២២** ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការស៊ីវិល (អង្គរដ្ឋបាល និងអង្គបច្ចេកទេស)**

- ក្រសួងមុខងារសាធារណៈ បាននិងកំពុងរៀបចំកែសម្រួលសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃអង្គសុខាភិបាល និងអង្គគ្រូបង្រៀនឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានភាពល្អប្រសើរដែលឆ្លើយតបទៅនឹងតម្រូវការ និងការវិវត្តនៃកំណែទម្រង់ក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។ សេចក្តីព្រាងអង្គទាំង២នេះ ត្រូវបានត្រៀមដាក់ឆ្លងកិច្ចប្រជុំលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈនាដើមឆ្នាំ២០២៦។

**២. ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៥ ស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនិយាមនីតិវិធីប្រតិបត្តិនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

- ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃបានរៀបចំដាក់ចេញប្រកាសអន្តរក្រសួងលេខ៣៣០៦/២៥ មស.នននក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនិយាមនីតិវិធីប្រតិបត្តិនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

- រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីគោលការណ៍ នីតិវិធីនៃការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងប្រធាន-អនុប្រធានអង្គភាព

សុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព)។

**៣. ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- គ.ជ.អ.ប. បានដាក់ចេញសៀវភៅណែនាំស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការរៀបចំការពិពណ៌នាមុខតំណែងក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមស្មារតីនៃអនុក្រឹតលេខ៧៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការគាំទ្រពី ISD/GIZ បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ (ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) បានចុះសិក្សាការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលរាជធានី ខេត្ត។

**៤. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំឱ្យមានលក្ខខណ្ឌការងារសម្រាប់មន្ត្រី បុគ្គលិកប្រចាំឆ្នាំនៅតាមអង្គភាពសាមីនីមួយៗរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក្តី លក្ខខណ្ឌការងារនេះ នឹងត្រូវពិនិត្យ និងកែសម្រួលឡើងវិញឱ្យកាន់តែច្បាស់លាស់នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានការកំណត់មុខតំណែងជាក់លាក់។

**៥. ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋបាលថ្នាក់ក្រោមជាតិ បានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនតាមរយៈការចុះបញ្ជីវត្តមានប្រចាំថ្ងៃនៅតាមអង្គភាពនីមួយៗ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមគ្រប់គ្រងបុគ្គលិកនានារបស់ខ្លួន ដែលបានផ្ទេរទៅឱ្យតាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌបានល្អប្រសើរជាងមុន។

**៦. ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រសួងមហាផ្ទៃសហការជាមួយក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាន និងកំពុងរៀបចំសេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ**

- ក្រសួងមហាផ្ទៃ បាននិងកំពុងរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការចូលនិវត្តន៍ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ (OMS-MOI) និងប្រព័ន្ធស្នើសុំគោលការណ៍អនុញ្ញាតច្បាប់ឈប់សម្រាកជូនគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (OMS-MOI)។

**៩. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់ខ្លួន។ ទិន្នន័យឆ្នាំ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកចំនួន **១០៣.៥៤៤នាក់** ក្នុងនោះ ៖
  - មន្ត្រីបុគ្គលិករដ្ឋបាលរាជធានី ខេត្តមានចំនួន **២៦.១៤១នាក់** (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន **៣.១៦១នាក់** និងគ្រូពេទ្យមានចំនួន **២៣.៤៨០នាក់**)
  - មន្ត្រីបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន **៧៦.៩០៣នាក់** (មន្ត្រីបុគ្គលិករដ្ឋបាល និងបុគ្គលិកជំនាញបច្ចេកទេសចំនួន **១២.២៣៩នាក់** និងគ្រូបង្រៀនចំនួន **៦៤.៦៦៤នាក់**)។

**១០. ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈ ក្រោមការគាំទ្រពីកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋ (ISD/GIZ/SDC/Luxambur) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរកិច្ចការនារី ព្រមទាំងតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។
- លេខាធិការដ្ឋាន គ.ជ.អ.ប.បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ទិន្នន័យមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ឆ្នាំ២០២៥**

| ល.រ | មុខតំណែងគ្រប់គ្រង | ឆ្នាំ២០២៥ | | |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ភាគរយស្ត្រី (%) |
| ១ | អភិបាល | ២៥ | ២ | ៨% |
| ២ | អភិបាលរង | ២៤៨ | ៣១ | ១៣% |
| ៣ | នាយករដ្ឋបាល | ២៥ | ១ | ៤% |
| ៤ | នាយករងរដ្ឋបាល | ១២១ | ២៣ | ១៩% |
| ៥ | នាយកទីចាត់ការ និងឬថ្នាក់ស្មើ | ២០៨ | ២៣ | ១១% |
| ៦ | នាយករងទីចាត់ការ និងឬថ្នាក់ស្មើ | ៤០៤ | ១០៦ | ២៦% |
| ៧ | ប្រធានការិយាល័យ | ៣៩៤ | ១០៦ | ២៧% |
| ៨ | អនុប្រធានការិយាល័យ | ៧០៦ | ៣០៩ | ៤៤% |
| **សរុប** | | **២.១៣១** | **៥៧០** | **២៧%** |

**ទិន្នន័យមន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២៥**

| ល.រ | មុខតំណែងគ្រប់គ្រង | ឆ្នាំ២០២៥ | | |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ភាគរយស្ត្រី (%) |
| ១ | អភិបាល | ២១០ | ៦ | ៣% |
| ២ | អភិបាលរង | ១.២១៤ | ២៤៩ | ២១% |
| ៣ | នាយករដ្ឋបាល | ១៩៨ | ២១ | ១១% |
| ៤ | នាយករងរដ្ឋបាល | ៥១១ | ១៣៩ | ២៧% |
| ៥ | ប្រធានការិយាល័យ និងឬថ្នាក់ស្មើ | ២.២៩៣ | ៥០៣ | ២២% |
| ៦ | អនុប្រធានការិយាល័យ និងឬថ្នាក់ស្មើ | ៣.៤២១ | ១.០៣៣ | ៣០% |
| **សរុប** | | **៧.៨៤៧** | **១.៩៥១** | **២៥%** |

### ១០. ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

- សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងបូកសរុបរបាយការណ៍អំពីតម្រូវការសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបាននិងកំពុងធ្វើបច្ចុប្បន្នភាពទិន្នន័យកម្រិតវប្បធម៌ធនធានមនុស្សនៅរដ្ឋបាល ឃុំ សង្កាត់។ ទន្ទឹមនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានចុះតាមដានត្រួតពិនិត្យ និងគាំទ្រវគ្គបណ្តុះបណ្តាលដល់ស្រុកចំនួន៥ រួមមានស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម ស្រុកស្អាង និងស្រុកអង្គស្នួល នៃខេត្តកណ្តាល ព្រមទាំងស្រុកសាមគ្គីមុនីជ័យ នៃខេត្តកំពង់ស្ពឺ។
- រដ្ឋបាលខេត្តចំនួន៥ រួមមានខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់បានរៀបចំ និងអនុវត្តការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខេត្ត។

### ១១. ការរៀបចំ និងការដាក់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព

- រដ្ឋបាលរាជធានី ខេត្តចំនួន២៥ បានរៀបចំផែនការផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០២៥ ដល់បុគ្គលិករបស់ខ្លួន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- រដ្ឋបាលរាជធានី ខេត្តមួយចំនួនបានសម្របសម្រួល រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលនយោបាយ បទដ្ឋានបច្ចេកទេសពាក់ព័ន្ធនានាដល់មន្ត្រី បុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់សរុបចំនួន **៥៤៤វគ្គ** ដែលមានសិក្ខាកាមចូលរួមសរុបចំនួន **៤៥.១៦៣នាក់** ស្ត្រី **១៤.៨៦៧នាក់** ដោយផ្តោតលើប្រធានបទសំខាន់ៗ ដូចជា៖
  - ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម

- ភាពជាអ្នកដឹកនាំ និងជំនាញសម្របសម្រួល
- ការពង្រឹងតួនាទីរបស់ គ.ក.ស.ក. និង គ.ក.ន.ក.
- ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ ការលើកកម្ពស់សេវាសង្គម
- ការរៀបចំលក្ខខណ្ឌការងារជូនមន្ត្រីរាជការ
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា
- ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- វេទិកាពិគ្រោះយោបល់ជាមួយអង្គការដៃគូ
- គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
- ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការងារគណនេយ្យភាពសង្គម
- ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត
- ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា។

**១២. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន**

- សាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលចំនួន **១១វគ្គ** ពាក់ព័ន្ធវិធីសាស្ត្រលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ការអប់រំភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត និងអនាម័យ មូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នវានុវត្តន៍សម្រាប់រដ្ឋបាលមូលដ្ឋាន ការរៀបចំផែនការ និងគ្រប់គ្រងគម្រោង សម្រាប់ក្រុមគោលដៅជាគ្រូបង្គោលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

- ក្នុងក្របខ័ណ្ឌការងារកែលម្អ និងធ្វើទំនើបកម្មអង្គភាព សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំមណ្ឌលចំនួន២រួមមាន៖ មណ្ឌលចំណេះដឹងអំពីការអភិវឌ្ឍមូលដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍មូលដ្ឋានដោយចីរភាព ដែលបច្ចុប្បន្នសាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំឯកសារគោលគំនិតស្តីពីការរៀបចំមណ្ឌលចំណេះដឹងអំពីការអភិវឌ្ឍមូលដ្ឋាន និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីរៀបចំបញ្ចប់ ព្រមទាំងបាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីការរៀបចំមណ្ឌលអភិវឌ្ឍន៍មូលដ្ឋានដោយចីរភាព។

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន២វគ្គ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងពិធីការការទូត និងបដិសណ្ឋារកិច្ច ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣៦នាក់ (ស្រី១៥នាក់)។

**១៣. កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល**

- សាលាជាតិរដ្ឋបាលមូលដ្ឋាន បានចុះអនុស្សរណៈនៃការយោគយល់គ្នាចំនួន២ជាមួយក្រសួង

ប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គការវ៉េតធីអេតអន្តរជាតិកម្ពុជា ព្រមទាំងអនុស្សរណៈនៃការយោគយល់គ្នាជាមួយដៃគូសរុបចំនួន១៥ ក្នុងនោះ ក្រសួងចំនួន១ ស្ថាប័នបណ្តុះបណ្តាលចំនួន៨ (ក្នុងប្រទេសចំនួន៧ និងក្រៅប្រទេសចំនួន១) និងអង្គការសង្គម ស៊ីវិលចំនួន៦។ ទន្ទឹមនេះ សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាកលវិទ្យាល័យជាតិគ្រប់គ្រង ព្រមទាំងបាននិងកំពុងពិនិត្យលទ្ធភាពចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅកម្ពុជា សាខាខេត្តកំពត។

- សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងអនុវត្តគម្រោងចំនួន៣ រួមមាន ៖ (១). គម្រោងសាលាជាតិរដ្ឋបាលមូលដ្ឋាន (២). គម្រោងលើកកម្ពស់ភាពជាដៃគូត្រីភាគីក្នុងការអភិវឌ្ឍមូលដ្ឋានប្រកប ដោយចីរភាពនៅថ្នាក់ក្រោមជាតិ និង(៣). គម្រោងការធ្វើមូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព ដោយសម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

- ក្នុងក្របខ័ណ្ឌនៃគម្រោងសាលាជាតិរដ្ឋបាលមូលដ្ឋាន ការសាងសង់អគារសាលាជាតិរដ្ឋបាលមូលដ្ឋានបានសាងសង់រួចរាល់១០០% បច្ចុប្បន្ន គម្រោងបាននិងកំពុងដំណើរការនីតិវិធីដេញថ្លៃសម្ភារបរិក្ខារដើម្បីបំពាក់នៅអគារសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីត្រៀមសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ២០២៦ខាងមុខ។
- ក្នុងក្របខ័ណ្ឌគម្រោងលើកកម្ពស់ភាពជាដៃគូត្រីភាគីក្នុងការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាពនៅថ្នាក់ក្រោមជាតិ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង រដ្ឋបាលខេត្ត និងអង្គការជាដៃគូអនុវត្តគម្រោង ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានសម្រាប់ក្រុមគោលដៅនៅខេត្តកំពត កាលពីថ្ងៃទី១៣-១៤ ខែមីនា ឆ្នាំ២០២៥ ព្រមទាំងបានអនុវត្តសាកល្បងវិធីសាស្ត្រដែលបានបណ្តុះបណ្តាល តាមរយៈការរៀបចំវេទិកាសាធារណៈនៅសង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥។ ជាមួយនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានធ្វើការវាស់ស្ទង់តម្រូវការបណ្តុះបណ្តាលរបស់ក្រុមគោលដៅអនុវត្តគម្រោង និងបានបូកសរុបរបាយការណ៍លទ្ធផលវាស់ស្ទង់ ព្រមទាំងបាននិងកំពុងត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោង ដើម្បីបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត។
- ក្នុងក្របខ័ណ្ឌគម្រោងការធ្វើមូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សាលាជាតិរដ្ឋបាលមូលដ្ឋានបានបង្កើតក្រុមការងារអនុវត្តគម្រោងការធ្វើមូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

- សាលាជាតិរដ្ឋបាលមូលដ្ឋានក៏បាននិងកំពុងសហការជាមួយដៃគូជាតិ និងអន្តរជាតិចំនួន៧ ស្ថាប័នរួមមាន អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ វិទ្យាស្ថានមេគង្គ អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការតម្លាភាពកម្ពុជា វិទ្យាស្ថានបណ្តុះបណ្តាល និង

ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា អង្គការវ័តធីអេត និងអង្គការអាក់សិនអេតអន្តរជាតិ ដើម្បីសហការក្នុងការរៀបចំការបណ្តុះបណ្តាល ការកែសម្រួលឯកសារបណ្តុះបណ្តាល និងការស្រាវជ្រាវរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។

- ក្រសួងមុខងារសាធារណៈបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីលេខាធិការដ្ឋាន គ.ជ.អ.ប. បានផ្សព្វផ្សាយព្រះរាជក្រឹត្យលេខ នស/រកត/១២២៤/១៥៥៩ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ០១ អនក្រ.បក ស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ ព្រមទាំងមន្ទីរមុខងារសាធារណៈ។

## ១៤. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន**៧៦វគ្គ** ដែលមានសិក្ខាកាមចូលរួមសរុបចំនួន**៥.៥២៩នាក់ ស្ត្រីចំនួន១.៧៣៦នាក់** សម្រាប់ក្រុមគោលដៅជាមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលទ្ធផលដូចតារាងខាងក្រោម៖

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនសិក្ខាកាម | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | វគ្គបណ្តុះបណ្តាលស្តីពីសេវាសាធារណៈឆ្លើយតបនឹងយេនឌ័រផ្សារភ្ជាប់ថវិកាឃុំសង្កាត់ | ៣ | ១១២ | ៧២ |
| ២ | វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីកិច្ចការស្មៀន និងការតាក់តែងអត្ថបទនិងអក្សរ កម្មវិធីជីថលសម្រាប់ស្មៀនឃុំ សង្កាត់វគ្គទី១ វគ្គទី២ និងវគ្គទី៣ | ៤ | ៣៣១ | ៩៩ |
| ៣ | វគ្គបណ្តុះបណ្តាលជុំទី២ នៃកម្មវិធីការអប់រំភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត និងអនាម័យសម្រាប់ក្រុមគោលដៅ | ៤ | ១៦០ | ៦៨ |
| ៤ | កម្មវិធីគ្រប់គ្រងជាន់ខ្ពស់, កម្មវិធីលេខាធិការរដ្ឋបាលវគ្គទី២, កម្មវិធីគ្រប់គ្រងកម្រិត១វគ្គ១ ដល់វគ្គ៤, កម្មវិធីភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីជំនាន់៧ វគ្គទី១, កម្មវិធីវិក្រឹតការមូលដ្ឋានជំនាន់៩វគ្គ៣, | ១៣ | ៦៧៨ | ២០១ |
| ៥ | វគ្គវិក្រឹត្យការជំនាញរាជធានី ខេត្ត ក្រុង ស្រុក វគ្គ១ ដល់វគ្គ៤ | ១១ | ៥៨៤ | ១៤៧ |

| | | | | |
|---|---|---|---|---|
| ៦ | វគ្គអន្តរាគមន៍អភិវឌ្ឍសមត្ថភាព | ៦ | ៣១០ | ៩០ |
| ៧ | ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ វគ្គទី១ វគ្គទី២ វគ្គទី៣ | ៤ | ៣២៥ | ៥៥ |
| ៨ | វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន | ៣ | ៩៣ | ២០ |
| ៩ | កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការរៀបចំនិងគ្រប់គ្រងគម្រោង | ៣ | ៩៤ | ១៩ |
| ១០ | កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការរៀបចំផែនការនិងគ្រប់គ្រងទីក្រុងប្រកបដោយចីរភាព | ៣ | ៩៤ | ១៩ |
| ១១ | ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមសម្រាប់ថ្នាក់ដឹកនាំនៅរដ្ឋបាលរាជធានី ខេត្ត វគ្គទី១ វគ្គទី២ | ២ | ១០០ | ២៣ |
| ១២ | វគ្គភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ | ៣ | ៦៨៤ | ២៤០ |
| ១៣ | វគ្គបណ្តុះបណ្តាលស្តីពី"នវានុវត្តន៍សម្រាប់រដ្ឋបាលមូលដ្ឋាន" និង "មូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" | ៤ | ៩៦ | ២៩ |
| ១៤ | វគ្គបណ្តុះបណ្តាលស្តីពីពិធីការ និងបដិសណ្ឋារកិច្ច វគ្គទី១ វគ្គទី២ វគ្គទី៣ | ៣ | ៥០៧ | ២៤៥ |
| ១៥ | វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងរដ្ឋបាលសង្កាត់សម្រាប់ក្រុមប្រឹក្សាសង្កាត់ចំនួន១០៥សង្កាត់ របស់រដ្ឋបាលសាលារាជធានីភ្នំពេញ វគ្គទី៣ វគ្គទី៤ | ៥ | ១.១៦៩ | ៣២៩ |
| ១៦ | កិច្ចការរដ្ឋបាល ការតាក់តែងលិខិតរដ្ឋបាល និងព័ត៌មានវិទ្យាសម្រាប់ការិយាល័យ | ១ | ៨០ | ៣៨ |
| ១៧ | វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំ និងការអនុវត្តផែនការនិងថវិការដ្ឋបាលឃុំ សង្កាត់ ពាក់ព័ន្ធការងារអត្រានុកូលដ្ឋាននៅរដ្ឋបាលឃុំ សង្កាត់ | ១ | ៦៤ | ២៩ |

| | | | | |
|---|---|---|---|---|
| ១៨ | ប្រព័ន្ធតាមដានការអនុវត្តគម្រោង កម្មវិធីវាយតម្លៃការបណ្តុះបណ្តាល និងការរៀបចំផែនការ និងការគ្រប់គ្រងផ្អែកលើលទ្ធផលសម្រាប់ផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | ១ | ២៣ | ១០ |
| ១៩ | ការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការ | ១ | ២៥ | ៣ |
| សរុប | | ៧៦ | ៥.៥.២៩ | ១.៧៣៦ |

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានចាត់គ្រូបង្គោលទៅចូលរួមផ្តល់វគ្គបណ្តុះបណ្តាលចំនួន២វគ្គស្តីពីការវិភាគទិន្នន័យ និងសរសេររបាយការណ៍ការសិក្សាស្រាវជ្រាវបែបចូលរួមស្តីពីថវិកាសាលារៀននៅកម្រិតបឋមសិក្សា និងការលើកកម្ពស់ការចូលរួម ដែលរៀបចំដោយអង្គការអាក់សិនអេតកម្ពុជា។

**១៥. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា**

- សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំកម្មវិធីសិក្សាចំនួន៦ដូចជាកម្មវិធីសិក្សារយៈពេលវែង កម្មវិធីសិក្សារយៈពេលខ្លីសម្រាប់សាធារណជន កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលកិច្ចការទាំងនេះសម្រេចបានវឌ្ឍនភាពពី៧០%ទៅ៨០%។

- សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំ និងឬកែសម្រួលកម្មវិធីសិក្សាចំនួន៥សម្រាប់ក្រុមគោលដៅជាមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត។

**១៦. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា**

- សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំសៀវភៅគោលចំនួន៥ពាក់ព័ន្ធ (១). ការគ្រប់គ្រងមុខងារសុខាភិបាល (២). ការធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព (៣). ការងារពិធីការ (៤). ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និង (៥). ក្រមសីលធម៌មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ។

## ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៤នេះ រួមមានសកម្មភាពជាអាទិភាពចំនួន**១៦** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន**១៦** ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២៦-២០២៨ ត្រូវបានពិនិត្យ ពិភាក្សា និងមានឯកភាពដោយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួងសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

- ក្រសួងមហាផ្ទៃសហការជាមួយក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប.កំពុងសិក្សាវាយតម្លៃអំពីដំណើរការនៃការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ (UNICEF)។ ការសិក្សានេះ ត្រូវបានធ្វើឡើងនៅរាជធានី ខេត្តគោលដៅចំនួន៥ (រាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តកំពត ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៩ ឃុំ សង្កាត់ចំនួន ១២ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធចំនួន៣។

- រដ្ឋបាលរាជធានី ខេត្តចំនួន២៥ និងរដ្ឋបាលខណ្ឌទាំង១៤ បានរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងបានបញ្ជូនមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងផ្តល់អនុលោម ដោយសម្រេចបានការផ្តល់អនុលោមភាពទាំង២៥រដ្ឋបាលរាជធានី ខេត្ត និង១៤រដ្ឋបាលខណ្ឌ ស្មើនឹង១០០%។ ជាមួយគ្នានេះរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ បានបញ្ចប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៥-២០២៧) ដោយសម្រេចបាន១០០%។ គិតត្រឹមឆ្នាំ២០២៥នេះ រដ្ឋបាលរាជធានី ខេត្តទាំង ២៥ស្មើនឹង ១០០% បាន និងកំពុងអនុវត្តជំហានទី៣ នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំ (២០២៦-២០២៨)។ ដោយឡែករដ្ឋបាលខណ្ឌទាំង១៤ នៃរដ្ឋបាលរាជធានីភ្នំពេញ បានអនុវត្ត និងកំពុងអនុវត្តជំហានទី២។

## ២. ការរៀបចំឯកសារយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រស្តីពីការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបសម្ព័ន្ធនៃកម្មវិធីជាតិ ដំណាក់កាលទី២ (២០២១-២០៣០)។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានផ្តល់ធាតុចូលទៅក្នុងសេចក្តីព្រាងឯកសារផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (NDC 3.0) ដើម្បីធ្វើបច្ចុប្បន្នភាពពីលើវឌ្ឍនភាពដែលសម្រេចបានក្នុងការរៀបចំ NDC 3.0 លើការងារអន្តរវិស័យ រួមមាន ការងារយេនឌ័រ ថាមពល ដឹកជញ្ជូន សំណល់ កសិកម្ម អភិបាលកិច្ច ព្រៃឈើ គាំពារសង្គមនិងកុមារ សុខភាពនិងអនាម័យ គ្រោះមហន្តរាយ និងវិស័យហេដ្ឋារចនាសម្ព័ន្ធ។

## ៣. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងផែនការដោយមានការចូលរួមពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យអនឡាញ ព្រមទាំងបានប្រមូល ផលិត និងចែករំលែកព័ត៌មានជាសាធារណៈអំពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។

- ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បាននិងកំពុងពិនិត្យកែសម្រួលជំពូកទី២ ស្តីអំពីការរៀបចំគម្រោង និងការពិនិត្យបញ្ជាក់បច្ចេកទេសលើគោលការណ៍សុវត្ថិភាពនិងបរិស្ថានសង្គមនៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងកែសម្រួលយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈក្នុងក្របខ័ណ្ឌថ្មី (២០២៥-២០២៨)។

**៩. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)**

- ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៥ សរុបមានចំនួន **៧.១៩៣.៦៦៩ លានរៀល** សមមូលនឹង **១.៧៥៤,៥៥លានដុល្លារ** ធៀបនឹងឆ្នាំ២០២៤ គឺមានចំនួនកើនឡើងប្រមាណ **៥៤,៧៦លានដុល្លារ** សមមូលនឹង**៣**% ក្នុងនោះ៖
    - ថវិការាជធានី ខេត្តមានចំនួន **៣.៥៥៤.៥០២លានរៀល** សមមូលនឹង **៨៦៦,៩៥លានដុល្លារ** ធៀបនឹងឆ្នាំ២០២៤ មានការថយចុះ**០.២៥**% ក្នុងនោះមានរួមបញ្ចូលនូវថវិកាវិស័យសុខាភិបាលចំនួន **៩២៦.៥៥៨លានរៀល** សមមូលនឹង **២២៦លានដុល្លារ** និងថវិកាវិស័យអប់រំចំនួន **៩១.៧៣៧លានរៀល** សមមូលនឹង **២២,៣៧លានដុល្លារ**។
    - ថវិកាក្រុង ស្រុក មានចំនួន **២.៣៤១.៥២០លានរៀល** សមមូលនឹង **៥៧១,១០លានដុល្លារ** ធៀបនឹងឆ្នាំ២០២៤ មានការកើនឡើង៤% ក្នុងនោះថវិកាវិស័យអប់រំ យុវជន និងកីឡាចំនួន **១.៧៥៣.៧៨៩លានរៀល** សមមូលនឹង **៤២៧,៧៥លានដុល្លារ**។
    - ថវិកាឃុំ សង្កាត់មានចំនួន **១.២៩៧.៦៤៧លានរៀល** សមមូលនឹង **៣១៦,៥០លានដុល្លារ** ធៀបនឹងឆ្នាំ២០២៤ មានការកើនឡើង**១៣**%។



- ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៥ ដែលមានចំនួន **៤.៥១៣.៣២២ លានរៀល** (ដោយមិនគិតបញ្ចូលថវិកាវិស័យសុខាភិបាល និងថវិកាវិស័យអប់រំ) ត្រូវបានគ្រោងសម្រាប់ប្រភេទចំណាយដូចខាងក្រោម៖

| ល.រ | ប្រភេទចំណាយ | ចំនួន (លានរៀល) | អត្រា (%) |
|---|---|---|---|
| ១ | បន្ទុកបុគ្គលិក | ៨៨៩.០៤១ | ២០% |
| ២ | ការអភិវឌ្ឍន៍មូលដ្ឋាន | ១.៧៤៥.៥៨៨ | ៣៩% |
| ៣ | សេវាសង្គម និងអនាម័យបរិស្ថាន | ២៥៨.៦១១ | ៦% |
| ៤ | ប្រតិបត្តិការរដ្ឋបាល | ៩១០.៨៩១ | ២០% |
| ៥ | ការបែងចែករវាងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៧០៩.១៩១ | ១៦% |
| **សរុប** | | **៤៥១៣.៣២២** | **១០០%** |




- ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលមានចំនួន **២.៦២៧.៩៤៤លានរៀល** (ដោយមិនគិតបញ្ចូលថវិកាវិស័យសុខាភិបាល និងថវិកាវិស័យអប់រំ) ត្រូវបានគ្រោងសម្រាប់ប្រភេទចំណាយ ដូចខាងក្រោម៖

| ល.រ | ប្រភេទចំណាយ | ចំនួន (លានរៀល) | អត្រា (%) |
|---|---|---|---|
| ១ | បន្ទុកបុគ្គលិក | ២០៤.២១៣ | ៨% |
| ២ | ការអភិវឌ្ឍន៍មូលដ្ឋាន | ៨៧៣.១៧២ | ៣៣% |
| ៣ | សេវាសង្គម និងអនាម័យបរិស្ថាន | ១៤៧.៨៤៣ | ៦% |
| ៤ | ប្រតិបត្តិការរដ្ឋបាល | ៦៩៣.៥២៦ | ២៦% |
| ៥ | ការបែងចែករវាងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៧០៩.១៩១ | ២៧% |
| **សរុប** | | **២.៦២៧.៩៤៤** | **១០០%** |




- ថវិការបស់រដ្ឋបាលក្រុង ស្រុកដែលមានចំនួន **៥៨៧.៧៣១លានរៀល** (ដោយមិនគិតបញ្ចូលថវិកាវិស័យអប់រំ) ត្រូវបានគ្រោងសម្រាប់ប្រភេទចំណាយ ត្រូវបានគ្រោងសម្រាប់ប្រភេទចំណាយ ដូចខាងក្រោម៖

| ល.រ | ប្រភេទចំណាយ | ចំនួន (លានរៀល) | អត្រា (%) |
|---|---|---|---|
| ១ | បន្ទុកបុគ្គលិក | ២៧១.១៣០ | ៤៦% |
| ២ | ការអភិវឌ្ឍន៍មូលដ្ឋាន | ២១០.២៩៥ | ៣៦% |
| ៣ | សេវាសង្គម និងអនាម័យបរិស្ថាន | ២០.០០០ | ៣% |
| ៤ | ប្រតិបត្តិការរដ្ឋបាល | ៨៦.៣០៦ | ១៥% |
| **សរុប** | | **៥៨៧.៧៣១** | **១០០%** |



- ថវិកាសរុបរបស់រដ្ឋបាលឃុំ សង្កាត់ដែលមានចំនួន **១.២៩៧.៦៤៧ លានរៀល** ត្រូវបានគ្រោងសម្រាប់ប្រភេទចំណាយ ដូចខាងក្រោម៖

| ល.រ | ប្រភេទចំណាយ | ចំនួន (លានរៀល) | អត្រា (%) |
|---|---|---|---|
| ១ | បន្ទុកបុគ្គលិក | ៤១៣.៦៩៨ | ៣២% |
| ២ | ការអភិវឌ្ឍន៍មូលដ្ឋាន | ៦៤៥.៦៧៥ | ៥0% |
| ៣ | សេវាសង្គម និងអនាម័យបរិស្ថាន | ១0៧.២១៤ | ៨% |
| ៤ | ប្រតិបត្តិការរដ្ឋបាល | ១៣១.0៦0 | ១0% |
| **សរុប** | | **១.២៩៧.៦៤៧** | **១00%** |




- ឆ្នាំ២0២៥នេះ រដ្ឋបាលថ្នាក់ក្រោមជាតិទទួលចំណូលថវិកាជាក់ស្តែងបានចំនួន **៧.៩៧៧.៦២៤ លានរៀល** (**១.៩៤៥,៧៦លានដុល្លារ**) និងបានចំណាយជាក់ស្តែងចំនួន **៦.៩៤២.៤៨៩លានរៀល** (**១.៦៩៣,២៩លានដុល្លារ**) ស្មើនឹង**៨៧**% នៃចំណូលជាក់ស្តែងសរុបប្រចាំឆ្នាំ២0២៥ ក្នុងនោះ៖ (១). ចំណូលថវិកាជាក់ស្តែងរបស់រាជធានី ខេត្តមានចំនួន **៤.១១៤.២៣៣លានរៀល** (**១.00៣,៤៧ លានដុល្លារ**) និងបានចំណាយជាក់ស្តែងចំនួន **៣.១៨៦.៧0៦លានរៀល** (**៧៧៧,២៥លានដុល្លារ**) ស្មើនឹង**៧៧**% នៃចំណូលជាក់ស្តែងសរុបប្រចាំឆ្នាំរបស់រាជធានី ខេត្ត (២). ចំណូលថវិកាជាក់ស្តែងរបស់ក្រុង ស្រុកមានចំនួន **២.៥៦១.៤២២លានរៀល** (**៦២៤,៧៣លានដុល្លារ**) និងបានចំណាយជាក់ស្តែងចំនួន **២.៥២៤.៥៥0លានរៀល** (**៦១៥,៧៤លានដុល្លារ**) ស្មើនឹង៩៩% នៃចំណូលជាក់ស្តែងសរុបប្រចាំឆ្នាំរបស់ក្រុង ស្រុក និង (៣). ចំណូលថវិកាជាក់ស្តែងរបស់ឃុំ សង្កាត់មានចំនួន **១.៣0១.៩៦៩ លានរៀល** (**៣១៧,៥៥លានដុល្លារ**) និងបានចំណាយជាក់ស្តែងចំនួន **១.២៣១.២៣៣លានរៀល** (**៣00,៣0លានដុល្លារ**) ស្មើនឹង៩៥% នៃចំណូលជាក់ស្តែងសរុបប្រចាំឆ្នាំរបស់ឃុំ សង្កាត់។

| ចំណូល និងចំណាយថវិកាជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំឆ្នាំ២០២៥ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | ថ្នាក់ថវិកា | ចំណូលជាក់ស្តែង | | ចំណាយជាក់ស្តែង | | % |
| | | លានរៀល | លានដុល្លារ | លានរៀល | លានដុល្លារ | |
| ១ | រាជធានី ខេត្ត | ៤.១១៤.២៣៣ | ១.០០៣,៤៧ | ៣.១៨៦.៧០៦ | ៧៧៧,២៥ | ៧៧% |
| ២ | ក្រុង ស្រុក | ២.៥៦១.៤២២ | ៦២៤,៧៣ | ២.៥២៤.៥៥០ | ៦១៥,៧៤ | ៩៩% |
| ៣ | ឃុំ សង្កាត់ | ១.៣០១.៩៦៩ | ៣១៧,៥៥ | ១.២៣១.២៣៣ | ៣០០,៣០ | ៩៥% |
| សរុប | | ៧.៩៧៧.៦២៤ | ១.៩៤៥,៧៦ | ៦.៩៤២.៤៨៩ | ១.៦៩៣,២៩ | ៨៧% |




– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅរៀបចំកែសម្រួលប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការកំណត់កម្រៃសេវាសម្រាប់សេវានានាដែលបានប្រតិភូកម្មដោយក្រសួង ស្ថាប័ននានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាល

ថ្នាក់ក្រោមជាតិ(ថ្មី) ដើម្បីរក្សាគុណភាពនៃឧត្តមានុវត្តន៍កម្ពុជាទៅនឹងទិសដៅនៃការកែទម្រង់ពាក់ព័ន្ធ ឱ្យមានសង្គតិភាពជាមួយនឹងគោលការណ៍គ្រឹះនៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ច្បាប់រៀបចំអង្គការ និងថ្លឹងថ្លែងជាមួយនឹងនិន្នាការនៃការអនុវត្តជាអន្តរជាតិ និងនៅតាមបណ្តាប្រទេសមួយចំនួនក្នុងតំបន់។

- រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងការតាមដានត្រួតពិនិត្យ ការអនុវត្តថវិកា និងការរៀបចំរបាយការណ៍។

- រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសបាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំនាន់ទី១ សម្រាប់ទូទាត់ចំណាយថវិការបស់ខ្លួន។ ដោយឡែក រដ្ឋបាលក្រុង និងរដ្ឋបាលខណ្ឌកំពុងអនុវត្តសាកល្បងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំនាន់ទី២ សម្រាប់ទូទាត់ចំណាយថវិការបស់ខ្លួន។

- រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតបាន និងកំពុងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តឆ្នាំ២០២៦-២០២៨ និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាឆ្នាំ២០២៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្អែកលើសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់នូវក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ២០២៦ ដល់ឆ្នាំ២០២៨ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

*ឯកតា៖ លានរៀល*

| **រដ្ឋបាលថ្នាក់ក្រោមជាតិ** | **គម្រោងថវិកាឆ្នាំ ២០២៦** | **គម្រោងថវិកាឆ្នាំ ២០២៧** | **គម្រោងថវិកាឆ្នាំ ២០២៨** |
|---|---|---|---|
| **សរុបចំណូល** | 3 994 480.1 | 4 212 968.7 | 4 520 779.9 |
| ចំណូលសារពើពន្ធ | 1 987 990.1 | 2 125 161.5 | 2 297 299.5 |
| ចំណូលមិនមែនសារពើពន្ធ | 306 567.6 | 318 217.2 | 329 991.2 |
| ចំណូលផ្សេងៗ | 1 699 922.4 | 1 769 590.0 | 1 893 489.1 |
| **សរុបចំណាយ** | 3 994 480.1 | 4 212 968.7 | 4 520 779.9 |
| បន្ទុកបុគ្គលិក(មិនគិតបញ្ចូលប្រាក់រង្វាន់) | 923 710.5 | 961 582.6 | 1 001 969.1 |
| មិនមែនបន្ទុកបុគ្គលិក | 3 070 769.7 | 3 251 386.1 | 3 518 810.8 |

| | | | |
|---|---|---|---|
| **០១-រដ្ឋបាលរាជធានី ខេត្ត** | | | |
| **សរុបចំណូល** | 2 282 142.1 | 2 430 491.2 | 2 613 926.5 |
| ចំណូលសារពើពន្ធ | 1 987 990.1 | 2 125 161.5 | 2 297 299.5 |
| ចំណូលមិនមែនសារពើពន្ធ | 294 152.0 | 305 329.8 | 316 627.0 |
| ចំណូលផ្សេងៗ | | | |
| **សរុបចំណាយ** | 2 282 142.1 | 2 430 491.2 | 2 613 926.5 |
| បន្ទុកបុគ្គលិក(មិនគិតបញ្ចូលប្រាក់រង្វាន់) | 221 451.3 | 230 530.8 | 240 213.1 |
| មិនមែនបន្ទុកបុគ្គលិក | 2 060 690.9 | 2 199 960.5 | 2 373 713.5 |
| **០២-រដ្ឋបាលក្រុង ស្រុក** | | | |
| **សរុបចំណូល** | 458 239.1 | 476 543.8 | 509 940.2 |
| ចំណូលសារពើពន្ធ | 0.0 | 0.0 | 0.0 |
| ចំណូលមិនមែនសារពើពន្ធ | 12 415.6 | 12 887.4 | 13 364.3 |
| ចំណូលផ្សេងៗ | 445 823.4 | 463 656.4 | 496 576.0 |
| **សរុបចំណាយ** | 458 239.1 | 476 543.8 | 509 940.2 |
| បន្ទុកបុគ្គលិក(មិនគិតបញ្ចូលប្រាក់រង្វាន់) | 278 596.8 | 290 019.1 | 302 199.9 |
| មិនមែនបន្ទុកបុគ្គលិក | 179 642.5 | 186 524.7 | 207 740.4 |
| **០៣-រដ្ឋបាលឃុំ សង្កាត់** | | | |
| **សរុបចំណូល** | 1254 098.9 | 1 305 933.6 | 1 396 913.1 |
| ចំណូលសារពើពន្ធ | 0.0 | 0.0 | 0.0 |
| ចំណូលមិនមែនសារពើពន្ធ | 0.0 | 0.0 | 0.0 |
| ចំណូលផ្សេងៗ | 1 254 098.9 | 1 305 933.6 | 1 396 913.1 |
| មូលនិធិឃុំ សង្កាត់ | 974 961.6 | 1 015 910.0 | 1 086 007.8 |
| មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ | 279 137.3 | 290 023.7 | 310 905.4 |
| **សរុបចំណាយ** | 1254 098.9 | 1 305 933.6 | 1 396 913.1 |
| បន្ទុកបុគ្គលិក(មិនគិតបញ្ចូលប្រាក់រង្វាន់) | 423 662.6 | 441 032.8 | 459 556.1 |
| មិនមែនបន្ទុកបុគ្គលិក | 830 436.3 | 864 900.9 | 937 357.0 |

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់គោលការណ៍ណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ លើការរៀបចំផែនការសកម្មភាពការងារ និងគ្រោងថវិកាសម្រាប់មុខសញ្ញាចាំបាច់នានាប្រចាំឆ្នាំ២០២៦ របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌនីមួយៗ ហើយបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលនីមួយៗ ដើម្បីឱ្យក្រុមប្រឹក្សានីមួយៗមានកញ្ចប់ថវិកាសម្រាប់បំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

## ៥. ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់គោលការណ៍ណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ

ថវិការាជធានី ខេត្តឆ្នាំ២០២៦-២០២៨ និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាឆ្នាំ២០២៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៦. ការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់**

- ផ្អែកតាមគោលការណ៍របស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងអត្រា ៤% សម្រាប់ឆ្នាំថវិកានីមួយៗ ប៉ុន្តែសម្រាប់ថវិកាឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពុំទាន់បានកំណត់បែងចែកចំណូលនេះទៅឱ្យក្រុង ស្រុកនៅឡើយទេ។ ដូចគ្នានេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់បែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តជូន រដ្ឋបាលឃុំ សង្កាត់ (លើកលែងសង្កាត់ក្នុងរាជធានីភ្នំពេញ) ក្នុងអត្រា ៦% ដែលមានទំហំថវិកាសរុបចំនួន **១០៩.៣១៨ លានរៀល** (**សមមូលនឹង ៦៦,៦៦ លានដុល្លារ**) ផ្អែកតាមលិខិតលេខ៧៩៤១ សហវ.ល.ស.អកហ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤។

**៧. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា**

- រដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស កំពុងបន្តអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)។
- អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង២៥ កំពុងបន្តអនុវត្តប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) សម្រាប់កម្រៃសេវារដ្ឋបាល។
- ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងសម្របសម្រួលការងារជាមួយធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំនីតិវិធីសម្រាប់បង់កម្រៃសេវារដ្ឋបាលនៅតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាម QR CODE។

**៨. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងសហការជាមួយក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងលេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំសេចក្តីព្រាងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្មី)។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានពិនិត្យពិភាក្សាចប់សព្វគ្រប់ក្នុងក្របខណ្ឌមន្ត្រីបច្ចេកទេស។

**៩. ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានដាក់ចេញនូវសារាចរណែនាំអន្តរក្រសួងស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំរបាយការណ៍លទ្ធផលនៃការសិក្សាអំពីជម្រើសនៃការកែសម្រួលរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់វិភាជន៍មូលនិធិក្រុង ស្រុក ដែលការសិក្សានេះគាំទ្រដោយGIZ។

- ក្នុងឆ្នាំ២០២៥នេះ មូលនិធិក្រុង ស្រុកបានទទួលធនធានផ្ទេរពីថវិកាជាតិក្នុងអត្រា១,៦% នៃចំណូលចរន្តថវិកាជាតិដែលមានទំហំប្រមាណ**៤៧៨.៣៣៦ លានរៀល** (**១៦៦,៦៧ លានដុល្លារអាមេរិក**)។ មូលនិធិឃុំ សង្កាត់បានទទួលធនធានផ្ទេរពីថវិកាជាតិក្នុងអត្រា៣,៥% នៃចំណូលចរន្តថវិកាជាតិដែលមានទំហំប្រមាណ១,០០៩,៤៧៨.៣៣៦ លានរៀល (២៤៦,១៧ លានដុល្លារអាមេរិក)។

**១០. ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តនូវសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារអប់រំយុវជន និងកីឡានៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

**១១. ការកំណត់ និងផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងរៀបចំរបាយការណ៍លទ្ធផលស្តីពីការសិក្សា និងកំណត់នូវមុខងារដែលមានតម្រូវការធនធានក្នុងវិស័យជំនាញទាំង១៩ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមស្មារតីនៃអនុក្រឹត្យលេខ១៨២ ១៨៣និង១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- ក្នុងឆ្នាំ២០២៥នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសរុបប្រមាណ២.៧៨៥.៤២៦ លានរៀល (៦៧៨,៨១ លានដុល្លារអាមេរិក) សម្រាប់អនុវត្តមុខងារវិស័យនានាដែលក្រសួង ស្ថាប័នថ្នាក់បានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ មានដូចខាងក្រោម៖

| ល.រ | មុខងារ | ទំហំថវិកា | | រដ្ឋបាលថ្នាក់ក្រោមជាតិ | ផ្សេងៗ |
|---|---|---|---|---|---|
| | | លានរៀល | លានដុល្លារ | | |
| ១ | សុខាភិបាល | ៩២៦.៥៥៨ | ២២៦ | រាជធានី ខេត្ត | ថវិកាថ្នាក់ជាតិ |
| ២ | អប់រំ | ១.៨៤៥.៥២៦ | ៤៥០ | ក្រុង ស្រុក ខណ្ឌ | ថវិកាថ្នាក់ជាតិ |
| ៣ | ការគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋ | ៤.៩២៨ | ១,២០ | ១៨ រាជធានី ខេត្ត | ថវិការាជធានី ខេត្ត |
| ៤ | សេវាអនាម័យបរិស្ថាន និងការគ្រប់គ្រងសំណល់រឹងទីប្រជុំជន | ៨.០០០ | ១,៥១ | ៣៣ ក្រុង | ថវិការាជធានី ខេត្ត |
| ៥ | ការលើកកម្ពស់អនាម័យជនបទ ការជួសជុលអណ្តូង និងការថែទាំផ្លូវជនបទ | ៤១០ | ០,១០ | ២១ ក្រុង ស្រុក | ថវិកាថ្នាក់ជាតិ |
| **សរុប** | | ២.៧៨៥.៤២៦ | ៦៧៨,៨១ | | |

**១២. ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រុមការងារអន្តរក្រសួងបានបញ្ចប់ការសិក្សាអំពីមុខងារ និងធនធានចាំបាច់នានាសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងខែធ្នូ ឆ្នាំ២០២៤។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលក្រុង ស្រុកសម្រាប់ផ្តល់ហិរញ្ញប្បទានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF)។
- លេខាធិការដ្ឋានក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (ក.វ.ក) បានចូលរួមពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់) ក្នុងការអនុវត្តគម្រោង SNIF ក៏ដូចជាគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ជាដើម។
- ក្នុងឆ្នាំ២០២៥ រដ្ឋបាលស្រុកចំនួន១៥ ក្នុងខេត្តចំនួន១៥ បានទទួលការផ្ទេរធនធានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិសរុបប្រមាណ៦,៥០០ លានរៀល (១,៥៩ លានដុល្លារអាមេរិក)។

**១៣. ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីមូលនិធិភាតរភាព។ ការបង្កើតមូលនិធិភាតរភាពនេះ មានគោលបំណងដើម្បីបង្កើនការផ្ទេរធនធានបន្ថែមពីថ្នាក់ជាតិសម្រាប់ជាគុណប្រយោជន៍ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមូលនិធិនេះ មានប្រភពចំណូលពី (១). ការចែករំលែកចំណូលពីសេវាធារណៈដែលស្ថិតក្នុងមុខងារគ្រប់គ្រង និងប្រមូលដោយក្រសួង ស្ថាប័នថ្នាក់ជាតិតាមអត្រាដែលកំណត់ដោយរាជរដ្ឋាភិបាល និង(២). ការចែករំលែកចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលរួមមាន ៖ ចំណូលពីការសម្បទាននេសាទ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញរាជធានីខេត្ត ចំណូលពីសម្បទានដីសេដ្ឋកិច្ច ចំណូលពីផលព្រៃឈើ និង/ឬចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀតដែលមានការសម្រេចពីរាជរដ្ឋាភិបាល។

**១៤. ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ឆ្នាំ២០២៥ ក្រសួង ស្ថាប័នចំនួន១០ បានដាក់ចេញនូវប្រកាស និងឬសេចក្តីសម្រេចប្រតិភូកម្មដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួនដែលរួមមាន ៖ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្ត ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងពាណិជ្ជកម្ម ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីពិនិត្យ ផ្តល់យោបល់ និងសម្រេចលើការចុះបញ្ជីគម្រោងវិនិយោគនានាដែលទុនសមមូលនឹង៥លានដុល្លារចុះ។ ដោយឡែក

ក្រសួង២ទៀត កំពុងដំណើរការរៀបចំប្រកាសប្រតិភូកម្ម រួមមាន ៖ ក្រសួងសុខាភិបាល និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានដាក់ចេញប្រកាសអន្តរក្រសួងលេខ០៧០ សហវ.ប្រក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ស្តីពីនីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ សម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត ព្រមទាំងបានផ្សព្វផ្សាយ និងឱ្យអនុវត្តរួចហើយ។

- លេខាធិការដ្ឋាន គ.ជ.អ.ប អគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានឌីជីថលនៃក្រសួងមហាផ្ទៃ បាននិងកំពុងពិភាក្សាជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការរៀបចំ និងដាក់ឱ្យអនុវត្តការចុះបញ្ជីគម្រោងវិនិយោគតាមប្រព័ន្ធឌីជីថល (CDC IPM)។

- សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ នីតិវិធីនៃការគ្រប់គ្រងការវិនិយោគក្រោម៥លានដុល្លារសម្រាប់អនុវត្តនៅថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំ និងពិគ្រោះយោបល់ចំនួន២ដងជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយដែលនឹងដាក់ឱ្យអនុវត្តនៅដើមឆ្នាំ២០២៦។

- គិតត្រឹម២០២៥នេះ រដ្ឋបាលរាជធានី ខេត្តបានចុះបញ្ជីគម្រោងវិនិយោគចំនួន**២៨៥គម្រោង** មានដើមទុនសរុប **៩៥៨.១០៨.៤៤៦ដុល្លារអាមេរិក** និងបង្កើតការងារបានចំនួន **១៣៤.៨៦០កន្លែង** ដែលមានលទ្ធផលដូចខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនគម្រោងដែលបានចុះបញ្ជី | សរុបទុនវិនិយោគសរុប (ដុល្លារ) | បង្កើតការងារ (កន្លែង) |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ៤៤ | ១៣៤.៣៦៥.៧៨៦ | ២២.៧០៣ |
| ២ | កណ្តាល | ៥៤ | ១៧៩.១៦២.៩៥៥ | ២២.០៩៧ |
| ៣ | កំពង់ធំ | ១ | ៤.៥០៨.៩៦២ | ៣០៤ |
| ៤ | កំពង់ស្ពឺ | ១២៣ | ៤២៦.៨៥៨.២៤៥ | ៥៦.៧៨៥ |
| ៥ | កោះកុង | ១ | ៤.៩២៨.៣០៧ | ១១៥ |
| ៦ | តាកែវ | ៤៧ | ១៥៥.៣៧២.២១៧ | ២៦.៣៥៨ |
| ៧ | ត្បូងឃ្មុំ | ២ | ៨.១២៧.៦៦៨ | ៥៣៣ |
| ៨ | ព្រះសីហនុ | ៦ | ២១.៤៨៨.១៨៩ | ១.៣៧៩ |
| ៩ | មណ្ឌលគិរី | ១ | ១.៥០០.០០០ | ១៥០ |
| ១០ | ស្វាយរៀង | ៦ | ២១.៧៩៦.១១៧ | ១.៤៣៩ |
| **សរុប** | | **២៨៥** | **៩៥៨.១០៨.៤៤៦** | **១៣៤.៨៦០** |




## ខ. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

សមាសភាគទី៥នេះ រួមមានសកម្មភាពជាអាទិភាពចំនួន ៩ នៅក្នុងនោះសកម្មភាពអាទិភាព ត្រូវបានអនុវត្តចំនួន ៩ សកម្មភាពដោយមានវឌ្ឍនភាពដូចខាងក្រោម៖

### ១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

- **មុខងារអប់រំ យុវជន និងកីឡា**ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន១៤ក្នុងខេត្តបាត់ដំបង នាឆ្នាំ២០២០ និងត្រូវបានពង្រីកការផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសនាឆ្នាំ២០២៣ តាមរយៈអនុក្រឹត្យលេខ២១៣អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ធនធាននានាក៏ត្រូវបានផ្ទេរភ្ជាប់ទៅជាមួយនឹងមុខងារដែលរួមមាន ធនធានហិរញ្ញវត្ថុប្រមាណ **១.៨៤៥.៥២៦លានរៀល** សមមូលនឹង **៤៤៨,១២លានដុល្លារ** ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០២៥ សម្រាប់អនុវត្តមុខងារចំនួន៣ គឺ (១). មុខងារអប់រំកុមារតូច (២). មុខងារអប់រំបឋមសិក្សា និង(៣). មុខងារអប់រំក្រៅប្រព័ន្ធ និងបុគ្គលិកជាគ្រូបង្រៀនសរុបចំនួនប្រមាណជាង៧០.០០០នាក់ (គ្រូក្របខ័ណ្ឌ និងគ្រូកិច្ចសន្យា) ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ក្នុងរយៈពេល៦ខែដើមឆ្នាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញសារាចរលេខ០០២សហវ.ស.រ.អរតណ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាល

ដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា។ ទន្ទឹមនេះក្រសួងអប់រំ យុវជន និងកីឡា បានគាំទ្រ តាមដាន ត្រួតពិនិត្យលើការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមរយៈ (១). ការបណ្តុះបណ្តាលស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡានៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមសរុប១០៨នាក់ (២). ការចុះគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលក្រុង ស្រុក លើការងារគ្រប់គ្រង ដឹកនាំ ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានផ្ទេរនៅក្រុង ស្រុក គោលដៅក្នុង ខេត្តចំនួន៩ ខេត្ត និង (៣). ការចុះពិនិត្យ និងវាយតម្លៃរដ្ឋបាលក្រុង ស្រុកអំពីការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ក្នុងក្របខណ្ឌគម្រោងគាំទ្រដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ (World Vision International) ក្នុងក្រុង ស្រុកគោលដៅទាំង១២ នៃខេត្តសៀមរាប (៦ក្រុង ស្រុក) និងខេត្តបន្ទាយមានជ័យ (៦ក្រុង ស្រុក)។

- **មុខងារសុខាភិបាល**ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តនាឆ្នាំ២០១៩ តាមរយៈអនុក្រឹត្យលេខ១៩៣អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារ និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ តាមរយៈអនុក្រឹត្យនេះ ធនធាននានាក៏ត្រូវបានផ្ទេរភ្ជាប់ទៅជាមួយនឹងមុខងារដែលរួមមាន ធនធានហិរញ្ញវត្ថុប្រមាណ **៩២៦.៥៥៨លានរៀល** សមមូលនឹង **២២៦លានដុល្លារ** ត្រូវបានផ្ទេរក្នុងឆ្នាំ២០២៥ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំលេខ៣៨០សជណ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៥ ស្តីពីការពង្រឹងលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត។ ក្រៅពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រសួងសុខាភិបាល ដោយមានការគាំទ្រពីកម្មវិធីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅកម្ពុជា (ISD/GIZ) បានចុះសិក្សាវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យលេខ១៩៣ និងការសិក្សាលទ្ធភាពស្តីពីការផ្ទេរមុខងារសុខាភិបាលពីរដ្ឋបាលរាជធានី ខេត្ត ទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។

- **មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋ**ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនាឆ្នាំ២០១៧ តាមរយៈអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។ តាមរយៈអនុក្រឹត្យនេះ នៅឆ្នាំ២០២៥ រដ្ឋបាលរាជធានី ខេត្តចំនួន**១៨** បានគ្រោងថវិកាសរុបប្រមាណ **៤.៩២៨លានរៀល** សមមូលនឹង **១,២០លានដុល្លារ** សម្រាប់ការគ្រប់គ្រងថែទាំកុមាររដ្ឋចំនួន**២០** ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា បានចុះពិនិត្យ តាមដាន និងគាំទ្រលើការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋនៅក្នុងខេត្តបាត់ដំបង នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ និងខេត្តកំពង់ឆ្នាំង នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ដែលមានគោលបំណង

ដើម្បីតាមដាន និងផ្តល់ការគាំទ្រដល់រដ្ឋបាលខេត្តក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ និងទទួលសំណើ សំណូមពរនានាសម្រាប់ជាយន្តការដោះស្រាយនូវបញ្ហាប្រឈមនៅក្នុងការអនុវត្តមុខងារដែលបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

- **មុខងារគ្រប់គ្រងសំរាម និងសំណល់រឹង**ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងស្រុកនាឆ្នាំ២០១៥ តាមរយៈអនុក្រឹត្យលេខ១១៣អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ តាមរយៈអនុក្រឹត្យនេះ ធនធាននានាក៏ត្រូវបានផ្ទេរភ្ជាប់ទៅជាមួយនឹងមុខងារដែលរួមមាន ធនធានហិរញ្ញវត្ថុប្រមាណ **៨.០០០លានរៀល** សមមូលនឹង **១,៩៥លានដុល្លារ** ត្រូវបានផ្ទេរក្នុងឆ្នាំ២០២៥ ទៅឱ្យរដ្ឋបាលក្រុងទាំង**៣២** នៃរដ្ឋបាលខេត្ត២៤។ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីកម្មវិធីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅកម្ពុជា (ISD/GIZ) បាននិងកំពុងគាំទ្រដល់រដ្ឋបាល ក្រុង ស្រុកចំនួន៦ នៃខេត្តចំនួន៣ ដែលរួមមាន ក្រុងបាត់ដំបង ស្រុកមោងឫស្សីនិងស្រុកបវេលនៃខេត្តបាត់ដំបង ក្រុងសៀមរាបនិងស្រុកសូទ្រនិគមនៃខេត្តសៀមរាប និងក្រុងប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យក្នុងការរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងនៅរដ្ឋបាលក្រុង ស្រុកទាំងនេះ ដោយបានគិតគូរពីការប្រែប្រួលអាកាសធាតុ និងលក្ខណៈសមស្របសម្រាប់ពង្រីកទៅឱ្យរដ្ឋបាលក្រុង ស្រុកផ្សេងទៀត។

### ២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

- ក្រសួងមហាផ្ទៃបានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការកែសម្រួលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM) ត្រង់ជំពូកទី២ ស្តីអំពីការរៀបចំគម្រោង និងការពិនិត្យបញ្ជាក់បច្ចេកទេសអំពីគោលការណ៍សុវត្ថិភាព និងបរិស្ថានសង្គម។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានត្រួតពិនិត្យ និងបញ្ជាក់លើរបាយការណ៍បច្ចេកទេសកិច្ចការសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចលើគម្រោងមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុក មានចំនួន**សរុប ៣៨៧គម្រោង** ដែលរួមមានផ្លូវដី ផ្លូវបេតុង ស្ពានប្រឡាយ ដាក់បង្គោលភ្លើង សាងសង់របងសាលា១គម្រោង ចាក់សាប សង់ស្ពាន និងសង់ទំនប់ទឹក។ល។

- ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៥ មានចំនួន **២.៤១៦គម្រោង** ថវិកាសរុបចំនួន **៦៣៣.៧៦៦លានរៀល** ក្នុងនោះ ៖

- គម្រោងបានបញ្ចប់ការសិក្សាចំនួន **២.៤១៦គម្រោង** ថវិកាចំនួន **៦៣៣.៧៦៦លានរៀល** (ស្មើនឹង១០០%)
- គម្រោងដេញថ្លៃរួចចំនួន **២.៣៤៥គម្រោង** ថវិកាចំនួន **៥០៨.៩១១លាន រៀល** (ស្មើនឹងប្រមាណ៩៧.០៦%នៃគម្រោងបានបញ្ចប់ការសិក្សា)
  - គម្រោងចុះកិច្ចសន្យាចំនួន **២.៣៤៥គម្រោង** ថវិកាចំនួន **៦១៧.២៩១លានរៀល** ស្មើនឹង១០០% នៃគម្រោងដែលបានដេញថ្លៃរួច

- គម្រោងបញ្ចប់ការសាងសង់១០០% ចំនួន**១.៣៥៩កិច្ចសន្យា**ថវិកាចំនួន **៣៨១.៣១៨លានរៀល** (ស្មើនឹងប្រមាណ៥៧.៩៥%នៃកិច្ចសន្យាសរុប)
- គម្រោងមិនទាន់បញ្ចប់ការសាងសង់១០០% ចំនួន **៩៨៦កិច្ចសន្យា** ដែលមានថវិកាចំនួន **២៧៥.៩៧៣លានរៀល** (ស្មើនឹងប្រមាណ៤២.០៥%នៃកិច្ចសន្យាសរុប)។







- ការរៀបចំគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០២៥ មានចំនួន **៥៧៤គម្រោង** ថវិកាសរុបចំនួន **២០៥.៤៥៤លានរៀល** ក្នុងនោះ ៖

- គម្រោងបានបញ្ចប់ការសិក្សាចំនួន **៥៧៤គម្រោង** ថវិកាចំនួន **២០៥.៤៥៤លានរៀល**
- គម្រោងដេញថ្លៃរួចចំនួន **៥៧២គម្រោង** ថវិកាចំនួន **២០០.០៥៥លានរៀល** (ស្មើនឹងប្រមាណ៩៩.៦៥%នៃគម្រោងបានបញ្ចប់ការសិក្សា)
- គម្រោងបានចុះកិច្ចសន្យារួចចំនួន **៥៧២គម្រោង** ថវិកាចំនួន **២០៣.៣២១លានរៀល** ស្មើនឹង១០០% នៃគម្រោងដែលបានដេញថ្លៃរួច
- បញ្ចប់ការសាងសង់១០០% ចំនួន **៥៦៥កិច្ចសន្យា** ថវិកាចំនួន **២០០.១៩៧លានរៀល** (ស្មើនឹងប្រមាណ៩៨.៧៨%នៃកិច្ចសន្យាសរុប)
- គម្រោងមិនទាន់បញ្ចប់ការសាងសង់១០០% ចំនួន **៧កិច្ចសន្យា** ថវិកាចំនួន **៣.១២៤លានរៀល** (ស្មើនឹងប្រមាណ១.២២%នៃកិច្ចសន្យាសរុប)។







- ការរៀបចំគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២៥ ចំនួន**២៦៧គម្រោង** មានទឹកប្រាក់សរុបចំនួន **៦១៣.៤៥៥.៤១៦.៩៣០រៀល** គិតជាដុល្លារប្រហែល **១៥៣,៣លានដុល្លារ**។ គម្រោងភាគច្រើនជាគម្រោងស្ថាបនា និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជា ផ្លូវថ្នល់ អគាររដ្ឋបាល អគាររដ្ឋបាលឃុំ សង្កាត់ អគារសិក្សា បណ្តាញអគ្គិសនី សួនច្បារសាធារណៈ ប្រព័ន្ធលូបង្ហូរទឹក ស្ថានីយ៍បូមទឹក ច្រាំងទន្លេ ស្ពានប្រឡាយដោះទឹក ភ្លើងសញ្ញាចរាចរ គំនូសចរាចរណ៍ និងសំណង់សិល្បការនានា។
- ក្នុងឆ្នាំ២០២៥នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានគ្រោងថវិកាផ្នែកសេវាសង្គម និងអនាម័យបរិស្ថានសរុបចំនួន **២៧៥.០៥៧លានរៀល** សមមូលនឹង **៦៧,០៩លានដុល្លារ** ក្នុងនោះ៖
    - រដ្ឋបាលរាជធានី ខេត្ត ចំនួន **១៤៧.៨៤៣លានរៀល** សមមូលនឹង **៣៦,០៦លានដុល្លារ**
    - រដ្ឋបាលក្រុង ស្រុកទូទាំង ចំនួន **២០.០០០លានរៀល** សមមូលនឹង **៤,៨៨លានដុល្លារ**
    - រដ្ឋបាលឃុំ សង្កាត់ ចំនួន **១០៧.២១៤លានរៀល** សមមូលនឹង **២៦,១៥លានដុល្លារ**។




## ៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត

- ក្រសួងមហាផ្ទៃបានសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ និងការកែសម្រួលលើលិខិតគតិយុត្ត និងបទដ្ឋានបច្ចេកទេសនានា ដើម្បីជំរុញការលើកកម្ពស់ការផ្តល់សេវា

សាធារណៈ ដែលរួមមាន ៖ (១). ការរៀបចំសេចក្តីណែនាំបច្ចេកទេស ការកំណត់ស្តង់ដារ គោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តការផ្តល់សេវា (២). ការរៀបចំ និងការកែសម្រួលបញ្ជីកម្រងសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យពាណិជ្ជកម្ម វិស័យសុខាភិបាល វិស័យឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍ និងវិស័យមួយចំនួនផ្សេងទៀត និង(៣). ការកែសម្រួលអត្រាប្រាក់រង្វាន់របស់រដ្ឋបាលរាជធានី ខេត្ត និងអត្រាប្រាក់រង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃពីចំណូលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

- ក្រសួងមហាផ្ទៃបានគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចដំណើរការនៃការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈ ៖ (១). ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (២). ការចុះសិក្សា និងវាយតម្លៃលើស្ថានភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (៣). ការរៀបចំយន្តការមួយចំនួន ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាធ្វើការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ (៤). ការប្រមូលទិន្នន័យនៃការផ្តល់សេវារដ្ឋបាលនៅតាមយន្តការច្រកចេញចូលតែមួយថ្នាក់រាជធានី ខេត្ត និងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ នូវសេវាដែលបានផ្តល់ជូនប្រជាពលរដ្ឋច្រើនជាងគេ និងតិចជាងគេក្នុងឆ្នាំ២០២៤ (៥). ការពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (៦). ការពិនិត្យមើលលើការរៀបចំបញ្ជីសេវារដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត និង(៧). ការរៀបចំការប្រឡងប្រណាំងជ្រើសរើសអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តឆ្នើមប្រចាំឆ្នាំ២០២៥។

- នៅឆ្នាំ២០២៥នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត បានផ្តល់សេវារដ្ឋបាលសរុបចំនួន **៧៨៨.១១៧សេវា**។ បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់ក្នុងវិស័យទាំង១៤ **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** បានផ្តល់សេវាច្រើនជាងគេគឺចំនួន **២៧៤.០៨៧សេវា** (**ស្មើនឹង ៣៤,៧៨%**) បន្ទាប់មកគឺ**វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានផ្តល់សេវាចំនួន **១៩៣.១៤២សេវា** (**ស្មើនឹង ២៤,៥១%**)។ ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេគឺ**វិស័យពាណិជ្ជកម្ម**បានផ្តល់សេវាចំនួន **១២សេវា** (**ស្មើនឹង០,០០២%**)។




– នៅឆ្នាំ២០២៥នេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន **១៤៦.២៤៤.៣៥០.០៦១រៀល** (**ស្មើនឹង៣៦.៥៦១.០៨៧,៥១ដុល្លារអាមេរិក**)។ ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបានក្នុងវិស័យទាំង១៤ **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន **១១២.៣៨៩.០៩៣.៥៩១រៀល** (**ស្មើនឹង៧៦.៨៥%**) បន្ទាប់មក**វិស័យសាធារណការ និងដឹកជញ្ជូន** ទទួលបានចំណូលចំនួន **១០.៣៨២.៦៤០.៨០០រៀល** (**ស្មើនឹង៧,១០%**)។ ចំពោះវិស័យដែលបានទទួលចំណូលតិចជាងគេគឺវិស័យពាណិជ្ជកម្មបានទទួលចំណូលចំនួន **២.៤០០.០០០រៀល** (**ស្មើនឹង០,០០២%**)។



## ៩. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- នៅឆ្នាំ២០២៥នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ បានផ្តល់សេវារដ្ឋបាលសរុបចំនួន **៣.៩៤៦.៣៤៧សេវា។** ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់ក្នុងវិស័យទាំង**១៧** **ការងារអត្រានុកូលដ្ឋាន** បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន**២.១៩៩.៥៣១សេវា** (**ស្មើនឹង៥៥.៧៤**%) បន្ទាប់មកការងារនីត្យានុកូលកម្មបានផ្តល់សេវាចំនួន១.៤៨៤.**១៥៦សេវា** (**ស្មើនឹង៣៧,៦១**%)។ ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេគឺ**វិស័យបរិស្ថាន**បានផ្តល់សេវាចំនួន**២សេវា**(**ស្មើនឹង០,០០០១**%)។




- នៅក្នុងឆ្នាំ២០២៥នេះ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន**១១.៨៩៩.៨៧៨.៤១៤រៀល** (**ស្មើនឹង២.៩៧៤.៩៦៩,៦០ដុល្លារអាមេរិក**)។ ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបានក្នុងវិស័យទាំង១៧ **វិស័យសំណង់**ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន**៣.១៧១.៦០៣.១២០រៀល** (**ស្មើនឹង២៧.០៩**%) បន្ទាប់មក**វិស័យសុរិយោដី**ទទួលបានចំណូលចំនួន**២.២០៦.៤៣០.០០០រៀល** (**ស្មើនឹង១៨.៧៥**%)។ ចំពោះវិស័យដែលបានទទួលចំណូលតិចជាងគេគឺ**វិស័យពាណិជ្ជកម្ម**ទទួលបានចំណូលចំនួន **១២៥.០០០រៀល** (**ស្មើនឹង ០.០០១**%) និងវិស័យដែលមិនទទួលបានចំណូលគឺការងារ**អត្រានុកូលដ្ឋាន និងវិស័យធម្មការនិងសាសនា**។




## ៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ

- ក្រសួងមហាផ្ទៃបាននិងកំពុងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងជំនាញ និងប្រព័ន្ធផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយក្នុងនោះរួមមាន ៖ (១). ការធ្វើសន្ទានកម្មរវាងប្រព័ន្ធគ្រប់គ្រង និងផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយ និងប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការផ្តល់សេវារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (២). ការធ្វើសន្ទានកម្មរវាងប្រព័ន្ធគ្រប់គ្រង និងផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយ និងប្រព័ន្ធផ្តល់សេវាតាមប្រព័ន្ធឌីជីថលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- ក្រសួងមហាផ្ទៃបាននិងកំពុងសហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីរៀបចំនីតិវិធីនៃការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិច (E-Payment NRMIS) នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

- ក្រសួងមហាផ្ទៃបាននិងកំពុងពិនិត្យ និងកែសម្រួលសេចក្តីព្រាងសារាចរស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី៥ នៅរដ្ឋបាលរាជធានី ខេត្ត។

- ក្រសួងមហាផ្ទៃបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងកំពុងរៀបចំឱ្យមានប្រព័ន្ធទូទាត់អេឡិចត្រូនិច (KHQR) នៅតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ នៅទូទាំងប្រទេស។

- ក្រសួងមហាផ្ទៃបាននិងកំពុងរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជាប្រព័ន្ធផ្តល់សេវាសាធារណៈឌីជីថល ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការស្នើសុំការចុះបញ្ជី ការបង់កម្រៃសេវា និងការគ្រប់គ្រងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។ ប្រព័ន្ធនេះចែកចេញជា២ គឺ៖

(១). ប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអនឡាញ។

(២). ប្រព័ន្ធគ្រប់គ្រងទិន្នន័យសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

**៦. យន្តការនានាក្នុងការសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការ និងសម្របសម្រួលជាមួយក្រសួងបរិស្ថានក្នុងការរៀបចំផែនការជាតិរួមចំណែកឆ្លើយតបនឹងអាកាសធាតុ ដំណាក់កាលទី៣ (NDC 3.0) ក្នុងនោះសកម្មភាពដែលគ្រោងនឹងអនុវត្តគឺ ការពង្រឹងយន្តការសម្របសម្រួលការប្រែប្រួលអាកាសធាតុ និងយន្តការសម្របសម្រួលផ្សេងៗទៀតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសិក្សាជាជម្រើសក្នុងការធ្វើសមាហរណកម្មការងារប្រែប្រួលអាកាសធាតុទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧. ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយ UNCDF និងក្រុមហ៊ុន OIKO ក្នុងការប្រមូលទិន្នន័យផលប៉ះពាល់ពីការពីការប្រែប្រួលអាកាសធាតុនៅរាជធានី ខេត្តទាំង២៥ ដែលគិតមកទល់ពេលនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. UNCDF និងក្រុមហ៊ុន OIKO កំពុងពិនិត្យ និងពិភាក្សាជាមួយក្រសួងបរិស្ថានលើប្រព័ន្ធទិន្នន័យដែលមានស្រាប់ក្នុងប្រទេសកម្ពុជា រួមមាន ប្រព័ន្ធ Vulnerability Assessment ប្រព័ន្ធ SPD និងប្រព័ន្ធ PID សម្រាប់ចងក្រងទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយនិងជំងឺឆ្លងកាចសាហាវនានានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សកម្មភាពនេះ គឺមានបំណងរៀបចំចងក្រងជាប្រព័ន្ធទិន្នន័យថ្មីមួយដែលមានការវិភាគបែបវិទ្យាសាស្ត្រ អំពីការរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅតាមមុខសញ្ញាភាពងាយគ្រោះនីមួយៗនៅកម្រិតក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យមានទិន្នន័យបែបវិទ្យាសាស្ត្រក្នុងការកសាងផែនការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែមានភាពសុក្រឹត និងប្រសើរឡើង។

**៨. ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

- លេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការ UNCDF បានចុះកិច្ចព្រមព្រៀងក្នុងការអនុវត្តគម្រោង LoCAL កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ ដែលគម្រោងនេះមានគោលបំណងដើម្បី ៖ (១). រៀបចំសំណើគម្រោងរដ្ឋបាលមូលដ្ឋាននិងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (២). ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (៣). រៀបចំប្រព័ន្ធហិរញ្ញប្បទានអាកាសធាតុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និង (៤). ពង្រឹងសមត្ថភាពលេខាធិការដ្ឋាន គ.ជ.អ.ប. លើការបិទបញ្ចប់លក្ខខណ្ឌទទួលស្គាល់ជាស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង ។

- លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរៀបចំឯកសារទស្សនទានគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចកសិករខ្នាតតូចធន់ដែលធន់នឹងអាកាសធាតុ (SRED-SP)

ដែលបានអនុម័ត និងចុះហត្ថលេខានៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥។ គម្រោងនេះ បាននិងកំពុងរៀបចំឯកសារគម្រោង (PPTA) ពេញលេញ និងគ្រោងអនុម័តនៅក្នុងឆ្នាំ២០២៦ ដែលមានទំហំទឹកប្រាក់ប្រមាណ៧០លានដុល្លារ។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយនឹងអង្គការ UNDP រៀបចំកិច្ចព្រមព្រៀងក្នុងការអនុវត្តគម្រោងមូលដ្ឋាននីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព នៅក្នុងក្រុងគោលដៅចំនួន០២គឺ ៖ ក្រុងសៀមរាប ខេត្តសៀមរាប និងក្រុងកំពង់ចាម ខេត្តកំពង់ចាម។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំសំណើគម្រោងរបស់មូលនិធិអាកាសធាតុបៃតង (GCF) ស្តីពីគម្រោងរដ្ឋបាលមូលដ្ឋាននិងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ (LGCC-3) ដែលមានថវិកាចំនួន១០លានដុល្លារសម្រាប់ការគាំទ្ររដ្ឋបាលក្រុង ស្រុក ចំនួន២៥ ក្នុងការរៀបចំគម្រោងបន្សាំការប្រែប្រួលអាកាសធាតុនៅក្នុងមូលដ្ឋានរបស់ខ្លួន។ គម្រោងបានទទួលការអនុម័តជាផ្លូវការនាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងសុងដូ សាធារណរដ្ឋកូរ៉េខាងត្បូង ក្នុងអំឡុងពេលនៃកិច្ចប្រជុំលើកទី៤៣ របស់ក្រុមប្រឹក្សាមូលនិធិអាកាសធាតុបៃតង (GCF)។

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំ និងបង្កើតសៀវភៅណែនាំការបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ បរិយាបន្នសង្គមទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុកម្ពុជារបស់គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ជំហានទី២ (EmPower-II)។ សៀវភៅណែនាំនេះ រៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាព និងជំនាញបន្ថែមដល់អ្នកទទួលបន្ទុកការងារអាកាសធាតុ និងការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័នក្នុងការចូលរួមលើកកម្ពស់ការគិតគូរការបញ្ជ្រាបយេនឌ័រ បរិយាបន្នសង្គមទៅសកម្មភាព និងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ប្រកបដោយប្រសិទ្ធភាព ដោយសង្កត់ធ្ងន់លើប្រធានបទដូចជាបញ្ហាយេនឌ័រ ការបែងចែកធនធាន និងវិធីសាស្ត្រចងក្រង និងគ្រប់គ្រងទិន្នន័យយេនឌ័រ។

## ៣. ស្ថានភាពហិរញ្ញវត្ថុ

ផ.ស.ថឆ្នាំ២០២៥នេះ រួមមានលទ្ធផលរំពឹងទុកចំនួន៣៤ សកម្មភាពជាអាទិភាពចំនួន **៨៧** សកម្មភាពលម្អិតចំនួន **២២៣** សូចនាករចំនួន**១១០** និងគម្រោងថវិកាចំណាយសរុបមានចំនួន **៧.២៩៧.៥២៦ លានរៀល** ( **១.៧៧៩,៨៨ លានដុល្លារ** ) ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន **៧.២០៤.៥៧៧ លានរៀល** ( **១.៧៥៧,២១ លានដុល្លារ** ) ស្មើនឹង **៩៨,៧៣**% និងថវិកាកម្ចី និងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាមានចំនួន **៩២.៩៥០ លានរៀល** ( **២២,៥៧ លានដុល្លារ** ) ស្មើនឹង ១,**២៧**% នៃថវិកាសរុប។

ឆ្នាំ២០២៥នេះ ចំណាយសរុបសម្រាប់ ផ.ស.ថ. របស់ គ.ជ.អ.ប. មាន**ចំនួន ៦.៨២៥.៨៦៣ លានរៀល** សមមូល**១.៦៦៤,៨៤លានដុល្លារ ស្មើនឹង ៩៣**% នៃផែនការថវិកាដែលបានគ្រោងទុក

សរុបចំនួន **៧.២៩៧.៥២៦ លានរៀល** សមមូល**១.៧៧៩,៨៨ លានដុល្លារ**។ ការចំណាយនេះ រួមបញ្ចូលការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយរបស់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបានគាំទ្រដល់ ផ.ស.ថ. ឆ្នាំ២០២៥។ ខាងក្រោមនេះ បង្ហាញអំពីក្រាហ្វិកនានានៃការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍន៍តាមសេចក្ដីសម្រេចរួមនិងកិច្ចព្រមព្រៀង និងចំណូលសរុប និងចំណាយសរុបជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះ៖

- ចំពោះការអនុវត្តសកម្មភាពនានានៃសេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងរវាង គ.ជ.អ.ប. ជាមួយស្ថាប័នអនុវត្តបានចំណាយថវិកាសរុបចំនួន **១១២.២៦៩លានរៀល សមមូល២៧,៣៣ លានដុល្លារ ស្មើនឹង៨២%** ធៀបនឹងថវិកាឆ្នាំ២០២៥មានចំនួន**១៣៧.០៤៧លានរៀល សមមូល ៣៣,៤លានដុល្លារ** ដូចរៀបរាប់សង្ខេបក្នុងតារាង និងក្រាហ្វិកដូចខាងក្រោម។

**តារាងទី៧ ៖ សង្ខេបការអនុវត្តថវិកាឆ្នាំ២០២៥ (គិតជាលានរៀល)**

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកាឆ្នាំ២០២៥ | | ការចំណាយ | | ភាគរយ |
|---|---|---|---|---|---|---|
| | | លានរៀល | លានដុល្លារ | លានរៀល | លានដុល្លារ | |
| ១ | ក្រសួង ស្ថាប័នថ្នាក់ជាតិ | ១១.០៦៨ | ២,៦៩ | ១០.៧៤៦ | ២,៦២ | ៩៧% |
| ២ | រដ្ឋបាលថ្នាក់ក្រោមជាតិ | ១៨.៧៦៦ | ៤,៥៧ | ១៣.២២៦ | ៣,២២ | ៧០% |
| ៤ | ថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍ | ១០៧.២១៣ | ២៦,១៤ | ៨៨.២៩៧ | ២១,៥៣ | ៨២% |
| **សរុប** | | **១៣៧.០៤៧** | **៣៣,៤** | **១១២.២៦៩** | **២៧,៣៣** | **៨២%** |

*** តួលេខចំណាយឆ្នាំ២០២៥*




- រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បានចំណាយជាក់ស្តែងសរុបចំនួន **៦.៧១៣.៥៩៤លានរៀល សមមូល ១.៦៣៧លានដុល្លារ ស្មើនឹង៨៦%** នៃចំណូលជាក់ស្តែងសរុបដែលមានចំនួន

**៧.៧៨០.២៣៩លានរៀលសមមូល១.៨៩៧,៦២លានដុល្លារ** ក្នុងនោះ រដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់នីមួយៗបានអនុវត្តចំណាយដូចខាងក្រោម៖

- រាជធានី ខេត្ត បានចំណាយសរុបចំនួន **២.៩៨៣.០២៤លានរៀល** សមមូល **៧២៧,៥៧ លានដុល្លារ ស្មើនឹង ៧៦%** នៃចំណូលសរុបមានចំនួន**៣.៩២០.៥១៦លានរៀល សមមូល ៩៥៦,២២លានដុល្លារ**
- ក្រុង ស្រុក បានចំណាយសរុបចំនួន **២.៥០០.៥២៦លានរៀល សមមូល ៦០៩,៨៨ លានដុល្លារ ស្មើនឹង ៩៨%** នៃចំណូលសរុបដែលមានចំនួន**២.៥៥៨.២៧៩ លានរៀល សមមូល៦២៣,៩៧លានដុល្លារ**
- ឃុំ សង្កាត់ បានចំណាយសរុបចំនួន **១.២៣០.០៤៤ លានរៀល សមមូល ៣០០,០១ លានដុល្លារ ស្មើនឹង ៩៥%** នៃចំណូលសរុបដែលមានចំនួន **១.១៣០.៤៤៤ លានរៀល សមមូល ៣១៧,៤៣ លានដុល្លារ**។

| ចំណូល និងចំណាយថវិកាជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំឆ្នាំ២០២៥ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | ថ្នាក់ថវិកា | ចំណូលជាក់ស្តែង | | ចំណាយជាក់ស្តែង | | % |
| | | លានរៀល | លានដុល្លារ | លានរៀល | លានដុល្លារ | |
| ១ | រាជធានី ខេត្ត | ៤.១១៤.២៣៣ | ១.០០៣,៤៧ | ៣.១៨៦.៧០៦ | ៧៧៧,២៥ | ៧៧% |
| ២ | ក្រុង ស្រុក | ២.៥៦១.៤២២ | ៦២៤,៧៣ | ២.៥២៤.៥៥០ | ៦១៥,៧៤ | ៩៩% |
| ៣ | ឃុំ សង្កាត់ | ១.៣០១.៩៦៩ | ៣១៧,៥៥ | ១.២៣១.២៣៣ | ៣០០,៣០ | ៩៥% |
| **សរុប** | | **៧.៩៧៧.៦២៤** | **១.៩៤៥,៧៦** | **៦.៩៤២.៤៨៩** | **១.៦៩៣,២៩** | **៨៧%** |

## ៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

ក្នុងការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៥នេះ មានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ រួមមាន៖

– ការដាក់ចេញគោលនយោបាយ យុទ្ធសាស្ត្រ ក្របខណ្ឌគតិយុត្តនៃកំណែទម្រង់គន្លឹះនានា និងកំណែទម្រង់តាមវិស័យនៅ មិនទាន់មានសង្គតិភាព ភាពប្រទាក់ក្រឡាគ្នា និងការគាំទ្រគ្នាទៅវិញទៅមកបានល្អនៅឡើយ។

– ការទទួលខុសត្រូវ និងភាពជាម្ចាស់ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក៏ចាំបាច់ត្រូវមានការពង្រឹងបន្ថែមទៀត។

– ការរៀបចំរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ចាំបាច់ត្រូវបន្តពង្រឹងការអនុវត្ត និងពិនិត្យមើលឡើងវិញឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងរបស់រដ្ឋបាលនីមួយៗ (ជាពិសេសស្ថានភាពប្រជាសាស្ត្រ ភូមិសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ច)។

– បញ្ហាកង្វះធនធានមនុស្សនៅថ្នាក់ក្រុង ស្រុក (ទាំងចំនួន និងជំនាញ) ដែលចាំបាច់ត្រូវមានការដោះស្រាយ ដើម្បីធានាឱ្យក្រុង ស្រុកអាចបំពេញមុខងារ និងធនធាននានាដែលបានផ្ទេរទៅឱ្យ។

– នៅមិនទាន់មានការផ្ទេរធនធានថវិកាសម្រាប់អនុវត្តមុខងារសំខាន់ៗមួយចំនួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក និងមិនទាន់មានការផ្ទេរទ្រព្យសម្បត្តិជាផ្លូវការភ្ជាប់នឹងមុខងារដែលបានផ្ទេរ ដែលចាំបាច់ត្រូវពន្លឿនការកំណត់ និងការផ្ទេរធនធានថវិកា និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលក្រុង ស្រុក។

– ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ក៏ចាំបាច់ត្រូវពង្រឹង កែលម្អ និងទំនើបកម្មនៃការផ្តល់សេវាឱ្យបានឆាប់ ព្រមទាំងរៀបចំការផ្តល់សេវាជាកញ្ចប់ ដើម្បីធានាដល់ការផ្តល់សេវាឱ្យកាន់តែសាមញ្ញ ងាយស្រួល និងឆាប់រហ័ស។

## ៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៦

កិច្ចការអាទិភាពសំខាន់ៗ ដែលត្រូវអនុវត្តសម្រាប់ឆ្នាំ២០២៦ មានដូចខាងក្រោម៖

១). ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់

២). ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

៣). ការពង្រឹងការពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

៤). ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា

៥). ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមក្រោមជាតិ

៦). ការកែលម្អ និងការពង្រឹងយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទង

៧). ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី២ នៃកជទី២

៨). ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្សុំជាមួយជអ៥ទី២

៩). ការរៀបចំស្ថាប័នថ្នាក់ជាតិសម្រាប់ការបង្កើតស្ថាប័នជាក់លាក់មួយនៅថ្នាក់ជាតិសម្រាប់ដឹកនាសម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ វាយតម្លៃ លើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១០). ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

១១). ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

១២). ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

១៣). ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលរាជធានី ខេត្ត

១៤). ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

១៥). ការពង្រឹងយន្តការគណនេយ្យភាពសង្គម

១៦). ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ

១៧). ការពង្រឹងយន្តការសម្រាប់ទទួល និងដោះស្រាយបណ្ដឹងតវ៉ា និងសំណើសំណូមពររបស់ប្រជាពលរដ្ឋ
១៨). ការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
១៩). ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ
២០). ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអ៊ីនធឺណិត
២១). ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
២២). ការរៀបចំ និងការពង្រឹងយន្តការសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
២៣). ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការស៊ីវិល (អង្គរដ្ឋបាល និងអង្គបច្ចេកទេស)
២៤). ការរៀបចំ និងដាក់ឱ្យអនុវត្តមុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
២៥). ការរៀបចំ និងដាក់ឱ្យអនុវត្តមុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត
២៦). ការរៀបចំនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រលងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌ និងមន្ត្រីផ្នែកលើ កិច្ចព្រមព្រៀងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
២៧). ការរៀបចំប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
២៨). ការសិក្សា វាយតម្លៃអំពីតម្រូវការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិ និងសេចក្ដីណែនាំនានាជាធរមាន
២៩). ការបង្កើតប្រព័ន្ធលើកទឹកចិត្តបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
៣០). ការរៀបចំសេចក្ដីណែនាំស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
៣១). ការរៀបចំសេចក្ដីណែនាំស្ដីពីការបង្កើតបរិយាកាសមេត្រីភាព និងលក្ខខណ្ឌអំណោយផលនៅកន្លែងបំពេញការងារ និងការអនុវត្តតួនាទី ភារកិច្ចរបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
៣២). ការរៀបចំនិងការពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
៣៣). ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
៣៤). ការពិនិត្យ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាជាកាតព្វកិច្ច
៣៥). ការរៀបចំក្របខ័ណ្ឌស្ដង់ដារសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
៣៦). ការរៀបចំអនុម័តកម្មវិធីសិក្សាស្របតាមក្របខ័ណ្ឌស្ដង់ដារសមត្ថភាព
៣៧). ការផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (កិច្ចការរដ្ឋបាល ផែនការ ការគ្រប់គ្រង ការតាមដាននិងវាយតម្លៃ និងជំនាញបច្ចេកទេស)
៣៨). ការរៀបចំសេចក្ដីណែនាំអំពីការវាយតម្លៃតម្រូវការបណ្ដុះបណ្ដាល ការធ្វើផែនការ និងការគ្រោងថវិកាសម្រាប់បណ្ដុះបណ្ដាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៣៩). ការអនុវត្តការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល ការរៀបចំផែនការ និងថវិកាសម្រាប់ការបណ្តុះបណ្តាលរបស់រដ្ឋបាលរាជធានី ខេត្ត
៤០). ការវាយតម្លៃអំពីប្រសិទ្ធភាពផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៤១). ការចងក្រង និងការចែករំលែកមេរៀនបទពិសោធន៍ក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការអនុវត្តមុខងារណាមួយដែលទទួលបានជោគជ័យ
៤២). ការរៀបចំសៀវភៅប្រតិបត្តិការការងារនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន
៤៣). ការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលសម្រាប់បុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋាន និងការរៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំ
៤៤). ការបណ្តុះបណ្តាលបុគ្គលិក និងគ្រូបង្គោលសាលាជាតិរដ្ឋបាលមូលដ្ឋាន
៤៥). ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន វិទ្យាស្ថានឯកទេសណាមួយក្នុងតំបន់ និងពិភពលោកដែលលក្ខណៈស្រដៀងគ្នា
៤៦). ការពង្រឹងសមត្ថភាពដល់ទីចាត់ការទទួលបន្ទុកអភិវឌ្ឍសមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្តដើម្បីផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
៤៧). ពង្រឹងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៤៨). ពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៤៩). ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០
៥០). ការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០)
៥១). ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៥២). ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ
៥៣). ការផ្ទេរចំណូលប្រភេទពន្ធថ្មីសម្រាប់ជាចំណូលជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៥៤). ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងរូបមន្តជាក់លាក់
៥៥). ការចែករំលែកចំណូលមិនមែនសារពើពន្ធពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមបណ្តាមន្ទីរជំនាញរាជធានី ខេត្តទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
៥៦). ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៥៧). ការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមមុខងារដែលបានផ្ទេរ
៥៨). ការផ្ទេរធនធានពីមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដោយផ្អែកទៅតាមរូបមន្តឱ្យទាន់ពេលវេលា

៥៩). ការផ្ទេរ និងការពង្រឹង ការគ្រប់គ្រង និងការចាត់ចែងការប្រើប្រាស់ធនធានមានភ្ជាប់លក្ខខណ្ឌ ដែលបានផ្ទេរភ្ជាប់នឹងមុខងារ

៦០). ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវមូលនិធិភាតរភាព

៦១). ការពង្រឹង និងការកែលម្អការរៀបចំ និងការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

៦២). ការពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៦៣). ការរៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងឯកជន

៦៤). ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

៦៥). ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

៦៦). ការធ្វើទំនើបកម្មនីតិវិធីផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៦៧). ការកែសម្រួលទំហំ ប្រភេទ និងការលម្អនីតិវិធីផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៦៨). ជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្តក្នុងការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល៥លានដុល្លារអាមេរិកចុះ

៦៩). ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយចីរភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៧០). ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

## ៦. សេចក្តីសន្និដ្ឋាន

ជារួម ឆ្នាំ២០២៥នេះ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដោយមានការចូលរួមគាំទ្រ និងអនុវត្តយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ កម្មវិធីកំណែទម្រង់នេះសម្រេចបាននូវសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ ការពង្រឹងការគ្រប់គ្រង និងការចាត់ចែងអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ការពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងការពង្រឹងការផ្តល់សេវាសាធារណៈ ព្រមទាំងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ។

តាមរយៈកម្មវិធីកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងជាបណ្តើរទៅជាស្ថាប័នដែលមានភាពរឹងមាំ មានសមត្ថភាព មានសិទ្ធិអំណាច មានមុខងារ និងធនធាន និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងរួមចំណែកសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។

ឆ្នាំ២០២៥នេះ គ.ជ.អ.ប. បានដឹកនាំ សម្របសម្រួលអនុវត្តមុខងារប្រមាណ ៦០ក្នុងវិស័យចំនួន ២០ ដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារផ្តល់សេវារដ្ឋបាលប្រមាណជាង ៨០០ ប្រភេទត្រូវដែលបានប្រគល់ និងធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ តាមយន្តការច្រកចេញចូលតែមួយ។ ឆ្នាំ២០២៥នេះ ពុំមានមុខងារថ្មីណាមួយបន្ថែមទៀតត្រូវបានផ្ទេរ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទេ។ ការផ្ទេរថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងពី ចំនួន**៦.៩៦៩.១៥៨ លានរៀល** ស្មើនឹង **១.៧០០លានដុល្លារ** ក្នុងឆ្នាំ២០២៤ និងកើនដល់ចំនួន **៧.១៩៣.៦៦៩ លានរៀល** ស្មើនឹង **១.៧៥៤ លានដុល្លារ** ក្នុងឆ្នាំ២០២៥។ នៅក្នុងក្របខ័ណ្ឌនៃការ អនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារជាជម្រើសរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និង ធ្វើការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គម ដើម្បីឆ្លើយតបទៅនឹង តម្រូវការជាក់ស្តែងនៅមូលដ្ឋាន ដែលជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាព រស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន។

ទន្ទឹមនឹងវឌ្ឍនភាព និងសមិទ្ធផលខាងលើនេះ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តផ្តោតការយកចិត្តទុកដាក់ និងបន្តដោះស្រាយនៅឆ្នាំ ២០២៦ ដើម្បីធានាថាសមិទ្ធផល លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាដែលបានកំណត់ ក្នុងកម្មវិធីជាតិ ដំណាក់កាលទី២ (២០២១-២០៣០)ត្រូវបានអនុវត្ត និងសម្រេចបានលទ្ធផលដោយ ជោគជ័យតាមការរំពឹងទុក ។

ថ្ងៃចន្ទ ១៤កើតខែផល្គុន ឆ្នាំម្សាញ់ សប្តស័កព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

# ឧបសម្ព័ន្ធទី១៖ ឧបសម្ព័ន្ធទី១៖ វឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពអាទិភាពចំនួន៨៧ ធៀបនឹងចំណុចដៅឆ្នាំ២០២៥

| **កូដ** | **សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពអាទិភាព** | **សូចនាករ** | **ឯកតា** | **ចំណុចដៅឆ្នាំ ២០២៥** | **លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥** | | |
|---|---|---|---|---|---|---|---|
| | | | | | **ប្រចាំឆ្នាំ** | **ស្ថានភាពអនុវត្ត (%)** | **វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥** |
| 1 | **ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖**<br>**យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | |
| 1.1 | **យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាបន្ន** | | | | | | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ | 1. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំប្រចាំឆ្នាំ | កិច្ចប្រជុំ | 2 | 1 | 50% | -គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំលើកទី២៤ នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥ ដែលមានសមាសភាពចូលរួមចំនួន ១៧៨នាក់ ស្ត្រីមានចំនួន១៨នាក់។ |
| | | 2. ចំនួនសរុបលិខិតបទដ្ឋាន/ឯកសារ ដែលបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប. | ឯកសារ | 5 | 5 | 100% | - លិខិតបទដ្ឋានចំនួន០៣ បានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប. លើកទី២៤ រួមមាន ៖ (១) ការអនុម័តកំណត់ហេតុកិច្ចប្រជុំលើកទី២៣ របស់ គ.ជ.អ.ប. (២) ការអនុម័តលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. (៣) ការអនុម័តលើផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ របស់ គ.ជ.អ.ប. (៤) របាយការណ៍លទ្ធផលរៀបចំវេទិការាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរាយការណ៍របស់ក្រសួងសេដ្ឋកិច្ច |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានា របស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព | 3. ចំនួនកិច្ចប្រជុំអនុគណៈកម្មាធិការ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 3 | 3 | 100% | - បានរៀបចំកិច្ចប្រជុំចំនួន០៣ រួមមាន ៖ (១) អនុគណៈកម្មាធិការមុខងារ និងធនធានប្រជុំអំពីវិធានការណ៍ដោះស្រាយបញ្ហាប្រឈម សំណើ សំណូមពរចំនួន៣០ (២) អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិប្រជុំអំពីវិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរចំនួន០៧ និង(៣) អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុអំពីវិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរចំនួន២១។ |
| 1.1.3 | ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 4. ចំនួនសរុបវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់បុគ្គលិក លេខាធិការដ្ឋាន គ.ជ.អ.ប. | វគ្គ | 5 | 8 | 160% | បានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋានចូលរួមសិក្ខាសាលា ទស្សនកិច្ចសិក្សា និងវគ្គបណ្តុះបណ្តាល ចំនួន៨វគ្គនៅប្រទេសនូវែលសឺឡង់ វៀតណាម ថៃ និងប្រទេសចិន។ |
| 1.1.4 | ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 5. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយក្រសួង ស្ថាប័ន | កិច្ចប្រជុំ | 48 | 48 | 100% | ក្រសួង ស្ថាប័នចំនួន២២ បានរៀបចំកិច្ចប្រជុំគ.ដ.វ.វ. របស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៥។ |
| | | 6. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាល ថ្នាក់រាជធានី ខេត្ត | កិច្ចប្រជុំ | 50 | 50 | 100% | រដ្ឋបាលរាជធានី ខេត្តចំនួន២៥បានរៀបចំកិច្ចប្រជុំ គ.ដ.វ.វ. របស់ខ្លួន ដើម្បីត្រួតពិនិត្យ និងបូកសរុបអំពីរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២៥។ |
| 1.1.5 | ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា | 7. ចំនួនកិច្ចប្រជុំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានាដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 3 | 75% | បានរៀបចំកិច្ចប្រជុំចំនួន៣ រួមមាន ៖ (១) កិច្ចប្រជុំប្រចាំឆ្នាំ២០២៥លើកិច្ចការកែទម្រង់គន្លឹះនៃរាជ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | ទង្វើនភាពសម្រេចបានឆ្នាំ២០២៥ |
| | | | | | | | រដ្ឋាភិបាល (យ.ស.ក.) (២) កិច្ចប្រជុំអន្តរកំណែទម្រង់របស់រាជរដ្ឋាភិបាលលើការរៀបចំយន្តការលើកកម្ពស់អភិបាលកិច្ចកំណែទម្រង់តាមក្រសួង ស្ថាប័ន និង ការរៀបចំឱ្យមានគោលការណ៍ណែនាំរួមមួយអំពីការរៀបចំ SOP សម្រាប់ការផ្តល់សេវារដ្ឋបាលនៅតាមក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣) កិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ។ |
| | | 8. ផែនការសកម្មភាពរួមប្រចាំឆ្នាំបានរៀបចំ | ផែនការ | 1 | 1 | 100% | បានរៀបចំផែនការសកម្មភាពរួមប្រចាំឆ្នាំរបស់កម្មវិធីកំណែទម្រង់គន្លឹះទាំង៥របស់រាជរដ្ឋាភិបាល។ |
| 1.1.7 | ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានាប្រកបដោយភាពស្ថាបនា | 9. ចំនួនកិច្ចប្រជុំ TWG-SNDD ដែលបានរៀបចំ | កិច្ចប្រជុំ | 1 | 1 | 100% | បានរៀបចំកិច្ចប្រជុំ TWG-SNDD លើកទី២១ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២៥។ |
| 1.1.8 | ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 10. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់រាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 300 | 300 | 100% | កិច្ចប្រជុំ គ.ក.ស.ក. បានអនុវត្តកិច្ចប្រជុំជាទៀងទាត់ប្រចាំខែទាំង២៥រាជធានី ខេត្ត។ |
| | | 11. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់ក្រុង ស្រុក ខណ្ឌដែលបានរៀបចំ | កិច្ចប្រជុំ | 2,496 | 2,496 | 100% | បានអនុវត្តកិច្ចប្រជុំជាទៀងទាត់សម្រាប់ក្រុង ស្រុក ខណ្ឌទាំង២០៨។ |
| **1.2** | **ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។** | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 1.2.1 | ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង | 12. យុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង ត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត | យុទ្ធសាស្ត្រ | 1 | 1 | 80% | -បាននិងកំពុងធ្វើបច្ចុប្បន្នភាពលើយុទ្ធសាស្ត្រស្តីពីប្រាស្រ័យទាក់ទងរបស់ គ.ជ.អ.ប. ដើម្បីធ្វើឱ្យប្រសើរឡើងនូវការលើកកម្ពស់ការយល់ដឹង និងការចូលរួមអនុវត្តនូវកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាពលរដ្ឋ។ |
| 1.2.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង | 13. ចំនួនសរុបវេទិកា ឬកម្មវិធីផ្សព្វផ្សាយអំពីចក្ខុវិស័យ គោលដៅ និងសមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំ | វេទិកា | 12 | 12 | 100% | បានផ្សព្វផ្សាយសរុបចំនួន១២វេទិកា រួមមាន៖ វេទិកា D&D ១លើក ផ្សព្វផ្សាយជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ២លើក ផ្សព្វផ្សាយជូនគណៈប្រតិភូធនាគារពិភពលោកប្រចាំអាស៊ីខាងកើត និងប៉ាស៊ីហ្វិកចំនួន១៦ប្រទេស ១លើក ផ្សព្វផ្សាយជូនគណៈប្រតិភូទីម័រខាងកើត១លើក ផ្សព្វផ្សាយជូនតំណាងស្ថានទូត និងដៃគូអភិវឌ្ឍន៍១លើក សិក្ខាសាលាផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល១លើក។ |
| | | 14. ចំនួនសរុបឯកសារព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្សព្វផ្សាយ | ឯកសារព័ត៌មាន | 5 | 5 | 100% | បានផ្សព្វផ្សាយឯកសារសំខាន់ៗចំនួន៥ រួមមាន៖ ១). របាយការណ៍វាយតម្លៃកម្មវិធីជាតិដំណាក់កាលទី១ ២). របាយការណ៍អង្កេតអភិបាលកិច្ច ៣).របាយការណ៍លទ្ធផលវេទិការវាងរាជរដ្ឋាភិបាល ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង ៤).ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| **1.3** | **កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 1.3.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. | 15. ផ.ស.ថ. ឆ្នាំ២០២៥ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ | 1 | អនុម័ត | 100% | ផ.ស.ថ. ឆ្នាំ២០២៥ ត្រូវបានអនុម័តនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៥។ |
| | | 16. ភាគរយសរុបសកម្មភាពអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២៥ ដែលសម្រេចបាន | ភាគរយ | 90% | 80% | 80% | សកម្មភាពអាទិភាពនៃផ.ស.ថ.ឆ្នាំ២០២៥មានចំនួន៨៧ សកម្មភាពដែលសម្រេចបានមានចំនួន៧០ ស្មើនឹង ៨០%។ |
| | | 17. ផ.ស.ថ. ឆ្នាំ២០២៦ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ | 1 | បញ្ចប់សេចក្ដីព្រាង | 90% | បានរៀបចំបញ្ចប់សេចក្ដីព្រាងផ.ស.ថ.២០២៦ ដោយបានប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មុននឹងដាក់ឆ្លងកិច្ចប្រជុំ គ.ជ.អ.ប. លើកទី២៥ នាអំឡុងខែមករា ឆ្នាំ២០២៦។ |
| | | 18. ចំនួនសរុបនៃសេចក្ដីសម្រេចរួមដែលបានរៀបចំ និងអនុម័តឆ្នាំ២០២៥ | សេចក្ដីសម្រេចរួម | 46 | 46 | 100% | ក្រសួង ស្ថាប័នចំនួន២២ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥បានរៀបចំ និងអនុម័តសេចក្ដីសម្រេចរួម។ |
| 1.3.3 | ការរៀបចំ និងដាក់បញ្ចូលនូវលទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាពនៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | 19. ចំនួនក្រសួង ស្ថាប័នបានបញ្ចូលសកម្មភាពនៃផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 23 | 23 | 100% | ក្រសួង ស្ថាប័នចំនួន២៣ បានបញ្ចូលសកម្មភាពផអ៥ទី១ ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។ |
| | | 20. ចំនួនរដ្ឋបាលរាជធានី ខេត្តបានបញ្ចូលសកម្មភាពនៃផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 25 | 25 | 100% | រដ្ឋបាលរាជធានី ខេត្តទាំង២៥ បានបញ្ចូលសកម្មភាពផអ៥ទី១ ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។ |
| 1.3.5 | | 21. ការអង្កេតអភិបាលកិច្ច | ការអង្កេត | 1 | 1 | 100% | របាយការណ៍ស្ដីពីការអង្កេតអភិបាលកិច្ចបានអនុម័តនៅថ្ងៃ២១ ខែឧសភា ឆ្នាំ២០២៥។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២ | 22. ការវាយតម្លៃលើការអនុវត្តផអ៥ទី១ | ការវាយតម្លៃ | 1 | 1 | 100% | បានការវាយតម្លៃលើការអនុវត្តផអ៥ទី១។ |
| | | 23. សវនកម្មយេនឌ័រ | ការអង្កេត | 1 | 0 | 0% | មិនទាន់អនុវត្ត |
| | | 24. គម្រោង/កម្មវិធីស្ថិតក្រោមការគ្រប់គ្រងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានធ្វើសវនកម្មជាទៀងទាត់ផ្អែកតាមផែនការសវនកម្ម | ចំនួនគម្រោង | 2 | 2 | 100% | គម្រោង/កម្មវិធី ដែលបានធ្វើសវកម្មរួមមាន ៖<br>១.គម្រោងអាហារូបត្ថម្ភនៅកម្ពុជា៖បានធ្វើសវនកម្ម០៥ខេត្តក្នុងចំណោម៩ខេត្ត (កំពង់ឆ្នាំង ពោធិ៍សាត់ ក្រចេះ មណ្ឌលគិរី និងស្ទឹងត្រែង)<br>២.គម្រោងគណនេយ្យភាពសង្គម៖បានធ្វើសវនកម្ម០៤ខេត្ត(បាត់ដំបង ប៉ៃលិន ព្រះវិហារ កំពង់ស្ពឺ) |
| | | 25. ការសិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធគ្រប់គ្រង ទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA-MIS) | របាយការណ៍ | 1 | អនុម័ត | 100% | របាយការណ៍បានអនុម័តនៅខែមេសា ឆ្នាំ២០២៥។ បច្ចុប្បន បាន និងកំពុងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA/MIS) កម្ពុជា។ |
| **1.5** | **ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់** | | | | | | |
| 1.5.1 | ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 26. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 3 | 75% | បានពិនិត្យ និងអនុម័តផែនការសកម្មភាព ការរៀបចំសេចក្តីសម្រេចរបស់គណៈកម្មការបច្ចេកទេសទាំងបីរបស់សមាគម និងការកៀគរថវិកាសម្រាប់ការសាងសង់អគារស្នាក់ការសមាគម។ |
| | | 27. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 9 | 225% | កិច្ចប្រជុំថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ និងថ្នាក់ដឹកនាំសមាគមតាមរាជធានី ខេត្ត បានពិនិត្យ និងពិគ្រោះយោបល់ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | | | | | | -ការរៀបចំរចនាសម្ព័ន្ធអង្គអភិបាលកិច្ចរបស់សមាគម និងសម្ព័ន្ធភាពជាតិ<br>-រៀបចំមហាសន្និបាតរបស់សមាគមនិងសម្ព័ន្ធភាពជាតិ<br>-កែសម្រួលលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិ<br>-ពិនិត្យ កែសម្រួលផែនការយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពជាតិ |
| | | 28. ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ផែនការ | 1 | 1 | 100% | ផែនការយុទ្ធសាស្ត្របានអនុម័ត ផែនការយុទ្ធសាស្ត្ររបស់សមាគមក្រុមប្រឹក្សារាជធានី ខេត្ត អនុម័តនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥ និងផែនការយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពជាតិត្រូវបានអនុម័ត នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ។ |
| | | 29. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សមាជិកសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត | វគ្គ | 5 | 2 | 40% | រៀបចំសិក្ខាសាលាចំនួន២លើក ស្តីពីការបង្ហាញឧបករណ៍វាយតម្លៃរបស់ដៃគូត្រៀមបង្ការអាស៊ី (APP)ជាមួយការតម្រង់ទិសសម្រាប់អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់អាជ្ញាធរមូលដ្ឋានឈានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។ សិក្ខាសាលាត្រូវបានចូលរួមដោយ ប្រធានក្រុមប្រឹក្សារាជធានី ខេត្តទាំង២៥ ថ្នាក់ដឹកនាំសមាគមជាតិ និងសម្ព័ន្ធភាពជាតិ និងក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់នៃខេត្តគោល ដៅគម្រោងសរុបចំនួន១១០នាក់។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | 30. ចំនួនសរុបនៃវគ្គបណ្ដុះបណ្ដាលដែលបានរៀបចំសម្រាប់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | វគ្គ | 5 | 5 | 100% | - វគ្គបណ្ដុះបណ្ដាលតម្រង់ទិសដល់សមាជិកក្រុមប្រឹក្សានៃសង្កាត់ ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ សរុបចំនួន៣៥នាក់ ស្ត្រី១៤នាក់ ពីការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងការកសាងផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលសង្កាត់<br>- រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការទប់ស្កាត់ និងបង្ការការបៀតបៀនផ្លូវភេទនៅកន្លែងការងារដល់ស្រុកទាំង៧ (ស្រុកទឹកផុស ឈូក ជុំគិរី ជីក្រែង ស៊ីធរកណ្ដាល រវៀង និងត្បែងមានជ័យ)។ អ្នកចូលរួមសរុបចំនួន ៦០នាក់ (ស្ត្រី២៧នាក់)គោលបំណងនៃការបណ្ដុះបណ្ដាលស្ដីពីការទប់ស្កាត់ និងបង្ការការបៀតបៀនផ្លូវភេទនៅកន្លែងការងារ។ |
| 2 | **រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖**<br>**រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្ដល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ** | | | | | | |
| **2.1** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ** | | | | | | |
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក | 31. ភាគរយសរុបនៃក្រុង ស្រុក ដែលទទួលការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | ភាគរយ | 20% | 15% | 75% | -ក្រសួង ស្ថាប័នផ្ទេរមុខងារមួយចំនួនបានផ្ដល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព និងការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុករួមមាន ៖ ក្រសួងអប់រំ ក្រសួងបរិស្ថាន |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | | | | | | ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងមហាផ្ទៃ និង ក្រសួងសាធារណការនិងដឹកជញ្ជូន។ |
| | | 32. ភាគរយសរុបនៃមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដែលមានសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្ត | ភាគរយ | 70% | 60% | 86% | សេចក្តីណែនាំបច្ចេកទេសចំនួន០៦លើវិស័យវប្បធម៌ កសិកម្ម សាធារណការនិងដឹកជញ្ជូន រ៉ែនិងថាមពល ទេសចរណ៍ និងវិស័យឧស្សាហកម្ម។ |
| | | 33. ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុកទូទាំងប្រទេស | កិច្ចប្រជុំ | 2,352 | 2,156 | 92% | ក្រុង ស្រុកចំនួន១៩៦បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ។ |
| | | 34. ភាគរយនៃរដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៦-២០២៨) | ឯកសារ | 100% | 100% | 100% | ក្រុង ស្រុកបានដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលបញ្ចប់ជំហានទី១ និងរដ្ឋបាលក្រុង ស្រុកទាំង៧១ នៅមិនទាន់បានចាប់ផ្តើមរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលជំហានទី២និងជំហានទី៣នៅឡើយ។ |
| | | 35. ការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល | របាយការណ៍ | 1 | ការសិក្សា | 50% | បាន និងកំពុងពិនិត្យ កែសម្រួលលើឯកសារទស្សនទានស្តីពីការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យលេខ១៩៣ និងការសិក្សាលទ្ធភាពស្តីពីការផ្ទេរមុខងារសុខាភិបាលពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ |
| 2.1.2 | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់ | 36. ភាគរយឃុំ សង្កាត់ដែលទទួលបានការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ | ភាគរយ | 5% | 3% | 60% | ឃុំ សង្កាត់ទទួលបានការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំទៅលើការផ្ទេរមុខងារ។ |
| | | 37. ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស | កិច្ចប្រជុំ | 19,836 | 18,172 | 92% | ក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសបានរៀបចំកិច្ចប្រជុំជាប្រចាំខែ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | 38. ភាគរយនៃរដ្ឋបាលឃុំ សង្កាត់ដែលបានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល | ឯកសារ | 100% | 100% | 100% | បានដំណើរការរៀបចំនិងកសាងកម្មវិធីវិនិ-យោគបីឆ្នាំរំកិលបញ្ចប់ជំហានទី១ និងឃុំ សង្កាត់ចំនួន ១.៦៥២ នៅមិនទាន់បានចាប់ផ្តើមជំហានទី២ និងជំហានទី៣ នៅឡើយ។ |
| | | 39. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្របច្ចេកទេសដោយរាជធានី ខេត្តក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | រដ្ឋបាលរាជធានី ខេត្តបានផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ទាំងអស់ទៅលើការអនុវត្តមុខងារ។ |
| 2.1.3 | ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន | 40. ការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | លិខិតបទដ្ឋាន | 1 | សេចក្តីព្រាងឯកសារទស្សនទាន | 60% | បាននិងកំពុងរៀបចំសេចក្តីព្រាងបឋមឯកសារទស្សនទានស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យនៃការរៀបចំក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន។ |
| | | 41. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | របាយការណ៍ | 1 | ការសិក្សា | 30% | -បានបញ្ចប់សេចក្តីព្រាងបឋមឯកសារទស្សនាទានស្តីពីការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន។<br>បាននិងកំពុងរៀបចំសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន។ |
| 2.1.4 | ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំស្ថិតនៅក្នុងតំបន់ជនបទ | 42. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ | របាយការណ៍ | 1 | ការសិក្សា | 30% | បាននិងកំពុងរៀបចំសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ជនបទ ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| **2.2** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | | | | | | |
| 2.2.1 | ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្ត | 43. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរបស់រដ្ឋបាលខេត្តត្រូវបានរៀបចំ | របាយការណ៍ | 1 | កំពុងសិក្សា ប្រមូលចងក្រង | 40% | បាននិងកំពុងសិក្សា និងប្រមូលចងក្រងឯកសារ និងបទដ្ឋានគតិយុត្តនៃបណ្តាប្រទេសមួយចំនួនរួមមាន ប្រទេសវៀតណាម ឥណ្ឌូនេស៊ី ថៃ ហ្វីលីពីន កូរ៉េខាងត្បូង។ |
| 2.3.1 | ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី | 44. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរដ្ឋបាលរាជធានីត្រូវបានរៀបចំ | របាយការណ៍ | 1 | កំពុងសិក្សា ប្រមូលចងក្រង | 40% | បាននិងកំពុងសិក្សា និងប្រមូលចងក្រងឯកសារ និងបទដ្ឋានគតិយុត្តនៃបណ្តាប្រទេសមួយចំនួនរួមមាន ប្រទេសវៀតណាម ឥណ្ឌូនេស៊ី ថៃ ហ្វីលីពីន កូរ៉េខាងត្បូង។ |
| **2.4** | **ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | |
| 2.4.3 | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | 45. ចំនួនសរុបនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ដែលបានរៀបចំដោយរដ្ឋបាលរាជធានី ខេត្ត | វេទិកា | 25 | 25 | 100% | រាជធានី ខេត្ត បានរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋ ដើម្បីដោះស្រាយបញ្ហា សំណើសំណូមពររបស់ប្រជាពលរដ្ឋ។ |
| | | 46. ចំនួនសរុបនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ដែលបានរៀបចំដោយរដ្ឋបាលក្រុង ស្រុក | វេទិកា | 210 | 210 | 100% | រដ្ឋបាលក្រុង ស្រុក បានរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋ ដើម្បីដោះស្រាយបញ្ហា សំណើសំណូមពររបស់ប្រជាពលរដ្ឋ។ |
| **2.6** | **ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 2.6.1 | ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | 47. ការសិក្សា និងការរៀបចំឯកសារយុទ្ធសាស្ត្រស្តីពីនិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមត្រូវបានពិនិត្យ និងអនុម័ត | ឯកសារយុទ្ធសាស្ត្រ | 1 | 1 | 50% | បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីនិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | 48. ភាគរយសរុបនៃឃុំ សង្កាត់ដែលអនុវត្តការងារគណនេយ្យភាពសង្គម | ភាគរយ | 100% | 94% | 94% | បានគ្របដណ្តប់ការអនុវត្តការងារគណនេយ្យភាពសង្គម នៅក្នុងរដ្ឋបាលឃុំ សង្កាត់ចំនួន១.៥៥០ នៃឃុំ សង្កាត់សរុបចំនួន១.៦៥២។ |
| | | 49. ការសិក្សា និងរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ត្រូវបានរៀបចំ | ផែនការយុទ្ធសាស្ត្រ | 1 | 20% | 20% | បានរៀបចំលក្ខខណ្ឌការងារក្នុងការជ្រើសរើសទីប្រឹក្សាបច្ចេកទេសក្នុងការរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣។ |
| | | 50. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌលើសេវាតាមការិយាល័យច្រកចេញចូលតែមួយ | ភាគរយ | 23% | 26% | 113% | បានគ្របដណ្តប់ការអនុវត្តការងារគណនេយ្យភាពសង្គម នៅថ្នាក់ក្រុង ស្រុក ខណ្ឌ នៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន២៦ នៃក្រុង ស្រុក ខណ្ឌសរុបចំនួន២១០។ |
| 2.6.2 | ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | 51. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះ សម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | បណ្តឹង | 93% | 63% | 63% | ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត បានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន ១.០២២ករណី ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន ១៨០ករណី (បញ្ចប់ការដោះស្រាយចំនួន ១១៣ករណី និងកំពុងដោះស្រាយចំនួន ៦៧ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន ៩៣ករណី និងព័ត៌មានផ្សេងៗចំនួន ៧៤៩ករណី (ការសរសើរចំនួន ១០០ករណី សំណើនិងសំណូមពរចំនួន ២៣១ករណី និងការសាកសួរព័ត៌មានចំនួន ៤១៨ករណី)។ |
| | | 52. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះ សម្រួលដោះស្រាយ | បណ្តឹង | 93% | 83% | 83% | ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន ២៤.៦៩៤ករណី។ ចំពោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន |

| **កូដ** | **សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព** | **សូចនាករ** | **ឯកតា** | **ចំណុចដៅឆ្នាំ ២០២៥** | **លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥** | | |
|---|---|---|---|---|---|---|---|
| | | | | | **ប្រចាំឆ្នាំ** | **ស្ថានភាពអនុវត្ត (%)** | **វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥** |
| | | ដោយការិយាល័យប្រជាពលរដ្ឋ ក្រុង ស្រុក ខណ្ឌ | | | | | ១៩៩ករណី (បញ្ចប់ការដោះស្រាយចំនួន ១៦៥ករណី និងកំពុងដោះស្រាយចំនួន ៣៤ករណី បណ្ដឹងក្រៅសមត្ថកិច្ចចំនួន ១០៦ករណី ព័ត៌មានផ្សេងៗសរុបចំនួន ២៤.៣៨៩ករណី)។ |
| 2.6.3 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ | 53. ចំនួនកិច្ចប្រជុំរវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយនឹងអង្គការសង្គមស៊ីវិល | កិច្ចប្រជុំ | 50 | 36 | 72% | រដ្ឋបាលរាជធានីខេត្តបានប្រជុំជាមួយអង្គការសង្គមស៊ីវិលចំនួន៧ខេត្តរួមមាន ៖ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តពោធិ៍សាត់ ខេត្តស្ទឹងត្រែង ខេត្តកោះកុង និងខេត្តកែប ចំនួន១១ដងមានអ្នកចូលរួមសរុបចំនួន ៥៤៣នាក់ ស្ត្រី ១៣៣នាក់។ |
| **2.7** | **ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល** | | | | | | |
| 2.7.1 | ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត | 54. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបានតំណភ្ជាប់សេវាអ៊ីនធឺណិត | ភាគរយ | 60% | 84% | 140% | រដ្ឋបាលថ្នាក់ក្រោមជាតិបានតភ្ជាប់សេវាអ៊ីធឺណែតរួមមាន រដ្ឋបាលរាជធានី ខេត្តចំនួន២៥ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន១៧៨ និងរដ្ឋបាលឃុំ សង្កាត់ចំនួន ១.១១៣។ |
| 2.7.2 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 55. ប្រព័ន្ធទិន្នន័យនានារបស់ គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល (SA M&E Database,...) | ប្រព័ន្ធ | 5 | 5 | 100% | បានរៀបចំ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យចំនួន៤ រួមមាន ៖ (១) ប្រព័ន្ធទិន្នន័យរៀបចំរបាយការណ៍ (NAD) (២) ប្រព័ន្ធទិន្នន័យត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម (៣) ប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិក និង(៤)ប្រព័ន្ធទិន្នន័យភូមិសាស្ត្រ។ |
| 2.7.3 | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 56. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់គេហទំព័រ | ភាគរយ | 100% | 98% | 98% | រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់គេហទំព័រ បណ្តាញសង្គមជាផ្លូវការដើម្បីផ្សព្វផ្សាយព័ត៌មាន និងទទួលព័ត៌មានរួមមាន៖ រដ្ឋបាលរាជធានី ខេត្តចំនួន២២ រដ្ឋបាលក្រុង |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | បណ្តាញសង្គម និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ ដើម្បីផ្សព្វផ្សាយ និងទទួលព័ត៌មានពាក់ព័ន្ធនានា | | | | | ស្រុក ខណ្ឌចំនួន១៨២ និងរដ្ឋបាលឃុំ សង្កាត់ចំនួន ៩៥០។ |
| **2.8** | **ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | |
| 2.8.1 | ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 57. ការសិក្សា និងការរៀបចំបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | លិខិតបទដ្ឋាន | 1 | បញ្ចប់របាយការណ៍សិក្សា | 50% | លទ្ធផលដូចជា ៖<br>• បានបង្កើតក្រុមការងារអន្តរក្រសួង<br>• បានរៀបចំបញ្ជីសំណួរ<br>• បានចុះសិក្សានៅរាជធានី និងខេត្តចំនួន០៤ (រាជធានីភ្នំពេញ សៀមរាប ស្ទឹងត្រែង កំពង់ស្ពឺ និងព្រះសីហនុ<br>• កំពុងរៀបចំសេចក្តីព្រាងរបាយការណ៍បឋម |
| | | 58. បែបបទ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង/ សវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំ | សៀវភៅណែនាំ | 1 | មិនទាន់អនុវត្ត | 0% | លើកទៅឆ្នាំ២០២៦ |
| | | 59. បែបបទ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង/ សវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ | សៀវភៅណែនាំ | 1 | 1 | 50% | បន្តរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៅរដ្ឋបាលក្រុង ស្រុក ។ |
| | | 60. ភាគរយរដ្ឋបាលក្រុង ស្រុកដែលបានអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង ឬសវនកម្មផ្ទៃក្នុង | ភាគរយ | 50% | 50% | 50% | បានចុះគាំទ្រដល់ក្រុង ស្រុកក្នុងការអនុវត្តត្រួតពិនិត្យផ្ទៃក្នុង ឬសវនកម្មផ្ទៃក្នុងចំនួន៥ខេត្តរួមមាន ៖ រាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តស្ទឹងត្រែង។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 3 | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ** | | | | | | |
| **3.1** | **អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.1.1 | ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ | 61. អង្គរដ្ឋបាល និងអង្គបច្ចេកទេសត្រូវបានរៀបចំ | លិខិតបទដ្ឋាន | 1 | កំពុងសិក្សា | 30% | -ក្រសួងមុខងារសាធារណៈបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការកែលម្អ និងបំពេញបន្ថែមនូវចំណុចខ្វះខាត ព្រមទាំងប្រមូលធាតុចូល ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គសុខាភិបាលឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ អ្នកចូលរួមសរុប២៥០នាក់។ |
| **3.3** | **ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.3.1 | ការរៀបចំការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 62. ភាគរយនៃរដ្ឋបាលក្រុង ស្រុក បានរៀបចំ និងអនុវត្តនូវការពិពណ៌នាអំពីមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ | ភាគរយ | 100% | សេចក្តីព្រាង | 80% | -បាន និងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីមុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រៀមរៀបចំការបណ្តុះបណ្តាលដល់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស។ |
| 3.3.2 | ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 63. ភាគរយនៃរដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិក | ភាគរយ | 100% | 100% | 100% | -បានដាក់ចេញនូវអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ (ថ្ងៃទី៦ ខែមករា ឆ្នាំ២០២៥) និងនិយាមនីតិវិធីប្រតិបត្តិនៃការតែងតាំង ការផ្លាស់ប្តូរ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | | | | | | និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។ |
| 3.3.5 | ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ | 64. ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ត្រូវបានរៀបចំ និងអនុម័ត | លិខិត បទដ្ឋាន | | សេចក្តីព្រាង អនុក្រឹត្យ | 50% | បានបន្តរៀបចំអនុក្រឹត្យស្តីពីប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដើម្បីកំណត់អំពីគោលការណ៍ យន្តការ និងនីតិវិធីនៃការស្នើសុំ ការអនុម័ត និងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាព និងសមិទ្ធផលការងារ នៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| **3.4** | **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.4.1 | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ | 65. ការសិក្សា និងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិត បទដ្ឋាន | 1 | សិក្សា | 90% | -ក្រសួងមុខងារសាធារណៈបាន និងសិក្សារៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការចូលនិវត្តន៍។ |
| **3.5** | **តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់** | | | | | | |
| 3.5.1 | ការរៀបចំ និងការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ | 66. ភាគរយរដ្ឋបាលក្រុង ស្រុក ដែលបានវាយតម្លៃតម្រូវការធនធានមនុស្សរបស់ខ្លួន | ភាគរយ | 100% | 90% | 90% | បានរៀបចំបញ្ចប់សៀវភៅណែនាំស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការរៀបចំការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 3.5.2 | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 67. ភាគរយរដ្ឋបាលថ្នាក់រាជធានី ខេត្ត បានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | 100% | 100% | 100% | មន្ត្រីបុគ្គលិករដ្ឋបាលរាជធានី ខេត្តមានចំនួន ២៦.៤០៨នាក់ ស្ត្រី ១៤.០៨៧នាក់ (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន ២.៨២៨នាក់ ស្ត្រីចំនួន ៩១៩នាក់ និងគ្រូពេទ្យមានចំនួន ២៣.៥៧៦នាក់ ស្ត្រីចំនួន ១៣.១៦៨នាក់)។ |
| | | 68. ភាគរយរដ្ឋបាលថ្នាក់ក្រុង ស្រុក បានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | 100% | 100% | 100% | មន្ត្រីបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន ៧៤.២៦១នាក់ ស្ត្រីចំនួន ៣៨.៦៩៨នាក់ (មន្ត្រីបុគ្គលិករដ្ឋបាលនិងបុគ្គលិកជំនាញបច្ចេកទេសចំនួន ១០.៨៨៧នាក់ ស្ត្រីចំនួន ៣.១៣១នាក់ និងគ្រូបង្រៀនចំនួន ៦៣.៣៧៤នាក់ ស្ត្រី ៣៥.៥៦៧នាក់)។ |
| **3.6** | **គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.6.1 | ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 69. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | 1 | សិក្សា | 50% | បាន និងកំពុងរៀបចំការសិក្សា កម្មវិធីលើកទឹកចិត្ត គាំទ្រសមិទ្ធកម្មសម្រាប់អង្គភាព និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅតំបន់ជួបការលំបាក។ |
| 3.6.2 | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 70. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត | ភាគរយ | 34.5% | 28.20% | 81.70% | មន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត (អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន៦០១ នាក់ ស្មើនឹង ២៨,២០% ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | 71. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | ភាគរយ | 23% | 24.87% | 108% | រដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន១.៩៥១ នាក់ ស្មើនឹង ២៤,៨៧%។ |
| **3.7** | **ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់** | | | | | | |
| 3.7.1 | ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 72. សេចក្តីណែនាំស្តីពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពត្រូវបានពិនិត្យ និងកែសម្រួល | សេចក្តីណែនាំ | 1 | 0 | 0% | មិនទាន់អនុវត្ត |
| 3.7.2 | ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | 73. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | វគ្គ | 1 | កំពុងរៀបចំឯកសារ | 60% | បាន និងបន្តរៀបចំឯកសារបណ្តុះបណ្តាលដើម្បីអាចរៀបចំវគ្គបណ្តុះបណ្តាលអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តនៅដើមឆ្នាំ២០២៦។ |
| 3.7.3 | ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 74. របាយការណ៍វាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | 1 | កំពុងរៀបចំបូកសរុបរបាយការណ៍ | 80% | បាននិងកំពុងបូកសរុបរបាយការណ៍ពាក់ព័ន្ធតម្រូវការសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| 3.7.4 | ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព | 75. ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | 100% | 100% | 100% | រដ្ឋបាលរាជធានី ខេត្តចំនួន២៥ បានរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០២៥ ដល់បុគ្គលិករបស់ខ្លួន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | 76. ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | 90% | 90% | 90% | រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន២០៨ បានរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០២៥ ដល់បុគ្គលិករបស់ខ្លួន និងរដ្ឋបាលឃុំ សង្កាត់។ |
| | | 77. ភាគរយនៃសកម្មភាពអភិវឌ្ឍសមត្ថភាពដែលបានគ្រោងក្នុងផែនការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត | ភាគរយ | 70% | 50% | 71% | រដ្ឋបាលរាជធានី ខេត្តមួយចំនួនបានសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលនយោបាយ បទដ្ឋានបច្ចេកទេសពាក់ព័ន្ធនានាដល់មន្ត្រីបុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់សរុបចំនួន ៥៤៤វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤៥.១៦៣នាក់ ស្ត្រី ១៤.៨៦៧នាក់ ដោយផ្តោតលើប្រធានបទសំខាន់ៗដូចជា ៖ ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធ៌មសង្គម ភាពជាអ្នកដឹកនាំ និងជំនាញសម្របសម្រួល ការពង្រឹងតួនាទីរបស់ គ.ក.ស.ក. និង គ.ក.ន.ក ។ល។ |
| **3.8** | **ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.8.1 | ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន | 78. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់គ្រូបណ្តុះបណ្តាល និងបុគ្គលិករបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | វគ្គ | 4 | 4 | 100% | --បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលសាលាជាតិរដ្ឋបាលមូលដ្ឋានស្តីពីវិធីសាស្ត្រលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន<br>-បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន៣វគ្គរួមមាន (១)ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និង |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | | | | | | ផែនការថវិកាប្រចាំឆ្នាំ (២)ពិធីការការទូត និងបដិសណ្ឋារកិច្ច និង(៣)ប្រព័ន្ធតាមដានការអនុវត្តគម្រោង ការវាយតម្លៃការបណ្តុះបណ្តាល ការរៀបចំផែនការ និងការគ្រប់គ្រងផ្អែកលើលទ្ធផល។ |
| 3.8.2 | កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល | 79. ចំនួនសរុបនៃគ្រឹះស្ថានបានចុះអនុស្សរណៈជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន ស្តីពីកិច្ចសហការក្នុងការរៀបចំកម្មវិធីសិក្សា និងសម្ភារៈបណ្តុះបណ្តាល | ស្ថាប័ន | 4 | 4 | 100% | -បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-បានចុះលិខិតព្រមព្រៀង (Letter of Agreement) ជាមួយ UNDP ដើម្បីអនុវត្តគម្រោងមូលដ្ឋាននីយកម្ម SDGs សម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព (The implementation of Localization of SDGs for Efficient Public Service Delivery Project)។ |
| 3.8.3 | ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ | 80. ចំនួនសិក្ខាកាមទទួលបានការបណ្តុះបណ្តាលពីសាលាជាតិរដ្ឋបាលមូលដ្ឋាន | នាក់ | 1,200 | 3,621 | 302% | -សិក្ខាកាមជាមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិចំនួន៥៨២នាក់<br>-សិក្ខាកាមជាមន្ត្រីរាជការនៅទីស្តីការក្រសួងចំនួន១១៧នាក់ |
| **3.9** | **កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.9.2 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា | 81. លិខិតបទដ្ឋានស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | សេចក្តីព្រាង | 80% | -សាលាជាតិរដ្ឋបាលមូលដ្ឋាន បាននិងកំពុងរៀបចំកម្មវិធីសិក្សាចំនួន៦ដូចជាកម្មវិធីសិក្សារយៈពេលវែង កម្មវិធីសិក្សារយៈពេលខ្លីសម្រាប់សាធារណជន កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | | | | | | ដែលកិច្ចការទាំងនេះសម្រេចបានវឌ្ឍនភាពពី៧០%ទៅ ៨០%។<br>-សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំ និងឬ កែសម្រួលកម្មវិធីសិក្សាចំនួន៥សម្រាប់ក្រុមគោលដៅ ជាមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ ធនធាន មនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធដទៃ ទៀត។ |
| 3.9.3 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើ បច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះប ណ្តាលសម្រាប់កម្មវិធីសិក្សានានា (ស្រង់ពីផែនការយុទ្ធសាស្ត្ររបស់ក្រសួង មហាផ្ទៃ) | 82. ចំនួនសៀវភៅគោលត្រូវបាន រៀបចំ | ក្បាល | 4 | 5 | 125% | បាននិងកំពុងរៀបចំសៀវភៅគោលចំនួន៥ប្រធានបទរួម មាន(១)ការគ្រប់គ្រងមុខងារសុខាភិបាលនៅ រដ្ឋបាល រាជធានី ខេត្ត (២)ការធ្វើបទបង្ហាញប្រកប ដោយ ប្រសិទ្ធភាព (៣)ការងារពិធីការ (៤)ការអភិវឌ្ឍសេដ្ឋ កិច្ចមូលដ្ឋាន និង(៥)ក្រមសីលធម៌មន្ត្រីរាជការស៊ីវិលក្នុង ក្របខ័ណ្ឌក្រសួងមហាផ្ទៃ។ |
| **3.10** | **វិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.10.1 | ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រ ផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា | 83. សេចក្តីណែនាំស្តីពីវិធីសាស្ត្រ សម្រាប់ការបណ្តុះបណ្តាលត្រូវ បានរៀបចំ | សេចក្តី ណែនាំ | 1 | 0 | 0% | គ្រោងអនុវត្តនៅឆ្នាំ២០២៦។ |
| | | 84. ចំនួនវិធីសាស្ត្រនៃការបណ្តុះប ណ្តាលត្រូវបានរៀបចំ និងដាក់ឱ្យ អនុវត្ត | ប្រភេទ | 3 | 4 | 133% | -ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ<br>-ការបណ្តុះបណ្តាលតាមប្រព័ន្ធ E-Learning<br>-ការបញ្ជ្រាបករណីសិក្សាទៅក្នុងការបណ្តុះបណ្តាល<br>-ការចុះសិក្សាស្រាវជ្រាវលើប្រធានបទណាមួយ និងធ្វើ បទបង្ហាញនៅក្នុងថ្នាក់រៀន។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 3.10.2 | ការលើកទឹកចិត្តដល់ស្វ័យសិក្សា និងស្រាវជ្រាវដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសិក្សា | 85. ចំនួនប្រភេទនៃការរៀបចំបរិស្ថានសម្រាប់ស្វ័យសិក្សារបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | ប្រភេទ | 2 | 1 | 50% | -បានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងការរៀនសូត្រតាមប្រព័ន្ធអនឡាញ (E-Learning) សម្រាប់ក្រុមគោលដៅជាក្រុមប្រឹក្សា ក្រុង ស្រុក។ |
| 4 | **ទិមដ្ឋការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ÷ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។** | | | | | | |
| **4.1** | **កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សុីគ្នា ដោយផ្អែកលើចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** | | | | | | |
| 4.1.1 | ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 86. ភាគរយគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រទៅលើកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន | ភាគរយ | 100% | 100% | 100% | សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២៦-២០២៨ ត្រូវបានពិនិត្យ ពិភាក្សា និងមានឯកភាពដោយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួងសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។។ |
| 4.1.3 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 87. ប្រព័ន្ធទិន្នន័យស្តីពីព័ត៌មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល (SPD) | ទិន្នន័យ | 1 | 1 | 100% | បាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យព័ត៌មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល (SPD) ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យអនឡាញ ព្រមទាំងបានប្រមូល ផលិត និងចែករំលែកព័ត៌មានជាសាធារណៈអំពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។ |
| | | 88. ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ត្រូវបានប្រមូល ផលិត និងចែករំលែក | ទិន្នន័យ | 1 | 1 | 100% | លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យអនឡាញ ព្រមទាំង |

| **កូដ** | **សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព** | **សូចនាករ** | **ឯកតា** | **ចំណុចដៅឆ្នាំ ២០២៥** | **លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥** | | |
|---|---|---|---|---|---|---|---|
| | | | | | **ប្រចាំឆ្នាំ** | **ស្ថានភាព អនុវត្ត (%)** | **វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥** |
| | | | | | | | បានប្រមូល ផលិត និងចែករំលែកព័ត៌មានជាសាធារណៈ អំពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។ |
| **4.2** | **ការអនុវត្តមុខងារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្ដល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) | 89. ចំនួនរដ្ឋបាលរាជធានី ខេត្ត ដែលបានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | រាជធានី ខេត្ត | 25 | 25 | 100% | រដ្ឋបាលរាជធានី ខេត្តចំនួន២៥បានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ |
| | | 90. កម្រិតទឹកប្រាក់នៃសិទ្ធិសម្រេចអំពីកិច្ចលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ | ទំហំទឹកប្រាក់ | កើនឡើងធៀបឆ្នាំ ២០២៣ | កើនឡើង ធៀបនឹងឆ្នាំ ២០២៤ | ថេរមិនកើន | កម្រិតទឹកប្រាក់នៃសិទ្ធិសម្រេចអំពីកិច្ចលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិនៅថេរគ្រប់កម្រិត។ |
| **4.4** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | |
| 4.4.1 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា | 91. ភាគរយនៃការទូទាត់តាមប្រព័ន្ធឌីជីថល (Payment Hub) សម្រាប់អង្គភាពប្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | ភាគរយ | សេវាចំនួន៣០% បានអនុវត្ត | 100% | 100% | បានអនុវត្តការបង់កម្រៃសេវាតាមប្រព័ន្ធ Payment នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទូទាំងប្រទេសដោយធៀបនឹងចំណូលសរុបដែលបានទូទាត់។ |
| **4.5** | **ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់** | | | | | | |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 92. ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមមុខងារដែលបានផ្ទេរ | ការផ្ទេរ | អនុវត្ត | 1 | 20% | បានចូលរួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីពិនិត្យផ្ដល់យោបល់ជាតុចូលសំខាន់ៗ និងកែសម្រួលលើសេចក្ដីព្រាងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | 93. សេចក្តីណែនាំស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | សេចក្តីណែនាំ | 1 | 0 | 0% | គ្រោងអនុវត្តនៅឆ្នាំ២០២៦។ |
| **4.6** | **មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ** | | | | | | |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | 94. ទំហំធនធានមូលនិធិក្រុង ស្រុក | ទំហំថវិកា | កើនឡើង | កើនឡើង | 12.80% | មូលនិធិក្រុង ស្រុកមានកើនឡើង១២,៨០%។ |
| | | 95. ទំហំធនធានមូលនិធិឃុំ សង្កាត់ | ទំហំថវិកា | កើនឡើង | កើនឡើង | 12.80% | មូលនិធិឃុំ សង្កាត់មានកើនឡើង១២,៨០%។ |
| 4.6.3 | ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា | 96. លិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីអនុវត្តគម្រោងសេវាសង្គម អនាម័យ និងបរិស្ថាន | លិខិតបទដ្ឋាន | 1 | 1 | 100% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានដាក់ចេញនូវសារាចរណែនាំអន្តរក្រសួងស្តីពីការគ្រប់គ្រងការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់។ |
| **4.7** | **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែ | 97. ថវិកាសម្រាប់អនុវត្តមុខងារសំខាន់ៗដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានផ្ទេរ | លិខិតបទដ្ឋាន | 1 | 1 | 100% | បានដាក់ឱ្យអនុវត្តនូវសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | លម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង | | | | | | ប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| **4.8** | **ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិធំទូលាយសាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត** | | | | | | |
| 4.8.1 | ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | 98. គោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានពិនិត្យ និងកែសម្រួល | គោលការណ៍ | 1 | ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ | 70% | បានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក។ |
| 4.8.2 | ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព និងកញ្ចប់ថវិកាពិសេស | 99. លិខិតបទដ្ឋានសម្រាប់បង្កើតយន្តការមូលនិធិភាតរភាពត្រូវបានរៀបចំ | លិខិតបទដ្ឋាន | 1 | អនុក្រឹត្យ | 100% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវអនុក្រឹត្យស្តីពីមូលនិធិភាតរភាពដែលបានអនុម័តនៅថ្ងៃទី........... |
| **4.9** | **ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព** | | | | | | |
| 4.9.1 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 100. នីតិវិធីសម្រាប់ការគ្រប់គ្រង និងការចុះបញ្ជីគម្រោងវិនិយោគដែលមានដើមទុនសមមូល៥លានដុល្លារចុះនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | សេចក្តីណែនាំ | 100% | បានបញ្ចប់ការរៀបចំសេចក្តីណែនាំស្តីពីនីតិវិធីសម្រាប់ការគ្រប់គ្រង និងការចុះបញ្ជីគម្រោងវិនិយោគដែលមានដើមទុនសមមូល៥លានដុល្លារចុះនៅរដ្ឋបាលរាជធានី ខេត្ត។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាពអនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| 5 | **ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ÷ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះសម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។** | | | | | | |
| **5.1** | **ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព** | | | | | | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច | 101. មុខងារជាកាតព្វកិច្ចត្រូវបានកំណត់ | លិខិតបទដ្ឋាន | 1 | កំពុងរៀបចំ | 10% | បាន និងកំពុងរៀបចំកំណត់នូវមុខងារជាកាតព្វកិច្ច |
| | | 102. ចំនួនមុខងារជាកាតព្វកិច្ចដែលមានសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្ត | ភាគរយ | 100% | 64% | 64% | សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារមាន ៖ មុខងារអប់រំ យុវជន និងកីឡា មុខងារសុខាភិបាល មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារ និងមុខងារគ្រប់គ្រងសំរាម និងសំណល់រឹង។ |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស | 103. នីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | បានកែសម្រួល | សេចក្តីព្រាង | 70% | បាន និងកំពុងរៀបចំសេចក្តីព្រាងស្តីពីនីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលឃុំ សង្កាត់ |
| **5.2** | **យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាថាការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួលឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | | | | |
| 5.2.3 | ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ | 104. កម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញត្រូវបានដាក់ឱ្យប្រើប្រាស់ | សិក្ខាសាលា | 1 | 1 | 100% | បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនូវការដាក់ប្រើប្រាស់កម្មវិធីកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ។ |

| **កូដ** | **សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព** | **សូចនាករ** | **ឯកតា** | **ចំណុចដៅឆ្នាំ ២០២៥** | **លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥** | | |
|---|---|---|---|---|---|---|---|
| | | | | | **ប្រចាំឆ្នាំ** | **ស្ថានភាពអនុវត្ត (%)** | **វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥** |
| | | 105. ការផ្តល់សេវាក្នុងវិស័យមួយចំនួនបានផ្តល់តាមប្រព័ន្ធអនឡាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ការផ្តល់សេវា | 14 | 14 | 100% | បានផ្តល់សេវាចំនួន១៤វិស័យគឺ វិស័យកសិកម្ម ឧស្សាហកម្ម វប្បធម៌ និងវិស័យទេសចរណ៍។ ដោយឡែកក្នុងវិស័យនីមួយៗមានការផ្តល់សេវាជាច្រើនប្រភេទផ្សេងៗគ្នា។ |
| **5.4** | **ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 5.4.1 | ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 106. សេចក្តីណែនាំស្តីពីការរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | សេចក្តីណែនាំ | 1 | សេចក្តីព្រាង | 15% | បាន និងកំពុងបន្តសិក្សាលទ្ធភាពស្តីពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ |
| 5.4.2 | ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | 107. ឯកសារបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | សៀវភៅណែនាំ | អនុម័ត | សេចក្តីព្រាង | 15% | បាននិងកំពុងពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងដាក់បញ្ចូលគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម។ |
| 5.4.3 | ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 108. ការសិក្សា និងរៀបចំទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះ និងទិន្នន័យនៃការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និង | របាយការណ៍ | អនុវត្ត | បានអនុវត្ត | 100% | លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយ UNCDF និងក្រុមហ៊ុន OIKO ក្នុងការប្រមូលទិន្នន័យផលប៉ះពាល់ពីការពីការប្រែប្រួលអាកាសធាតុនៅរាជធានី ខេត្តទាំង២៥។ |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និង សកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ចំណុចដៅឆ្នាំ ២០២៥ | លទ្ធផលសម្រេចបានធៀបនឹងចំណុចដៅឆ្នាំ២០២៥ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ស្ថានភាព អនុវត្ត (%) | វឌ្ឍនភាពសម្រេចបានឆ្នាំ២០២៥ |
| | | ផែនទីភូមិសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យាស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ និងអនុវត្ត | | | | | |
| 5.4.3 | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 109. លិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សមភាពយេនឌ័រ បរិយាបន្ន សមធម៌សង្គម និងសេវាសង្គមត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | 1 | សេចក្តីព្រាង | 70% | បានពិនិត្យ និងកែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |
| | | 110. ចំនួនភាគរយនៃគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុវត្តដោយផ្តោតលើការបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានានៅក្នុងសហគមន៍មូលដ្ឋាន | ភាគរយ | 20% | 20% | 100% | លេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការ UNCDF បានចុះកិច្ចព្រមព្រៀងក្នុងការអនុវត្តគម្រោង LoCAL កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ ដើម្បី ៖ (១). រៀបចំសំណើគម្រោង LGCC3 (២). ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (៣). រៀបចំប្រព័ន្ធហិរញ្ញប្បទានអាកាសធាតុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និង (៤). ពង្រឹងសមត្ថភាពលេខាធិការដ្ឋាន គ.ជ.អ.ប. លើការបិទបញ្ចប់លក្ខខណ្ឌហិរញ្ញប្បទានGCF។ |

# ឧបសម្ព័ន្ធទី២៖ វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៥របស់ក្រសួង ស្ថាប័ន

*(គិតជាលានរៀល)*

| ល.រ. | ក្រសួង ស្ថាប័ន | ថវិកាឆ្នាំ២០២៥ | ថវិកាចំណាយឆ្នាំ ២០២៥ | សមតុល្យ |
|---|---|---|---|---|
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | ៨.៥៥០ | ៨.៥៤៧ | ៣ |
| ២ | ក្រសួងមហាផ្ទៃ | ៣៣៨ | ១២១ | ២១៧ |
| ៣ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៤៨ | ១៨៥ | ៦៣ |
| ៤ | ក្រសួងមុខងារសាធារណៈ | ៨០ | ៤៦ | ៣៤ |
| ៥ | ក្រសួងផែនការ | ១០៣ | ៨៨ | ១៥ |
| ៦ | ក្រសួងកិច្ចការនារី | ២៧៦ | ២៧៥ | - |
| ៧ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១០៣ | ៩១ | ១១ |
| ៨ | ក្រសួងបរិស្ថាន | ៤៤ | ៤១ | ៣ |
| ៩ | ក្រសួងទេសចរណ៍ | ៦៦ | ៦៦ | - |
| ១០ | ក្រសួងពាណិជ្ជកម្ម | ៧៧ | ៥៥ | ២២ |
| ១១ | ក្រសួងធនធានទឹក និងឧតុនិយម*** | ៣៥ | ៣៥ | - |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៣៤ | ៣៥ | ២ |
| ១៣ | ក្រសួងរ៉ែ និងថាមពល | ៦៨ | ៦៧ | - |
| ១៤ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ | ១០៥ | ១០៥ | - |
| ១៥ | ក្រសួងសុខាភិបាល | ៥០ | ៤១ | ៩ |
| ១៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៩១ | ៩១ | - |
| ១៧ | ក្រសួងអប់រំ យុវជន និងកីឡា | ២៤២ | ១៩៥ | ៤៧ |
| ១៨ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៦៥ | ៦៥ | - |
| ១៩ | ក្រសួងអភិវឌ្ឍន៍ជនបទ | ៦០ | ២៧០ | (២១០) |
| ២០ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៧៥ | ៧៥ | - |
| ២១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥១ | ៥ | ៤៦ |
| ២២ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ២៨៧ | ២២៥ | ៦២ |
| ២៣ | ក្រសួងព័ត៌មាន | ២០ | ២០ | - |
| | **សរុប** | **១១.០៦៨** | **១០.៧៤៦** | **៣២២** |

# ទំហំនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២៥របស់រាជធានី ខេត្ត

*(គិតជាលានរៀល)*

| ល.រ. | រាជធានី ខេត្ត | ថវិកាឆ្នាំ២០២៥ | ថវិកាចំណាយ ឆ្នាំ២០២៥ | សមតុល្យ |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៣០៧ | ២៦៧ | ៤០ |
| ២ | បាត់ដំបង | ៦២៨ | ២០៤ | ៤២៤ |
| ៣ | កំពង់ចាម | ៨៨៦ | ៨៧៨ | ៨ |
| ៤ | កំពង់ឆ្នាំង | ២៦៣ | ១៩៣ | ៧១ |
| ៥ | កំពង់ស្ពឺ | ២៩៩ | ២៩៤ | ៥ |
| ៦ | កំពង់ធំ | ៤៧៩ | ២២១ | ២៥៨ |
| ៧ | កំពត | ១.១១២ | ១.០៤៤ | ៦៨ |
| ៨ | កណ្ដាល | ៤.៧៩៤ | ៣.៩៧៧ | ៨១៧ |
| ៩ | កោះកុង | ៧៩៧ | ៧៧៥ | ២២ |
| ១០ | ក្រចេះ | ៤៥២ | ៣៣៣ | ១១៩ |
| ១១ | មណ្ឌលគិរី | ២៥២ | ៣៤ | ២១៧ |
| ១២ | ភ្នំពេញ | ៣.៥៧៧ | ២.៧០១ | ៨៧៦ |
| ១៣ | ព្រះវិហារ | ២១២ | ៥២ | ១៦០ |
| ១៤ | ព្រៃវែង | ៥០១ | ១០០ | ៤០០ |
| ១៥ | ពោធិ៍សាត់ | ៩២៨ | ៥៦១ | ៣៦៧ |
| ១៦ | រតនគិរី | ១៨៦ | ១២១ | ៦៤ |
| ១៧ | សៀមរាប | ៤៥២ | ៣០១ | ១៥១ |
| ១៨ | ព្រះសីហនុ | ៣៥០ | ១៦៥ | ១៨៥ |
| ១៩ | ស្ទឹងត្រែង | ៤០១ | ១៣១ | ២៧០ |
| ២០ | ស្វាយរៀង | ៣៨៤ | ២៣៧ | ១៤៧ |
| ២១ | តាកែវ | ៣១៩ | ៣១៥ | ៤ |
| ២២ | ឧត្ដរមានជ័យ | ២៥០ | ១៩ | ២៣១ |
| ២៣ | កែប | ៤៦ | ៥ | ៤« |
| ២៤ | ប៉ៃលិន | ២០៩ | ៣៤ | ១៧៥ |
| ២៥ | ត្បូងឃ្មុំ | ៦៨២ | ២៦៤ | ៤១៨ |
| សរុប | | **១៨.៧៦៦** | **១៣.២២៦** | **៥.៥៣៩** |

## វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំ ២០២៥របស់ដៃគូអភិវឌ្ឍន៍

*(គិតជាលានរៀល)*

| ល.រ. | គម្រោង | ប្រភពមូលនិធិ | ថវិកា | ចំណាយ | សមតុល្យ |
|---|---|---|---|---|---|
| ១ | ការលើកកម្ពស់អាហារូបត្ថម្ភ (CNP) | WB | ៣៥.៩០២ | ២៦.០៩៤ | ៩.៨០៨ |
| ២ | ការអភិវឌ្ឍសមត្ថភាពដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) | ADB, RGC | ១៥.០៦៤ | ១០.៧៨៤ | ៤.២៨០ |
| ៣ | ការគាំទ្រមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) | ADB | ១០.០០០ | ៨.១៨៣ | ១.៨១៧ |
| ៤ | ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STA) | UNDP | ១.១៣៣ | ៣.៥៩១ | (២.៤៥៨) |
| ៥ | ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF) | WB | ១០.២៨៤ | ៦.៨១៧ | ៣.៤៦៧ |
| ៥ | ការលើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (ISAF-CSOs) | WB | ១០.៧១១ | ១០.៦៥៤ | ៥៦ |
| ៦ | ការលើកកម្ពស់វិស័យសេវាសង្គម | UNICEF | ៦៣៣ | ១.៥១២ | (៨៧៩) |
| ៧ | ការលើកកម្ពស់កិច្ចគាំពារកុមារ | UNICEF | ២.០០០ | ១.៦៤៤ | ៣៥៦ |
| ៨ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា (ISD) | GIZ | ១៧.២០០ | ១៥.៦៤០ | ១.៥៦០ |
| ៩ | សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ASAC | ១.៣២០ | ២.៦២៩ | (១.៣០៩) |
| ១០ | ពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ជំហានទី២ (Empower-II) | UNEP | ៦៤៤ | ២៥៣ | ៣៩១ |
| ១១ | ការរៀបចំហិរញ្ញប្បទានអាកាសធាតុរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា(Readiness KHM-RS-011) | GCF | ១.៧៨៥ | ៦៤ | ១.៧២១ |
| ១២ | បន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន (LoCAL) | UNCDF | ៣៧៧ | ២៧២ | ១០៥ |
| ១៣ | គម្រោងមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) | UNDP | ១៦០ | ១៦០ | ០ |
| **សរុប** | | | **១០៧.២១៣** | **៨៨.២៩៧** | **១៨.៩១៦** |

# ឧបសម្ព័ន្ធទី៣ ÷ ស្ថានភាពនៃការគ្រប់គ្រងហានិភ័យ

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| **សមាសភាពទី១ ៖ ការគ្រប់គ្រង និងការសម្របសម្រួលកម្មវិធីកំណែទម្រង់** | | | | | | |
| ១ | ធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ដែលបានសន្យាគាំទ្រដោយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត មិនបានវិភាជគ្រប់គ្រាន់ និងផ្ដល់គ្រប់ចំនួន និងទាន់ពេលវេលា | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដានការអនុវត្តគ្រោងថវិកាឆ្នាំ២០២៥ របស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត<br>➢ ពង្រឹងការតាមដានការអនុវត្តសេចក្ដីសម្រេចរួម<br>➢ ពង្រឹងទំនាក់ទំនង និងកិច្ចសហការជាមួយ MEF ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តថវិកាសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | – ឆ្នាំ២០២៥នេះ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ បានអនុវត្តសេចក្ដីសម្រេចរួមទាន់ពេលវេលា ស្របតាមទៅតាមផែនការដែលបានគ្រោងទុក។ |
| ២ | ភាពអសកម្មភាពនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់រៀមដ្ឋការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាំឱ្យដំណើរការ និងប្រសិទ្ធភាពនៃការងារកំណែទម្រង់មានការថយចុះ រួមបញ្ចូលទាំងការអនុវត្ត ផ.ស.ថ. សេចក្ដីសម្រេចរួម និងកិច្ចព្រមព្រៀងនានា | ទាប | មធ្យម | ➢ ពង្រឹងការតាមដាន និងការអនុវត្តការងារកំណែទម្រង់ដោយ គ.ជ.អ.ប. តាមរយៈកិច្ចប្រជុំ គ.ជ.អ.ប.<br>➢ ពង្រឹងការរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ជាមួយស្ថាប័នអនុវត្តនានា | – គ.ជ.អ.ប.<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាក្នុងចំនួនសមស្រប (៦លានដុល្លារ) សម្រាប់គាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ និងបានចំណាយសម្រាប់ការអនុវត្តកិច្ចការនេះចំនួនប្រមាណ៨៣% ដូចមានបរិយាយនៅផ្នែកស្ថានភាពហិរញ្ញវត្ថុខាងលើ។ |
| **សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| ១ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកមិនអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងត្រួតពិនិត្យលើការអនុវត្តការងាររបស់គណៈអភិបាល និងបុគ្គលិករបស់ខ្លួន | មធ្យម | មធ្យម | ➢ រៀបចំវគ្គបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការយល់ដឹងបន្ថែមទៅក្នុងការអនុវត្តតួនាទី និងអាណត្តិការងាររបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាល ថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្ដុះបណ្ដាលដើម្បីពង្រឹងសមត្ថភាពតួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ ការរៀបចំឱ្យមានគម្រោងចំណាយច្បាស់លាស់របស់ក្រុមប្រឹក្សានៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| ២ | មន្ត្រីរដ្ឋបាលខេត្តមិនផ្លាស់ប្តូរទម្លាប់ក្នុងការគ្រប់គ្រង និងអន្តរាគមន៍លើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋានឱ្យទៅជាការជួយគាំទ្រផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់ | មធ្យម | ខ្ពស់ | ➢ ផ្តល់គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលខេត្តអំពីទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន<br>➢ ជំរុញ និងពង្រឹងការតាមដានត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ពីក្រសួងមហាផ្ទៃ ក្នុងករណីដែលមានអាកប្បកិរិយា និងសកម្មភាពមិនសមស្របរបស់មន្ត្រីនៃរដ្ឋបាលខេត្ត | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – សាលាជាតិរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពការលើកកម្ពស់សមធម៌ និងបរិយាបន្នសង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣ | ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការបង្កើនចំនួនស្ត្រី | មធ្យម | ខ្ពស់ | ➢ ពង្រឹងការផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្ត្រលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ<br>➢ ពង្រឹងការត្រួតពិនិត្យ និងការគាំទ្រ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួងកិច្ចការនារី<br>– ក្រសួងមហាផ្ទៃ | – ផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិបានអនុម័ត |
| **សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | | | |
| ១ | សិទ្ធិអំណាចក្នុងការជ្រើសរើស និងរៀបចំបុគ្គលិកមិនអាចអនុវត្តបានតាមគោលការណ៍បទប្បញ្ញត្តិដែលបានកំណត់ | មធ្យម | មធ្យម | ➢ ការរៀបចំសេចក្តីណែនាំបន្ថែមរបស់ថ្នាក់ជាតិដើម្បីពង្រឹងការអនុវត្តគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់រួចហើយ | – ក្រសួងមុខងារសាធារណៈ<br>– ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំផែនការ និងជ្រើសរើសបុគ្គលិករបស់ខ្លួន ស្របតាមបែបបទ និងនីតិវិធីដែលមានស្រាប់។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ ការពង្រឹងការតាមដាន ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងរៀបចំបុគ្គលិក | | |
| ២ | ការវាយតម្លៃបុគ្គលិកមិនត្រូវបានអនុវត្តទៀងទាត់ និងត្រឹមត្រូវ | មធ្យម | មធ្យម | ➢ ពង្រឹងការគាំទ្រ ការតាមដានត្រួតពិនិត្យការអនុវត្តផែនការវាយតម្លៃបុគ្គលិកទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីថ្នាក់ជាតិ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងមុខងារសាធារណៈ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – បុគ្គលិកថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវាយតម្លៃរៀងរាល់២ឆ្នាំម្តងសម្រាប់ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ។ |
| ៣ | ខ្វះការចូលរួមរបស់មន្ទីរ អង្គភាពជំនាញនាំឱ្យការអភិវឌ្ឍសមត្ថភាព ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្ត មុខងារដែលបានផ្ទេរមិនសូវមានប្រសិទ្ធភាព | មធ្យម | មធ្យម | ➢ ពង្រឹងកិច្ចសហការ និងផ្តល់ការគាំទ្រដល់មន្ទីរ អង្គភាពជំនាញក្នុងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌ<br>➢ ពង្រឹងការរៀបចំ និងការអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ តាមរយៈវិធីសាស្ត្រផ្សេងៗ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– រដ្ឋបាលរាជធានី ខេត្ត | – មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាសម្រាប់អភិវឌ្ឍសមត្ថភាពមន្ត្រីការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| ៤ | ពុំមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពអន្តរកាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដានក្រសួងមហាផ្ទៃ ក្នុងការរៀបចំ និងការវិភាជថវិកាសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការផ្តល់ថវិកាគាំទ្រផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរធនធានសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – ឆ្នាំ២០២៥ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន៧៦វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៥.៥២៩នាក់ ស្ត្រីចំនួន១.៧៣៦នាក់ សម្រាប់ក្រុមគោលដៅជាមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| ៥ | សមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅមានកម្រិតក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដាន ការគាំទ្រទៅដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>➢ ការអភិវឌ្ឍសមត្ថភាពបន្ថែមទៅលើស្តង់ដានៃការអនុវត្តមុខងារដែលបានផ្ទេរក្រុង ស្រុក ខណ្ឌ | – គ.ជ.អ.ប.<br>– គ.ជ.វ.វ. ក្រសួង ស្ថាប័នអនុវត្ត | – ឆ្នាំ២០២៥នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងបានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពបន្ថែមស្តង់ដានៃការអនុវត្តមុខងារដែលបានផ្ទេរដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| **សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធកសាងផែនការ និងថវិកាថ្នាក់ក្រោមជាតិ** | | | | | | |
| ១ | រដ្ឋបាលក្រុង ស្រុកមានធនធានថវិកាផ្នែកអភិវឌ្ឍន៍តិចតួចដែលមិនអាចអនុវត្តមុខងារផ្តល់សេវា ក៏ដូចជាការឆ្លើយតបនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព | មធ្យម | មធ្យម | ➢ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងចំណាយផ្នែកអភិវឌ្ឍន៍របស់ក្រុង ស្រុក<br>➢ សិក្សា និងរៀបចំលិខិតបទដ្ឋាននានាអំពីការបង្កើនចចំណូលដល់រដ្ឋបាលក្រុង ស្រុក | – ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – មូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ ត្រូវបានវិភាជចំនួន ១,៦% នៃចំណូលចរន្តថវិកាជាតិមានការកើនឡើងចំនួន ០,១% ធៀបនឹងឆ្នាំ២០២៣។ |
| ២ | ការផ្ទេរការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពន្យារពេល | មធ្យម | ខ្ពស់ | ➢ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា | – ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | – លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃកំពុងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា។ |
| **សមាសភាគទី៥ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | | | | | | |
| ១ | ភាពយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក | ទាប | ខ្ពស់ | ➢ ជំរុញ និងពង្រឹងការរៀបចំឯកសារចាំបាច់នានានៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនានា<br>➢ លេខាធិការដ្ឋាន គ.ជ.អ.ប. តាមដាន សហការ និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការរៀបចំឯកសារពាក់ព័ន្ធនានា | - ក្រសួង ស្ថាប័ន<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | – សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន៨ រួមមាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនិវានុវត្តន៍ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ក្រសួងរ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជន និងកីឡា។ |
| ២ | រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនពុំមានបុគ្គលិក និងសមត្ថភាពសមស្របនាំឱ្យការអនុវត្តមុខងារដែលបានផ្ទេរពុំមានប្រសិទ្ធភាព | ទាប | មធ្យម | ➢ សម្របសម្រួល និងពង្រឹងកិច្ចសហការរវាងកម្មវិធីកំណែទម្រង់ទាំងបីក្នុងការសម្របសម្រួលដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើង<br>➢ ពង្រឹងការតាមដាន ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌនៅនឹងកន្លែង<br>➢ សិក្សា និងពិនិត្យមើលជម្រើសនានាក្នុងការផ្ទេរបុគ្គលិកពីមន្ទីរ អង្គភាពជំនាញទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួង ស្ថាប័ន<br>- រាជធានី ខេត្ត | - បានរៀបចំកិច្ចប្រជុំកំណែទម្រង់ទាំង៣ ចំនួន០៣លើកសម្រាប់ដោះស្រាយបញ្ហា ប្រឈមនានា<br>- ឆមាសទី១ ឆ្នាំ២០២៥នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ១៨វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួនប្រមាណ ២.៦៥៨នាក់ ស្ត្រី ១.០៦០នាក់។ |
| ៣ | មុខងារជាជម្រើសពាក់ព័ន្ធនឹងសេវាសង្គមមិនអាចអនុវត្តស្របទៅតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ទាប | មធ្យម | ➢ គោលការណ៍ណែនាំច្បាស់លាស់ស្តីពីការជ្រើសរើស ការរៀបចំ និងការអនុវត្តមុខងារជាជម្រើសដែលពាក់ព័ន្ធនឹងសេវាសង្គម<br>➢ ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់អាទិភាពដល់ការចំណាយលើការផ្តល់សេវាសង្គមសម្រាប់ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ | - ក្រសួងមហាផ្ទៃ<br>- លេខាធិការដ្ឋាន គ.ជ.អ.ប. | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន។ |
| ៤ | រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់តិចតួចអំពីអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះទាំងនៅក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងគម្រោងថវិកានានា | មធ្យម | មធ្យម | ➢ រៀបចំផែនការសកម្មភាពនិង ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួងមហាផ្ទៃ | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ ពង្រឹងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>➢ ពង្រឹងការវាយតម្លៃ និងតាមដានដល់ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំ និងអនុវត្តកម្មវិធីផ្តល់ពានរង្វាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារបានល្អ | | សម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន រួមបញ្ចូលទាំងចំណាយសម្រាប់ការងារសមភាពយេនឌ័រ បរិយាបន្ន និងសង្គម។ |
| ៥ | ក្រុង ស្រុក ខណ្ឌមួយចំនួនមិនសូវយកចិត្តទុកដាក់ និងផ្តួចផ្តើមគំនិតក្នុងការអនុវត្តលិខិតបទដ្ឋាននានាដែលមាន និងមុខងារនានាដែលបានផ្ទេរនាំឱ្យការគាំទ្ររបស់រាជធានី ខេត្ត មិនមានប្រសិទ្ធភាព | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែលបានផ្ទេរ<br>➢ ធ្វើការណែនាំដល់ក្រុង ស្រុក ខណ្ឌដែលអសកម្ម | - លេខាធិការដ្ឋាន គ.ជ.អ.ប.<br>- ក្រសួង ស្ថាប័ន<br>- រាជធានី ខេត្ត | - រដ្ឋបាលរាជធានី ខេត្តបានចុះតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជាប្រចាំក្នុងការរៀបចំ និងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។ |
| ៦ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការចំណាយបន្ថែមលើការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា | មធ្យម | ខ្ពស់ | ➢ កៀរគរធនធានបន្ថែមពីមូលនិធិអាកាសធាតុបៃតង និងពីប្រភពផ្សេងទៀត ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ | - លេខាធិការដ្ឋាន គ.ជ.អ.ប. | - រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលបានថវិកាមួយចំនួន ដើម្បីអនុវត្តគម្រោងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| ៧ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | មធ្យម | មធ្យម | ➢ បញ្ចូលការលើកកម្ពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុទៅក្នុងវគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | - លេខាធិការដ្ឋាន គ.ជ.អ.ប. | - អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិកាជាតិជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ បានកំណត់ច្បាស់លាស់អំពីសមាសភាគសម្រាប់ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន រួមបញ្ចូលទាំងចំណាយសម្រាប់ការពង្រឹងភាពធន់ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។ |

# ឧបសម្ព័ន្ធទី៤ ៖ គម្រោងផាច់ដោយឡែកដែលបានគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| ល.រ | គម្រោង/គោលបំណង | រយៈពេលអនុវត្ត | គាំទ្រដោយ | ថវិកា | ភ្នាក់ងារអនុវត្ត | វឌ្ឍនភាពគម្រោង |
|---|---|---|---|---|---|---|
| ១ | **គម្រោង៖**<br>ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF)<br>**គោលបំណង៖**<br>គម្រោងមានគោលដៅធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងធ្វើឱ្យក្លាយទៅជាប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវតម្លាភាព ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបតម្រូវការនានា។ | ២០២៣-២០២៥ | មូលនិធិបរធនបាលកិច្ចគ្រប់គ្រងដោយធនាគារពិភពលោក (គាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី) | ៤លានដុល្លារ (សម្រាប់ផ្នែកផ្គត់ផ្គង់ និងតម្រូវការ) | លេខាធិការដ្ឋាន គ.ជ.អ.ប. | -បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង និងពិភាក្សាលើនិន្នាភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ មានការចូលរួមពីលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ សរុបចំនួន ១២០នាក់។<br>-បានផ្សព្វផ្សាយ I4Cs និងលទ្ធផលបំពេញការងាររបស់អង្គភាពផ្តល់សេវា យ៉ាងទូលំទូលាយតាមរយៈកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម (SA Mobile App)។ |
| ២ | **គម្រោង៖**<br>ការលើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (CSOs)<br>**គោលបំណង៖**<br>គម្រោងមានគោលដៅធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងធ្វើឱ្យក្លាយជាប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងតម្លាភាព ពង្រឹង | ២០២៤-២០២៥ | មូលនិធិបរធនបាលកិច្ចគ្រប់គ្រងដោយធនាគារពិភពលោក (គាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី USAID) | ៧.០៩ លានដុល្លារ | • អង្គការទស្សនៈពិភពលោក<br>• អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)<br>• អង្គការអុកស្វាមប្រចាំកម្ពុជា | |

| | | | | | | |
|---|---|---|---|---|---|---|
| | ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបតម្រូវការនានា។ | | | | | |
| ៣ | **គម្រោង៖**<br>កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា (ISD/GIZ)<br>**គោលបំណង៖**<br>គម្រោងមានគោលបំណងលើកកម្ពស់ការផ្តល់សេវាសាធារណៈដោយមានការចូលរួមពីប្រជាពលរដ្ឋ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ | ខែមីនា ឆ្នាំ ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៥ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (ជី អាយ ហ្សេត GIZ) កម្ពុជា | ៩.៨១៨.១៨២អឺរ៉ូ ស្មើនឹង ១០.៥២២.៣៦៥ ដុល្លារ | អនុវត្តដោយ ISD ក្រោមកិច្ចសហប្រតិបត្តិការ លេខាធិការដ្ឋាន គ.ជ.អ.ប. អគ្គនាយដ្ឋានរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន | – បន្តរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងក្រុង ស្រុកគោលដៅចំនួន០៦ដែលគិតគូដល់ការប្រែប្រួលអាកាសធាតុ ការចូលរួម និងមានលក្ខណៈសមស្របសម្រាប់ពង្រីកវិសាលភាពទៅបណ្តាស្រុក ឬក្រុងផ្សេងទៀតសម្រាប់យកទៅអនុវត្ត តាមរយៈការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំផែនការគ្រប់គ្រងសំរាម និងសំណល់រឹង និងរៀបចំយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក។<br>– បន្តរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងទឹកនៅក្នុងក្រុង ស្រុកគោលដៅចំនួន០៤ ដែលគិតគូដល់ការបម្រែបម្រួលអាកាសធាតុ ការចូលរួម និងមានលក្ខណៈសមស្របសម្រាប់ពង្រីកវិសាលភាពទៅបណ្តាស្រុក ឬក្រុងផ្សេងទៀតសម្រាប់យកទៅអនុវត្ត តាមរយៈការគាំទ្រដល់រដ្ឋបាលក្រុង ស្រុកគោលដៅក្នុងការកែតម្រូវកិច្ចព្រមព្រៀងផ្តល់ហិរញ្ញវត្ថុរួមគ្នារវាងដៃគូពាក់ព័ន្ធនៅថ្នាក់ខេត្ត រៀបចំសេចក្តីព្រាងដំបូងនៃការគ្រប់គ្រងទឹក ដែលគិតពីបម្រែបម្រួលអាកាសធាតុ និងរៀបចំផែនការហ្វឹកហ្វឺនប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដល់ក្រុង ស្រុកគោលដៅ។<br>បន្តការអនុវត្តសាកល្បងនៃការចូលរួមថែទាំសុខភាព និងអាហារូបត្ថម្ភរបស់សហគមន៍ទៅឱ្យរដ្ឋបាលឃុំ សង្កាត់តាមរយៈការបន្តគាំទ្រដល់បេសកកម្មគាំទ្រការអនុវត្តគម្រោងលើកទី៨ របស់ធនាគារពិភពលោក និងបន្តកសាងសមត្ថភាពអ្នកអនុវត្តសំខាន់ៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៤ | **គម្រោង៖**<br>ពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាល II (EmPower II) | ២ឆ្នាំ | • UNEP | ១៦១.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | ការលើកម្ពស់ការពង្រឹងសមត្ថភាពដល់ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ មន្ត្រីបច្ចេកទេសទទួលបន្ទុកប្រែប្រួលអាកាសធាតុ និងថាមពលស្អាតរបស់ក្រសួងបរិស្ថាន ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ និងមន្ត្រីទទួលបន្ទុកការងារយេនឌ័ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប. អំពីការបញ្ជ្រាបយេនឌ័រ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | បរិយាបន្នសង្គមក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុជាតិ។<br>- ពិនិត្យគោលនយោបាយដែលមានស្រាប់ទាក់ទងទៅនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ<br>- ជួបសម្ភាសន៍ផ្ទាល់ជាមួយជនបង្គោលសំខាន់ៗ ៖<br>○ ទី១ ៖ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ មានសមាជិកសមាជិកា ចំនួន៣៨រូប ស្ត្រី០៤<br>○ ទី២ ៖ ក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យ មានសមាជិកសមាជិកា ចំនួន ១១រូប ស្ត្រី០២<br>○ ទី៣ ៖ ក្រុមការងារយេនឌ័រសម្រាប់គាំទ្រការអនុវត្ត ផអ៥ ដំណាក់កាល ១&២ នៃNP2 មានសមាជិកសមាជិកា ចំនួន១៨រូប ស្ត្រី១១<br>○ ទី៤ ៖ ក្រុមការងារទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងមូលនិធិអាកាសធាតុ មានសមាជិកសមាជិកា ចំនួន១១រូប ស្ត្រី០៤។ សរុប០៤ ក្រុម ៧៨រូប ស្ត្រី២១ រូប។ |
| ៥ | **គម្រោង៖**<br>ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (UNDP/STA)<br>**គោលបំណង៖**<br>ដើម្បីបង្កើនការចូលរួម និងការទទួលយោបល់ត្រលប់របស់ប្រជាពលរដ្ឋការបំពេញការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការ | ២០២៣-២០២៥ | រាជរដ្ឋាភិបាលជប៉ុន តាមរយៈកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (UNDP) | .<br>៨៩៧.៧៥២ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | -បានបង្កើតក្រុមការងារពិគ្រោះយោបល់សម្រាប់ការវាយតម្លៃកម្មវិធីជាតិ និងការអង្កេតអភិបាលកិច្ចរួចរាល់ស្របទៅតាមកិច្ចព្រមព្រៀងគម្រោង ដោយមានតំណាងដឹកនាំជាប្រធានក្រុមការងារពីបានបញ្ចប់និងដាក់ឲ្យដំណើរការគេហទំព័រចែករំលែកព័ត៌មានជាសាធារណៈរបស់រដ្ឋបាលនៅក្រុងសៀមរាប ក្រុងកំពង់ចាម និងក្រុងបានលុងតាមរយៈឈ្មោះដែន (Domain name) របស់រដ្ឋបាលក្រុងនីមួយៗដូចជា ៖ krongsiemreap.gov.kh, krongkampongcham.gov.kh, krongbanlung.gov.kh<br>-ការអង្កេតវាយតម្លៃសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពិនិត្យរៀបចំបញ្ជីសំនួរ ប្រព័ន្ធKobo Tool Box ជ្រើសរើសនិងបណ្តុះបណ្តាលក្រុមការងារប្រមូលទិន្នន័យ ដើម្បីអនុវត្តនៅតាមរដ្ឋបាលរាជ |

| | | | | | | |
|---|---|---|---|---|---|---|
| | គាំទ្រការអនុវត្តគោលនយោបាយនៅថ្នាក់ជាតិ។ | | | | | ធានី ខេត្តចំនួន១២ គឺៈ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តរតនគិរី ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តតាកែវ និងខេត្តត្បូងឃ្មុំ និងនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់<br>-បានដំឡើង និងដាក់ដំណើរការServersចំនួន២បន្ថែម ដើម្បីពង្រីកសមត្ថភាពផ្ទុកទិន្នន័យសម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងបានកែលម្អគេហទំព័ររបស់ គ.ជ.អ.ប. ព្រមទាំងបានពិភាក្សាក្នុងក្រុមការងារបច្ចេកទេសអំពីជម្រើសនានាសម្រាប់ការរៀបចំ និងការផ្សព្វផ្សាយទិន្នន័យនានាក្នុងគេហទំព័ររបស់គ.ជ.អ.ប.។ |
| ៦ | **គម្រោងៈ**<br>Readiness KHM-RS-011 ស្តីពីការអភិវឌ្ឍហិរញ្ញប្បទានអាកាសធាតុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា<br>**គោលបំណងៈ**<br>ដើម្បីសិក្សានិងរៀបចំនូវក្របខ័ណ្ឌ និងយន្តការសម្រាប់ការវិនិយោគលើសកម្មភាពប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ដោយបន្សីជាមួយសកម្មភាពបន្សាំជាតិ គោលនយោបាយប្រែប្រួលអាកាសធាតុរបស់ក្រសួងបរិស្ថាន និងមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២ឆ្នាំ | GCF | ៤៤១.៤៦០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង UNCDF | -បានបង្កើតក្រុមការងារគាំទ្រ និងសម្របសម្រួលកម្មវិធី **Readiness KHM-RS-011** តាមរយៈសេចក្តីសម្រេចលេខ០០២ ស.ស.រ/គ.ជ.អ.ប ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៥<br>-បានរៀបចំផែនការសកម្មភាព និងថវិកាកម្មវិធី**KH-011** និងទទួលបានការពិនិត្យអនុម័តដោយឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២៥<br>-បាននឹងកំពុងជ្រើសរើសទីប្រឹក្សា និងមន្ត្រីគម្រោង រួមមាន **National Program Coordinator, Finance and admin Officer, M&E Office**<br>-បានពិភាក្សាជាមួយទីប្រឹក្សា **UNCDF** ដើម្បីជ្រើសរើស **Professional Consulting Firm** (ជ្រើសរើសដោយ **UNCDF**) |
| ៧ | **គម្រោងៈ**<br>អាហារូបត្ថម្ភនៅកម្ពុជា (CNP)<br>**គោលបំណងៈ** | ២០១៩-២០២៦ | ធនាគារពិភពលោក (WB) និងអាល្លឺម៉ង់ | ១៧.៨០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. | លទ្ធផលសម្រេចបានទី១ៈ ការវាយតម្លៃលទ្ធផលបំពេញការងាររបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ បានវាយតម្លៃលទ្ធផលនៃការបំពេញការងារមូលនិធិគាំទ្រការផ្តល់សេវាឃុំ |

| | | | | | | |
|---|---|---|---|---|---|---|
| | ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងគុណភាពនៃសេវាសុខភាព និងអាហារូបត្ថម្ភជាអាទិភាពសម្រាប់មាតា និងកុមារសម្រាប់ក្រុមគោលដៅនៅក្នុងប្រទេសកម្ពុជា។ | | | | | សង្កាត់ របស់រដ្ឋបាលឃុំ សង្កាត់ចំនួន៣៦៥ និងរដ្ឋបាល ក្រុង ស្រុកគោលដៅចំនួន៦០ នៃខេត្តគោលដៅចំនួន៩ និងបានការផ្ទេរមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់សរុបចំនួន ១,៦២៣,៤៨២.៥១ ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះចំនួន ១,៥២៤,១១៩.៤៥ ដុល្លារសហរដ្ឋអាមេរិកបានផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់ចំនួន៣៦៥ និងចំនួន ៩៩,៣៦៣.០៦ ដុល្លារសហរដ្ឋអាមេរិកបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៦០<br>-លទ្ធផលសម្រេចបានទី២៖ ការកសាងសមត្ថភាព បានបើកវគ្គបណ្តុះបណ្តាលចំនួន១៤ វគ្គក្នុងនោះមាន៖ (១). វគ្គបណ្តុះបណ្តាលគ្រូឧទេស្ទថ្នាក់ក្រុង ស្រុកស្តីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ចំនួន១ វគ្គរយៈពេល៣ ថ្ងៃដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣០ នាក់ ក្នុងនោះមានស្ត្រីចំនួន ១៥ នាក់ (២). វគ្គបណ្តុះបណ្តាលស្តីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ចំនួន៦ វគ្គរយៈពេល ២ ថ្ងៃក្នុងមួយវគ្គដែលមានសិក្ខាកាមចូលរួមសរុបចំនួន២២០នាក់ ក្នុងនោះមានស្ត្រីចំនួន៧៣នាក់។ |
| ៨ | **គម្រោង៖**<br>ការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍដោយចីរភាព (SDGs) | ៦ខែ | UNDP | ៤០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលក្រុងសៀមរាប និងកំពង់ចាម | បានផ្តល់វគ្គបណ្តុះបណ្តាលការដាក់បញ្ចូលគោលដៅអភិវឌ្ឍន៍ដោយចីរភាពទៅក្នុងផែនការអភិវឌ្ឍន៍ក្រុងកំពង់ចាម និងសៀមរាប ដោយមានការចែករំលែកបទពិសោធន៍ពីរដ្ឋបាលក្រុងនិងខេត្តនៃសាធារណៈរដ្ឋបារាំង។ បានសាងសង់សួនច្បារ២កន្លែងជាការសាកល្បងអនុវត្តនូវការគិតគូរលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋក្នុងក្រុង។ និងបានបិទបញ្ចប់គម្រោងនៅខែធ្នូ ឆ្នាំ២០២៥។ |
| **សំណើគម្រោងថ្មី** | | | | | | |
| ១ | **គម្រោង៖**<br>រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុជំហានទី៣ (LGCC-III) | ៥ឆ្នាំ | GCF | ១០.០០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង UNCDF | លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយអង្គការ UNCDF ក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចដើម្បីប្រមូលព័ត៌មាន និងពិគ្រោះយោបល់ជាមួយនឹងជនជាតិ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ដើមភាគតិច និងសិក្សាផលប៉ះពាល់អំពីការវិនិយោគ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់គោលដៅចំនួនបីរួមមាន ខេត្តព្រះវិហារ ខេត្តបាត់ដំបង និងខេត្តពោធិសាត់ ព្រមទាំងលើកឡើងនូវយន្តការបន្ធូរបន្ថយផលប៉ះពាល់អវិជ្ជមាននានា ក្នុងគោលបំណងបំពេញលក្ខខណ្ឌស្នើសុំហិរញ្ញប្បទានពីមូលនិធិអាកាសធាតុបៃតងសម្រាប់រៀបចំសំណើគម្រោង LGCC ជំហានទី៣។ គម្រោងបានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល GCF កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ និងត្រូវអនុវត្តនៅដើមឆ្នាំ២០២៦។ |
| ២ | **គម្រោង៖**<br>សេវាកម្មទឹក និងអនាម័យនៅក្នុងក្រុងណេបអាទិភាពដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត (CR-Wash) | ៥ឆ្នាំ | GCF | ១០.០០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង GGGI | ស្ថិតនៅក្នុងដំណាក់កាលរៀបចំឯកសារទស្សនទានគម្រោង (Concept Note)៖<br>- បានឯកភាព និងអនុម័តលើការពន្យារពេលបញ្ចប់កិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និង GGGI រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤<br>- បានបញ្ជូនលិខិតស្នើសុំកិច្ចប្រជុំជាមួយមូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ចសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា (KECF)។ លទ្ធផលស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជានឹងផ្តល់កាលបរិច្ឆេទនៅពេលជាក់លាក់ណាមួយលើកិច្ចប្រជុំ។ |
| ៣ | **គម្រោង៖**<br>ការធ្វើឱ្យប្រសើរឡើងនូវកសិកម្មអេកូឡូស៊ីដែលងាយរងគ្រោះដោយសារអាកាសធាតុនៅតំបន់ខ្ពង់រាប (Agroecological transitions) | ៥ឆ្នាំ | GCF | ១០.០០០.០០០ដុល្លារ | លេខាធិការដ្ឋាន គ.ជ.អ.ប.និង UNDP | ស្ថិតនៅក្នុងដំណាក់កាលរៀបចំឯកសារទស្សនទានគម្រោង (Concept Note)៖<br>- បានប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីកសិកម្ម និងនីតិកម្មរបស់ GCF លើការស្នើសុំសម្របសម្រួលលើលក្ខខណ្ឌពិសេសសម្រាប់កិច្ចសន្យារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និង UNDP។ ជាលទ្ធផលនៃកិច្ចប្រជុំនេះមន្ត្រីនីតិកម្មរបស់ GCF បានផ្តល់អនុសាសន៍លើការរៀបចំពិសេសសម្រាប់កិច្ចសន្យារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងUNDP សម្រាប់តែគម្រោងមួយនេះទេ ដោយយោងគោលនយោបាយហិរញ្ញវត្ថុរបស់ UNDP តម្រូវឱ្យមានលក្ខខណ្ឌពិសេសនេះក្នុងការរាយការណ៍ជា |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | របាយការណ៍ហិរញ្ញវត្ថុឱ្យស្របលើគោលការណ៍ Single Audit Principles<br>- បានស្នើសុំកិច្ចប្រជុំជាមួយធនាគារពិភពលោកនៅក្នុងខែមិថុនា ឆ្នាំ២០២៤។ ធនាគារពិភពលោកយល់ព្រមតាមការស្នើសុំជួប គឺនៅសប្តាហ៍ទី២នៃខែមិថុនា ឆ្នាំ២០២៤<br>- លោក Shakeel Deputy Resident of UNDP បានស្នើសុំជំនួបពិភាក្សាលើឯកសារទស្សនទានគម្រោង (Concept Note)។ លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលយកសំណើនេះនឹងពិចារណារកពេល ដើម្បីពិភាក្សាការងារនេះ<br>- បានរៀបចំសេចក្តីព្រាងសំណើគម្រោងសម្របសម្រួលក្នុងការរៀបចំគម្រោង (PPF)។ |
| ៤ | **គម្រោង៖**<br>ការពង្រឹងប្រព័ន្ធយន្តការបង្ការ និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅប្រទេសកម្ពុជា | ៥ឆ្នាំ | ADB | ៧លានដុល្លារ | ក្រសួងកិច្ចការនារី<br>ក្រសួងមហាផ្ទៃ<br>និងលេខាធិការដ្ឋាន គ.ជ.អ.ប. | - រៀបចំសេចក្តីព្រាងអនុសារណៈយោគយល់រវាង ADB និងក្រសួងកិច្ចការនារី |

